**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**

**Université royale de droit et des sciences Economiques**

**Royal University of law and Economic**


## សារណាបញ្ចប់ការសិក្សា

# នីតិវិធីស៊ើបសួររឿងក្តីព្រហ្មទណ្ឌបច្ចុប្បន្ន ក្នុងព្រះរាជាណាចក្រកម្ពុជា

ស្រាវជ្រាវចាប់ពីថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២១ ដល់ថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២១


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **ភេត ម៉េងគាន**

**ឡៀង ធីថាង**

សាស្ត្រាចារ្យណែនាំ

សាស្ត្រាចារ្យ **ជួន ប៊ុនធី**


ថ្នាក់បរិញ្ញាបត្រ: **នីតិសាស្ត្រ**

ជំនាន់ទី ២១

ឆ្នាំចូលសិក្សា ២០១៧

ឆ្នាំសរសេរសារណា ២០២១

**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**

**Université royale de droit et des sciences Economiques**

**Royal University of law and Economic**

## សារណាបញ្ចប់ការសិក្សា

# នីតិវិធីស៊ើបសួររឿងក្តីព្រហ្មទណ្ឌបច្ចុប្បន្ន ក្នុងព្រះរាជាណាចក្រកម្ពុជា

ស្រាវជ្រាវចាប់ពីថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២១ ដល់ថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២១

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **កេត ម៉េងគាន**

**ខៀង ធីថាវ**

សាស្ត្រាចារ្យណែនាំ

សាស្ត្រាចារ្យ **ជួន ម៉ុនធី**

ថ្នាក់បរិញ្ញាបត្រ: **នីតិសាស្ត្រ**

ជំនាន់ទី ២១

ឆ្នាំចូលសិក្សា ២០១៧

ឆ្នាំសរសេរសារណា ២០២១

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំ ឈ្មោះ **គេត ម៉េងគាន** និង **ខៀង ធីថាវ** ជានិស្សិតថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រឆ្នាំទី៤ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ចឆ្នាំ ២០១៧-២០២១ជំនាន់ទី ២១។

**សូមលំអោនកាយក្រាបប្រណិប័តន៍ និងសម្តែងនូវកតញ្ញូតាធម៌ និងកតវេទីយ៉ាងខ្ពង់ខ្ពស់ចំពោះជីដូនជីតា ក្រុមគ្រួសារ ជាពិសេសមាតាបិតា៖**

**លោកឪពុក ហេង គេត　　លោកឪពុក ខៀង ឃុំងយីក**

**អ្នកម្តាយ លាន ដានី　　អ្នកម្តាយ ដាំង ធីភឿង**

អ្នកមានគុណទាំងទ្វេរដែលបានផ្តល់កំណើត និងពលីកម្មគ្រប់បែបយ៉ាងដើម្បីចិញ្ចឹមបីបាច់ថែរក្សា ផ្តល់នូវភាពកក់ក្តៅ សេចក្តីស្រលាញ់អនុគ្រោះ ព្រហ្មវិហារធម៌ និងអប់រំទូន្មានកូន ឲ្យប្រព្រឹត្តខ្លួនដើរតាមគន្លងធម៌ ព្រមទាំងទំនុកបម្រុងគ្រប់បែបយ៉ាង ទាំងផ្នែកសម្ភារៈ និងស្មារតីជាពិសេស លោកតែងតែនៅចាំលើកទឹកចិត្តដល់កូន ទាំងការសិក្សា និងកិច្ចការផ្សេងៗ ទៀតតាំង ពីថ្នាក់បឋមសិក្សា រហូតដល់ថ្នាក់បរិញ្ញាបត្រនៅសាកលវិទ្យាល័យ ហើយទទួលបានជោគជ័យដោយមោទនភាព។ ព្រហ្មវិហារធម៌ និងឧបការគុណរបស់លោកពិតជាមានតម្លៃណាស់មិនអាចកាត់ថ្លៃបានឡើយ។

**សូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតជូនចំពោះ**

- **ឯកឧត្តមបណ្ឌិត លុយ ចណ្ណា សាកលវិទ្យាធិការ** សាកលវិទ្យាធិការរង ថ្នាក់ដឹកនាំ និងលោក លោកស្រីសាស្ត្រចារ្យ ទាំងអស់ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានសម្រួល និងគាំទ្រដល់ការសិក្សារបស់យើងខ្ញុំយ៉ាងយកចិត្តទុកដាក់នូវគ្រប់វិជ្ជាដ៏មានតម្លៃទើបធ្វើឲ្យខ្ញុំទទួលបានចំណេះដឹងដ៏ឧត្តុងឧត្តម ដើម្បីទុកជាអាវុធដ៏មានប្រសិទ្ធិភាពសម្រាប់កែលម្អជីវិតទៅថ្ងៃអនាគត។
- លោកសាស្ត្រាចារ្យ **ជួន ម៉ុនធី** ដែលជាសាស្ត្រចារ្យដ៏មានទេពកោសល្យ និងមានបទពិសោធន៍ផ្ទាល់ ដោយលោកបានចំណាយពេលវេលាដ៏មានតម្លៃ និងកម្លាំងកាយចិត្តដើម្បីធ្វើការណែនាំ បង្ហាត់បង្ហាញ ផ្តល់យោបល់ និងផ្តល់នូវវិធីសាស្ត្រល្អៗ ក្នុងការសរសេរសារណារបស់យើងខ្ញុំឲ្យបានល្អប្រសើរ រហូតបានចងក្រងសារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រនេះដោយជោគជ័យ។

ជាទីបញ្ចប់ យើងខ្ញុំទាំងទ្វេរសូមប្រសិទ្ធិពរជ័យ ដល់មាតាបិតា ជីដូនជីតា ក្រុមគ្រួសារ អាណាព្យាបាល ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង សាស្ត្រាចារ្យ គណៈគ្រប់គ្រងសាលា និងមន្ត្រីគ្រប់ផ្នែកទាំងអស់ សូមឲ្យជួបប្រទះតែនឹងសេចក្តីសុខ សេចក្តីចម្រើនជាពិសេសសូមឲ្យទទួលបានជោគជ័យគ្រប់ភារកិច្ចការងារ និងសូមឲ្យជួបតែពុទ្ធពរទាំងបួនប្រការគឺ **អាយុ វណ្ណៈ សុខៈ ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

យើងខ្ញុំជានិស្សិត នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ផ្នែកនីតិសាស្ត្រ ជំនាន់ទី២១ ឆ្នាំសិក្សា ២០១៧ - ២០២០ ក្រោយពីធ្លាប់បានឆ្លងកាត់ការសិក្សារបស់សាកលវិទ្យាល័យ និងការស្រាវជ្រាវនានា។ នៅឆ្នាំទី៤ នេះដែលជាឆ្នាំបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រដោយ មានឱកាសដ៏មានតម្លៃក្នុងការសរសេរសារណានេះយើង ខ្ញុំបានជ្រើសរើសយកនូវប្រធានបទមួយស្តីពី **នីតិវិធីស៊ើបសួររឿងក្តីព្រហ្មទណ្ឌបច្ចុប្បន្នក្នុងព្រះរាជាណាចក្រកម្ពុជា**ដើម្បីយកមកធ្វើការសិក្សាស្រាវជ្រាវនិងចងក្រងជាសារណានេះឡើង។

យើងខ្ញុំបានសម្រេចជ្រើសយកប្រធានបទនេះមកធ្វើការស្រាវជ្រាវ និងចងក្រងឡើងក្នុងគោលបំណងដើម្បីទុកជាឯកសារ សម្រាប់បំពេញនូវតម្រូវការរបស់សិក្សា និស្សិតជំនាន់ក្រោយនឹងជួយដល់អស់លោកអ្នកទាំងអស់ ដែលបានសិក្សាស្រាវជ្រាវជំនាញនីតិសាស្ត្រហើយចង់ធ្វើការសិក្សាបន្តទៅនឹងអ្វីដែលទាក់ទងនឹងប្រធានបទនេះ។ ជាពិសេសយើងខ្ញុំចង់ដឹង និងចង់សិក្សាឲ្យស៊ីជម្រៅច្បាស់លាស់បន្ថែមទៀតទៅលើខ្លឹមសារ និងអត្ថន័យនៃក្រមនីតិវិធីព្រហ្មទណ្ឌទាំងមូលជាក់ស្តែងជុំវិញប្រធានបទស្តី **នីតិវិធីស៊ើបសួររឿងក្តីព្រហ្មទណ្ឌបច្ចុប្បន្នក្នុងព្រះរាជាណាចក្រកម្ពុជា** ជាការពិតណាស់ សារណាបញ្ចប់ការសិក្សានេះ ប្រាកដជាមានលេចឡើងនូវចំណុចខ្វះខាតមួយចំនួនជាក់ជាពុំខាន។

អាស្រ័យហេតុនេះ យើងខ្ញុំសូមធ្វើការអភ័យទោសទុកជាមុនពីសំណាក់លោកលោកស្រី សាស្ត្រាចារ្យ មិត្តអ្នកអាន អ្នកស្រាវជ្រាវនានា ក្នុងករណីស្នាដៃនេះ មានកំហុសខុសឆ្គងត្រង់ប្រការណាមួយទាំងខ្លឹមសារ និងអក្ខរាវិរុទ្ធ រួមទាំងចំណុចលើសលប់ ឬខ្វះខាត ឬខ្លឹមសារមិនពិស្តារត្រង់ចំណុចណាមួយដែលបានលេចឡើងដោយអចេតនា។ជាទីបញ្ចប់យើងខ្ញុំពិតជាមានសេចក្តីសោមនស្សរីករាយ ក្នុងការទទួលយកនូវមតិរិះគន់ ការទិតៀននានាក្នុងន័យស្ថាបនាពីគ្រប់មជ្ឈដ្ឋានជុំវិញដើម្បីជាការកែលម្អនូវកំហុសឆ្គង ចំណុចខ្វះខាត ក៏ដូចជាការរួមចំណែកនូវការអភិវឌ្ឍន៍សមត្ថភាពចំណេះដឹងឲ្យមានលក្ខណៈប្រសើរឡើងជា មុនព្រមទាំងធ្វើឲ្យសារណាមួយនេះកាន់តែមានលក្ខណៈត្រឹមត្រូវ និងមានភាពសុក្រឹតឡើងថែមមួយកម្រិតទៀត។ ម្យ៉ាងវិញទៀត ក្នុងការសិក្សាស្រាវជ្រាវ និងការចងក្រងសារណានេះឡើងក្នុងគោលដៅដើម្បីទទួលបាននូវបទពិសោធន៍ក្នុងការរៀបចំសៀវភៅ និងកែប្រែចំណុចខ្វះខាត ផ្នែកអក្ខរាវិរុទ្ធ ឲ្យកាន់តែប្រសើរឡើង។ នៅក្នុងការសិក្សាស្រាវជ្រាវ និងចងក្រងឯកសារនេះឡើង ប្រាកដជាមាននូវចំណុចខ្វះខាតខាងផ្នែកខ្លឹមសារ និងមានកំហុសខុសឆ្គង ដែលកើតមានឡើងក្នុងឯកសារនេះនឹងទទួលបាននូវការអធ្យាស្រ័យ និងអភ័យទោសពីសំណាក់ ឯកឧត្តម លោកជំទាវ លោក លោក ស្រី សាស្ត្រាចារ្យ និងមិត្តអ្នកអាន គ្រប់មជ្ឈដ្ឋានជាមិនខាន។

ជាទីបញ្ចប់ខ្ញុំសូមគោរពជូនពរដល់ ឯកឧត្តម លោក ជំទាវ លោក លោកស្រី សាស្ត្រាចារ្យ និងមិត្តអ្នកអានទាំងអស់សូមជួបប្រទះតែសំណាងល្អ និងជោគជ័យភារកិច្ចព្រមទាំងពុទ្ធពរទាំងបួនប្រការគឺ**អាយុ វណ្ណៈ សុខៈ ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ

# មាតិកា

ទំព័រ

**សេចក្តីផ្តើម** ........................................ ១

**ជំពូកទី១**
**មន្ទីរស៊ើបសួរនៃសាលាដំបូង**
........................................ ៣

**ផ្នែកទី១៖ សញ្ញាណទូទៅនៃចៅក្រមស៊ើបសួរនៃមន្ទីរស៊ើបសួរ** ........................................ ៣
**កថាខណ្ឌទី១៖ ការទទួលបានគុណសម្បត្តិជាចៅក្រមស៊ើបសួរ** ........................................ ៣
១.១.លក្ខន្តិកៈនៃចៅក្រមស៊ើបសួរ ........................................ ៣
១.២.ការដកហូត និង វិសមិតភាព ........................................ ៣
**កថាខណ្ឌទី២ សមត្ថកិច្ចរបស់ចៅក្រមស៊ើបសួរ** ........................................ ៤
២.១.សមត្ថកិច្ចដែនដី ........................................ ៤
២.២.សមត្ថកិច្ចតាមរឿងក្តី ........................................ ៦
**ផ្នែកទី២៖ ដំណើរការស៊ើបសួរតាមភាលប្បវត្តិរបស់ចៅក្រមស៊ើបសួរ** ........................................ ៧
**កថាខណ្ឌទី១៖ ការបើកការស៊ើបសួរ** ........................................ ៧
១.១.លក្ខណៈទម្រង់នៃបណ្តឹង និង អានុភាពនៃបណ្តឹង ........................................ ៧
១.១.១.ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់ព្រះរាជអាជ្ញា ........................................ ៧
១.១.២.ការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីតាមផ្លូវអន្តរាគមន៍ ........................................ ៧
១.១.៣.អានុភាពនៃបណ្តឹង ........................................ ៧
១.២.វិសាលភាពនៃបណ្តឹង ........................................ ១១
១.២.១.ព្រំដែនស៊ើបសួរនៃបណ្តឹងចំពោះអង្គហេតុ ........................................ ១១
១.២.២.ព្រំដែនស៊ើបសួរចំពោះឯកត្តបុគ្គល ........................................ ១២
**កថាខណ្ឌទី២៖ ការស្រាវជ្រាវរបស់ចៅក្រមស៊ើបសួរ** ........................................ ១៣
២.១.វិធីសាស្ត្រស្វែងរកភស្តុតាងរបស់ចៅក្រមស៊ើបសួរ ........................................ ១៣
២.១.១.ការដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យ ........................................ ១៣
២.១.២.ការសួរចម្លើយជនត្រូវចោទ ........................................ ១៤
២.១.៣.ការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សី ........................................ ១៥
២.១.៤.ការឆែកឆេរ និងការចាប់យកភស្តុតាង ........................................ ១៦
២.១.៥.កោសល្យវិច័យ ........................................ ១៨
២.១.៦.ការស្តាប់ទូរស័ព្ទ ........................................ ១៩
២.២.សិទ្ធិអំណាចរបស់ចៅក្រមស៊ើបសួរក្នុងការចាត់ចែងអង្គហេតុ ........................................ ២១
២.២.១.ការបំពេញកិច្ចស៊ើបសួរដោយផ្ទាល់របស់ចៅក្រមស៊ើបសួរ ........................................ ២១

២.២.២.ដីកាចាត់ឲ្យស៊ើបសួរជំនួស........................................................................................២២
ក.ជនដែលអាចទទួលការចាត់ឲ្យស៊ើបសួរជំនួស ........................................................................២៣
ខ.ការផ្ទេរអំណាចស៊ើបសួរទៅឲ្យចៅក្រមតុលាការជាមួយគ្នា ឬ តុលាការផ្សេងទៀត..........................២៣
គ.ការផ្ទេរអំណាចស៊ើបសួរទៅឲ្យចៅក្រម ....................................................................................២៤
ឃ.កម្មវត្ថុនៃការចាត់ឲ្យស៊ើបសួរ..................................................................................................២៤
ង.កម្មវត្ថុនៃការចាត់ឲ្យស៊ើបសួរ ជំនួសដោយចៅក្រមតុលាការតែមួយ ឬតុលាការផ្សេង ......................២៤
ច.កម្មវត្ថុនៃការចាត់ឲ្យស៊ើបសួរជំនួសដោយមន្ត្រីនគរបាលយុត្តិធម៌...................................................២៤
២.២.៣.សិទ្ធិអំណាចបង្ខំរបស់ចៅក្រមស៊ើបសួរ ឬ វិធានការនិរន្តរាយ..................................................២៥
២.២.៣.១.ការបង្ខំឲ្យចូលខ្លួនក្នុងដំណើរការកិច្ចនីតិវិធី ........................................................................២៥
ក.ដីកាបង្គាប់ឲ្យចូលខ្លួន.............................................................................................................២៥
ខ.ដីកាបង្គាប់ឲ្យនាំខ្លួន ..............................................................................................................២៦
គ.ដីកាបង្គាប់ឲ្យចាប់ខ្លួន............................................................................................................២៧
២.២.៣.២.សិទ្ធិអំណាចត្រួតពិនិត្យថែរក្សាជនត្រូវចោទ ...........................................................................២៩
ក.ការឃុំខ្លួនបណ្តោះអាសន្ន ........................................................................................................២៩
ខ.ការត្រួតពិនិត្យតាមផ្លូវតុលាការ ................................................................................................៣៣
**កថាខណ្ឌទី៣៖ ការបិទបញ្ចប់នីតិវិធីស៊ើបសួរ**..................................................................................៣៦
៣.១.លំហូរនីតិវិធីបិទបញ្ចប់ការស៊ើបសួរ.........................................................................................៣៦
៣.១.១ដីកាជូនព័ត៌មាននៃការបញ្ចប់ការស៊ើបសួរ..................................................................................៣៦
៣.១.២ដីកាសន្និដ្ឋានស្ថាពរ .................................................................................................................៣៧
៣.២.ដីកាដំណោះស្រាយ ...................................................................................................................៣៨
៣.២.១.ដីកាលើកលែងការចោទប្រកាន់....................................................................................................៣៨
៣.២.២.ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះ ...................................................................................៣៩

## ជំពូកទី ២
## សភាស៊ើបសួរនៃសាលាឧទ្ធរណ៍

.................................................................................................................................................៤០
**ផ្នែកទី១៖ សញ្ញាណនៃសភាស៊ើបសួរ**...............................................................................................៤០
**កថាខណ្ឌទី១៖ តួនាទីនៃសភាពិសេសនៃសាលាឧទ្ធរណ៍**.....................................................................៤០
១.១.ភារកិច្ចរដ្ឋបាលនៃសភាស៊ើបសួរ .............................................................................................៤០
១.២.ការត្រួតពិនិត្យនិយ័តភាពនៃកិច្ចស៊ើបសួររបស់មន្ទីរស៊ើបសួរ.........................................................៤២
**កថាខណ្ឌទី២៖ អំណាចរបស់សភាស៊ើបសួរ**......................................................................................៤៥
២.១.អំណាចយុត្តាធិការនៃសភាស៊ើបសួរ...........................................................................................៤៥
២.២.អំណាចផ្ទាល់របស់ប្រធានសភាស៊ើបសួរ និបន្ទាប់បន្សំ ..................................................................៤៦
២.២.១អំណាចផ្ទាល់របស់ប្រធានសភាស៊ើបសួរ.......................................................................................៤៦
២.២.២.អំណាចបន្ទាប់បន្សំរបស់ប្រធានសភាស៊ើបសួរ ...............................................................................៤៧

**ផ្នែកទី២៖ ដំណើរការនីតិវិធីនៃបណ្ដឹងឧទ្ធរណ៍**....................................................................៤៨
**កថាខណ្ឌទី១៖ គុណវុឌ្ឍន៍នៃបណ្ដឹងឧទ្ធរណ៍**........................................................................៤៨
១.១.តំណាងអយ្យការ........................................................................................................៤៨
១.២.ភាគី.......................................................................................................................៤៨
១.២.១.ជនត្រូវចោទ...............................................................................................៤៨
១.២.២.ដើមបណ្ដឹងរដ្ឋប្បវេណី.................................................................................៥១
**កថាខណ្ឌទី២៖ យន្តការរបស់សភាស៊ើបសួរ**.........................................................................៥៣
២.១.ដំណើរការសវនាការរបស់សភាស៊ើបសួរ.....................................................................៥៣
២.២.អានុភាពនៃមោឃដោយសភាស៊ើបសួរ.........................................................................៥៥
**សេចក្ដីសន្និដ្ឋាន**..........................................................................................................៥៧
**អនុសាសន៍**...................................................................................................................៥៨
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

ប្រទេសកម្ពុជា ជាប្រទេសមួយដែលកំពុងមានការអភិវឌ្ឍន៍ ព្រមទាំងកំណើនសេដ្ឋកិច្ចមានការកើនឡើងគួរឲ្យកត់សំគាល់។ ប៉ុន្តែក៏ជាកត្តាមួយដែលបានធ្វើឲ្យមានការប្រកួតប្រជែង ដើម្បីដណ្តើមផលប្រយោជន៍គ្នា ក្នុងគោលដៅបំពេញនូវសេចក្តីត្រូវការគតព្រំដែនរបស់ខ្លួន ដោយបានបង្កឲ្យមាននូវអំពើអសកម្មនានាដែលនាំឲ្យមានផលវិបាកនៅក្នុងសង្គមជាតិ។ វិធិសាស្ត្រដើម្បីទប់ស្កាត់នូវសកម្មភាពទាំងនោះ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាបានខិតខំប្រឹងប្រែងក្នុងការតាក់តែងលិខិតបទដ្ឋានគតិយុត្តនានាដើម្បីផ្តន្ទាទោសលើបុគ្គលទាំងនោះ។ តួយ៉ាងដូចជាក្រមព្រហ្មទណ្ឌ ដែលកំណត់អំពីការដាក់ទណ្ឌកម្មដល់ជន ដែលបានប្រព្រឹត្តបទល្មើស ចំណែកឯក្រមនីតិវិធីព្រហ្មបានចែង នូវសំណុំវិធានទាក់ទងទៅនឹងការគ្រប់គ្រង ការរៀបចំនិងការប្រព្រឹត្តទៅ និងការវិនិច្ឆ័យលើរឿងក្តីព្រហ្មទណ្ឌ។ ក្រមនីតិវិធីព្រហ្មទណ្ឌបានចងក្រងឡើងក្នុងគោលដៅសំខាន់ទាក់ទងទៅនឹង ដំណាក់កាល នៃការវិនិច្ឆ័យបទល្មើសជាច្រើនរួមមាន ដំណាក់កាលរបស់មន្ត្រីនគរបាលយុត្តិធម៌ក្នុងការកសាងសំណុំរឿងហើយបន្តទៅដល់ ដំណាក់កាលរបស់អយ្យការអមសាលាដំបូងរាជធានីខេត្ត ដើម្បីចោទប្រកាន់រួចបញ្ជូនបន្តរហូតដល់ ដំណាក់កាលចៅក្រមស៊ើបសួរ និងដំណាក់កាលចុងក្រោយគឺ ដំណាក់កាលជំនុំជម្រះក្នុងរឿងក្តីព្រហ្មទណ្ឌ។

ទោះបីជានៅក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌ មានដំណាក់កាលជាច្រើនក៏ដោយ ដំណាក់កាលស៊ើបសួររបស់យុត្តិធិការស៊ើបសួរ ជានីតិវិធីស្វែងរកការពិតមួយដែលមានសារៈសំខាន់ដោយហេតុថា ដំណាក់កាលនេះបង្ហាញពីស្មារតីនៃគោលការណ៍ បែងចែកអំណាចក្នុងស្ថាប័នតុលាការក្នុងការស្វែងរក និងធានាយុត្តិធម៌ ជូនប្រជាពលរដ្ឋស្របតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងបទបញ្ញត្តិច្បាប់នានា។ ក្រមនីតិវិធីព្រហ្មទណ្ឌ បានសរបញ្ជាក់ពីការ កំណត់សិទ្ធិអំណាចពិសេសរបស់យុត្តាធិការស៊ើបសួររួមមាន សិទ្ធិក្នុងការស្រាវជ្រាវបទល្មើស និងបញ្ជាក់នូវការពិតក្នុងរឿងហេតុដែលទាក់ទងនឹងអង្គហេតុ ដែលតំណាងអយ្យការបានរៀបចំសំណុំរឿងដាក់ប្តឹងមកចៅក្រមស៊ើបសួរ និងមានវិធានការមួយចំនួនដែលក្រមនីតិវិធីព្រហ្មទណ្ឌបានកំណត់ផងដែរ។ មិនតែប៉ុណ្ណោះ ចៅក្រមស៊ើបសួរក៏ត្រូវបានកំណត់ឲ្យមាននូវសមត្ថកិច្ចពីរគឺ សមត្ថកិច្ចដែនដី និងសមត្ថកិច្ចតាមរឿងក្តី ជាពិសេសនោះក៏មាននូវអំណាចក្នុងការស្រាវជ្រាវចាប់យកវត្ថុតាង ការសួរចម្លើយ ការស្តាប់ចម្លើយនូវបុគ្គលដែលពាក់ព័ន្ធ ការដាក់ជនត្រូវចោទឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យ និងអំណាចពិសេសមួយទៀតនោះ គឺការប្រើប្រាស់នូវយន្តការនៃវិធានការនិន្នាយ ដីកាបង្គាប់ឲ្យចូលខ្លួន ដីកាបង្គាប់ឲ្យនាំខ្លួន ដីកាបង្គាប់ឲ្យចាប់ខ្លួន និងដីកាបង្គាប់ឲ្យឃុំខ្លួន បណ្តោះអាសន្ន ព្រមទាំងការលើកលែងការចោទប្រកាន់ទៅលើជនត្រូវចោទទៀតផង។ ទោះបីជាចៅក្រមស៊ើបសួរទទួលបានសិទ្ធិអំណាចដូចនេះក៏ដោយ ប៉ុន្តែចៅក្រមស៊ើបសួរអាចបើកការស៊ើបសួរទៅបានលុះត្រាណាតែទទួលបាននូវដីកា សន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរពីព្រះរាជអាជ្ញា ដែលជាដំណាក់កាលដំបូងនៃការចាប់ផ្តើមកិច្ចស៊ើបសួរប្រើប្រាស់ដើម្បី ស្វែងរកការពិតស្របតាមបញ្ញត្តិច្បាប់។ ម្យ៉ាងវិញទៀតក្រមរដ្ឋប្បវេណីព្រហ្មទណ្ឌ មិនបានកំណត់ចំពោះចៅក្រមស៊ើបសួរអំពីថិរវេលា នៅក្នុងការស្រាវជ្រាវបទល្មើសនោះទេ ឬអាចនិយាយបានថារយៈពេលនៃ ការបិទបញ្ចប់ការស្រាវជ្រាវនៅពេលណាឡើយដោយច្បាប់ទុកសិទ្ធិឲ្យចៅក្រមស៊ើបសួរធ្វើបុរេវិនិច្ឆ័យក្នុងការស្រាវជ្រាវបទល្មើស មានគោលដៅដើម្បីឲ្យចៅក្រមស៊ើបសួរ មានពេលវេលាគ្រប់គ្រាន់ក្នុងការស្វែងរកភស្តុតាងដាក់បន្ទុក និងភស្តុតាងដោះបន្ទុក។ នៅក្នុងនោះផងដែរ ការស៊ើបសួរមិនមែនមានតែនៅក្នុងដំណាក់កាលសាលាដំបូងនោះទេ ចំពោះនៅក្នុងដំណាក់កាលសាលាឧទ្ធរណ៍ក៏មានដែរ ដែលហៅថា សភាស៊ើបសួរ។

ការបង្កើតឡើងនូវសភាស៊ើបសួរ ដែលជាដំណាក់កាលទីពីរនៃការស៊ើបសួរ ដែលមានបន្ទាប់ពីមន្ទីរស៊ើបសួរនៃសាលាដំបូងរាជធានីខេត្ត គឺដើម្បីធានាឲ្យនីតិវិធីនៃការស៊ើបសួរអនុវត្តប្រកបទៅ ដោយសុក្រឹត្យភាព យុត្តិធម៌ឲ្យទៅជនត្រូវចោទនិងដើម្បីត្រួតពិនិត្យលើនិយ័តភាពនៃនីតិវិធីរបស់ចៅក្រមស៊ើបសួរនៅសាលាដំបូង។ ជាក់ស្តែង សភាស៊ើបសួរ

ក៏មាននូវអំណាចក្នុងការធ្វើការស៊ើបសួរ និងស្រាវជ្រាវរកភស្តុតាងទាំងឡាយណាដែលអាចសម្តែងចេញនូវភាពពិតផងដែរ។ នៅក្នុងនោះផងដែរ សភាស៊ើបសួរមានអំណាចក្នុងការប្តឹងសុំបត្យាប័ននូវបុគ្គលទាំងឡាយណា ដែលបានប្រព្រឹត្តបទល្មើសនៅក្រៅព្រះរាជាណាចក្រកម្ពុជា។ ទោះបីជានីតិវិធីទាំងអស់បានបញ្ញត្តិ នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧យ៉ាងណាក៏ ដោយចំពោះចំណាត់ការទាំងឡាយរបស់ចៅក្រមស៊ើបសួរ និងសភាស៊ើបសួរ នៅក្នុងរឿងក្តីព្រហ្មទណ្ឌនីមួយៗ សង្កេតឃើញថាសាធារណៈជនទូទៅ និងនីតិសាស្ត្រជនខ្មែរមួយចំនួននៅមិនទាន់យល់ អំពីនីតិវិធីនេះឲ្យបានច្បាស់លាស់នោះឡើយទេ។ ដូចនេះ ទើបមានមតិមួយចំនួនតែងតែលើកឡើងនូវចម្ងល់មួយចំនួនថា ហេតុអ្វីបានជាចាប់ជនសង្ស័យហើយបែរជាមានការដោះលែងឲ្យមានសេរីភាព ឬមួយក៏មិនត្រូវបានតុលាការជម្រះក្តីភ្លាមៗទៅវិញ? ហេតុអ្វីមានការឃុំខ្លួនបណ្តោះអាសន្ន? ហេតុអ្វីបានជាតុលាការដោះលែងជនត្រូវចោទនោះឲ្យនៅក្រៅទៅវិញ? ហេតុដូចម្តេចទើបតុលាការប្រកាសលើកលែងការចោទប្រកាន់?

ដូច្នេះ ដើម្បីជ្រាបច្បាស់នៃសំនួនបញ្ហាទាំងឡាយខាងលើដែលជាការប្រឈម ប្រធានបទនេះនឹងជួយធ្វើការដោះស្រាយនូវចម្ងល់ទាំងឡាយដែលកើតមានឡើងរួមទាំងការបកស្រាយបំភ្លឺឲ្យកាន់តែច្បាស់លាស់ទៀតផងមិនតែប៉ុណ្ណោះក៏មានការបកស្រាយស៊ីជម្រៅពាក់ព័ន្ធទៅនឹងនីតិវិធីនៃការស៊ើបសួរក្នុងរឿងក្តីព្រហ្មទណ្ឌរបស់ចៅក្រមស៊ើបសួរ និងសភាស៊ើបសួរដោយមានការបែងចែកជារចនាបទដូចខាងក្រោម៖

- **ជំពូកទី១. មន្ទីរស៊ើបសួរនៃសាលាដំបូង**
- **ជំពូកទី២. សភាស៊ើបសួរនៃសាលា**

# ជំពូកទី១
# មន្ទីរស៊ើបសួរនៃសាលាដំបូង

# ជំពូកទី១

# មន្ទីរស៊ើបសួរនៃសាលាដំបូង

## ផ្នែកទី១៖ សញ្ញាណទូទៅនៃចៅក្រមស៊ើបសួរនៃមន្ទីរស៊ើបសួរ

### កថាខណ្ឌទី១៖ ការទទួលបានគុណសម្បត្តិជាចៅក្រមស៊ើបសួរ

#### ១.១.លក្ខន្តិកៈនៃចៅក្រមស៊ើបសួរ

ស្ថាប័នតុលាការ ជាអំណាចឯករាជ្យ។ តុលាការ ធានារក្សាអនាគតិ និងការពារសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ។ ចៅក្រមនៃតុលាការគ្រប់ជាន់ថ្នាក់ ត្រូវបំពេញភារកិច្ចនេះដោយគោរពយ៉ាងម៉ឺងម៉ាត់ ឲ្យអស់ពីដួងចិត្ត និងសម្បជញ្ញៈរបស់ខ្លួន។ ចៅក្រមស៊ើបសួរ មិនខុសពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា និងការរៀបចំអង្គការតុលាការឡើយ។ មន្ទីរស៊ើបសួរនៃសាលាដំបូងគឺ ជាផ្នែកមួយណៃតុលាការព្រហ្មទណ្ឌដែល អនុលោមតាមបទប្បញ្ញត្តិស្ដីពីនីតិវិធីព្រហ្មទណ្ឌ។ ប្រធានសាលាដំបូងត្រូវចាត់តាំងចៅក្រមយ៉ាងតិច **០២** (**ពីរ**) រូបតាមដីកាសម្រេចឲ្យ បំពេញតួនាទីជាចៅក្រមស៊ើបសួរនៃតុលាការព្រហ្មទណ្ឌនៃសាលាដំបូង[1]។ ដីកានេះផងដែរ ត្រូវបានកំណត់អំពីលំដាប់លេខរៀងសម្រាប់ការបំពេញការងារ។ ករណីពុំមានចៅក្រមស៊ើបសួរប្រធានសាលាដំបូងអាចចាត់តាំងចៅក្រម នៃតុលាការជំនាញផ្សេងដើម្បីបំពេញមុខងារស៊ើបសួរបាន។

#### ១.២.ការដកហូត និងវិសមិតភាព

កាលណាចៅក្រមស៊ើបសួរពុំអាចបំពេញមុខងាររបស់ខ្លួនបានទេ ដោយសារការឈប់សម្រាក ដោយមានជម្ងឺ ឬដោយមានមូលហេតុផ្សេងៗ ទៀតចៅក្រមស៊ើបសួរផ្សេងទៀតនៃតុលាការដដែល ត្រូវបានចាត់តាំងជាបណ្ដោះអាសន្នដោយប្រធានតុលាការដើម្បីបំពេញមុខងារស៊ើបសួរ។ ក្នុងករណីកាលណា ពុំមានចៅក្រមផ្សេងទៀតនៃតុលាការដដែលអាចត្រូវបានចាត់តាំង ជាបណ្ដោះអាសន្នដោយប្រធានតុលាការ ដើម្បីបំពេញមុខងារស៊ើបសួរ។ ប្រធានតុលាការចេញដីកាចាត់តាំងមួយ ដែលពុំបើកផ្លូវតវ៉ាឡើយ។ សំណុំរឿងព្រហ្មទណ្ឌទាំងអស់ត្រូវបានបែងចែក ដោយប្រធានតុលាការកាលណា មានចៅក្រមស៊ើបសួរច្រើនរូបនៅក្នុងតុលាការមួយ។

ការដកហូតសំណុំរឿងពីចៅក្រមស៊ើបសួរដើម្បីប្រគល់ជូនចៅក្រមស៊ើបសួរម្នាក់ទៀត អាចស្នើទៅប្រធាន ដើម្បីជាប្រយោជន៍នៃរដ្ឋបាលដ៏ល្អនៃយុត្តិធម និងវាសចាកពីភាពលម្អៀង។ ការស្នើសុំនេះ អាចធ្វើឡើងដោយមានសំអាងហេតុរបស់ព្រះរាជអាជ្ញាដែលធ្វើឡើងដោយការផ្ដើមគំនិតផ្ទាល់ខ្លួន ឬតាមរយៈពាក្យប្ដឹងរបស់ភាគី។

ការដកសំណុំរឿងពីចៅក្រមស៊ើបសួរ ដោយយោងតាមមូលហេតុនៃការប្ដឹងជិតចិត្តចៅក្រមអាសនៈ[2]។

បណ្ដឹងជិតចិត្ត អាចទទួលបានតែចៅក្រមអាសនៈតែប៉ុណ្ណោះដូចមូលហេតុខាងក្រោម៖

- កាលណាចៅក្រម ឬសហព័ទ្ធរបស់ចៅក្រម ឬអតីតសហព័ទ្ធរបស់ចៅក្រមជាភាគីណាមួយក្នុងរឿងក្ដី។
- កាលណាជាញាតិលោហិតដល់ថ្នាក់ទី៦ ឬ ញាតិពន្ធហូតដល់ថ្នាក់ទី៣ ឬ អតីតញាតិពន្ធហូតដល់ថ្នាក់ទី៣របស់ភាគីណាមួយ
- កាលណាចៅក្រមជាអ្នកអាណាព្យាបាលរបស់ភាគីណាមួយ
- កាលណាចៅក្រមដែលទទួលបន្ទុករឿងក្ដី ធ្លាប់ ឬ កំពុងមានវិវាទនៅតុលាការជាមួយភាគីណាមួយ
- កាលណាចៅក្រមបានធ្វើសាក្សី ឬ អ្នកជំនាញក្នុងរឿងក្ដី

[1] ច្បាប់ស្ដីពីការរៀបចំអង្គហេតុតុលាការឆ្នាំ២០១៤,មាត្រា២០

[2] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧,មាត្រា២៧

- ០
- ០ កាលណាចៅក្រមជា ឬ ធ្លាប់ជាអ្នកតំណាង ឬ ជាអ្នកជំនួយឲ្យភាគីចំពោះរឿងក្ដី ឬ កាលណាចៅក្រមបានចូលរួមក្នុងការសម្រេចសេចក្ដីក្នុងនាមជាមជ្ឍត្តករចំពោះរឿងក្ដី ឬ បានចូលរួមក្នុងការសម្រេចសេចក្ដីនៅសាលាដំបូងដែលបានប្ដឹងឧបស្រ័យ ឬ ការជំនុំជម្រះនៃបណ្ដឹងឧទ្ធរណ៍ដែលបានឧបស្រ័យ ឬបញ្ចេញមតិយោបល់ណែនាំផ្នែកច្បាប់ចំពោះរឿងក្ដី។

ចៅក្រមស៊ើបសួរមិនអាចចូលរួមជំនុំជម្រះរឿងព្រហ្មទណ្ឌដែលខ្លួនបានចាត់ការក្នុងឋានៈជាចៅក្រមស៊ើបសួរបានទេ។

### កថាខណ្ឌទី២៖ សមត្ថកិច្ចរបស់ចៅក្រមស៊ើបសួរ

#### ២.១.សមត្ថកិច្ចដែនដី

ចៅក្រមស៊ើបសួរស្ថិតនៅជាមួយសាលាដំបូង ដូច្នេះសមត្ថកិច្ចក្នុងដែនដីរបស់តុលាការនេះចំពោះគ្រប់បទល្មើសដែលបានប្រព្រឹត្តនៅក្នុងដែនសមត្ថកិច្ច និងចំពោះបទល្មើសដែលដូចទៅ នឹងសមត្ថកិច្ចដែនដីរបស់សាលាដំបូងដែរ។

ចៅក្រមស៊ើបសួរ[3]មានសមត្ថកិច្ចនាទីកន្លែងបទល្មើស៖

- ចៅក្រមស៊ើបសួរទីកន្លែងបទល្មើស
- ចៅក្រមស៊ើបសួរនាទីលំនៅឋានឬទីសំណាក់របស់បុគ្គលដែលសង្ស័យថាបានប្រព្រឹត្តបទល្មើសចៅក្រមស៊ើបសួរទីកន្លែងចាប់ខ្លួនបុគ្គលដែលសង្ស័យថា បានប្រព្រឹត្តបទល្មើស។

ក្នុងករណីដែលមានទំនាស់រវាងចៅក្រមស៊ើបសួរច្រើនរូប នៅសាលាដំបូងខុសៗគ្នា ហើយទទួលបណ្ដឹងទាំងអស់ដូចគ្នាអំពីរឿងព្រហ្មទណ្ឌតែមួយ ទំនាស់នេះត្រូវបញ្ជូនទៅប្រធានសភាស៊ើបសួរដើម្បីសម្រេច។

ចំពោះវិវាទសមត្ថកិច្ចដែនដី រវាងសភាស៊ើបសួរច្រើនការសម្រេចពីសមត្ថកិច្ចរបស់សភាស៊ើបសួរ ត្រូវបញ្ជូនទៅប្រធានតុលាការដើម្បីសម្រេច។ការសម្រេចរបស់ប្រធានតុលាការកំពូលជាសាលដីកាសម្រេចបិទផ្លូវតវ៉ា។

#### ២.២.សមត្ថកិច្ចតាមរឿងក្ដី

ក្រមនីតិវិធីព្រហ្មទណ្ឌ បានកំណត់សមត្ថកិច្ចរបស់ស្ថាប័នអយ្យការ និងតុលាការ តាមដំណាក់កាលនីមួយៗ ឈរលើស្មារតីនៃ គោលការណ៍បែងចែកមុខងាររបស់ស្ថាប័នអយ្យការ និងតុលាការ ដែលជាផលវិបាកចេញគោលការណ៍បែងចែកអំណាច។ ស្ថាប័នតុលាការ ពុំអាចប្ដឹងមកដោយខ្លួនឯងផ្ទាល់ដើម្បីស៊ើបសួរ ឬវិនិច្ឆ័យបទល្មើសព្រហ្មទណ្ឌឡើយទោះបីជាតុលាការនោះបានដឹងដោយខ្លួនឯងផ្ទាល់នូវបទល្មើសនោះក៏ដោយ។ ដូច្នេះ ចៅក្រមស៊ើបសួរ អាចស៊ើបសួរដោយតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ទៅចៅក្រមស៊ើបសួរមិនមានលក្ខណៈចាំបាច់ចំពោះការវិនិច្ឆ័យបទល្មើសនោះទេ។ហេតុដូច្នេះ ការស៊ើបសួររបស់ចៅក្រមស៊ើបសួរចំពោះបទល្មើសទាំង៣ (បី) ប្រភេទ អាស្រ័យលើការប្ដឹងពីព្រះរាជអាជ្ញា តាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ អន្តរាគមន៍របស់គាត់ត្រូវធ្វើដោយខានពុំបានចំពោះបទឧក្រិដ្ឋ[4]។ ចៅក្រមស៊ើបសួរមានសមត្ថកិច្ច ទៅលើគ្រប់បុគ្គលទាំងអស់ លើកលែងតែរឿងក្ដីព្រហ្មទណ្ឌជាសមត្ថកិច្ចរបស់តុលាការពិសេស។

## ផ្នែកទី២៖ ដំណើរការស៊ើបសួរតាមកាលប្បវត្តិរបស់ចៅក្រមស៊ើបសួរ

### កថាខណ្ឌទី១៖ ការបើកការស៊ើបសួរ

[3] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧,មាត្រា១២៣

[4] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧,មាត្រា១២២

## ១.១.លក្ខណៈទម្រង់នៃបណ្តឹង និង អានុភាពនៃបណ្តឹង

### ១.១.១.ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់ព្រះរាជអាជ្ញា

ការស៊ើបសួរ ត្រូវបានបើកដោយដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់ព្រះរាជអាជ្ញា។ ក្នុងករណីបទឧក្រិដ្ឋ ព្រះរាជអាជ្ញាត្រូវបើការស៊ើបសួរ[5]។ ការបើកការស៊ើបសួរ ត្រូវបានបើកតាមដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ដែលត្រូវប្តឹងទៅចៅក្រមស៊ើបសួរ។ ការស៊ើបសួរអាចបើប្រឆាំងនឹងបុគ្គលម្នាក់ ឬច្រើននាក់ ដោយមានចង្អុលប្រាប់ឈ្មោះ ឬ ប្រឆាំងនឹងអញ្ញាតជន។ ដីកាបញ្ជូនរឿងឲ្យស៊ើបសួររួមមាន៖

- សេចក្តីសង្ខេបនៃអង្គហេតុ
- ការកំណត់ឈ្មោះបទល្មើស
- ការបង្ហាញអត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើស និង
- ឈ្មោះបុគ្គលដែលត្រូវរងការស៊ើបសួរ ប្រសិនបើអាចកំណត់បាន។

ដីកាបញ្ជូនរឿងឲ្យស៊ើបសួរ ត្រូវចុះកាលបរិច្ឆេទ និងចុះហត្ថលេខា។ ការបើកការស៊ើបសួរក្នុងករណីបទមជ្ឈឹមជាជម្រើសនៃការចោទប្រកាន់របស់ព្រះរាជអាជ្ញា។ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរត្រូវបញ្ជាក់ ឲ្យច្បាស់ពីអង្គហេតុដែលបញ្ជូនទៅចៅក្រមស៊ើបសួរ។ ក្នុងការអនុវត្តជាក់ស្តែងសេចក្តីសន្និដ្ឋាន ត្រូវមានភ្ជាប់ជាមួយលិខិតផ្សេងៗ ដែលកំណត់ពីអង្គហេតុ។ ករណីនេះ គ្រាន់តែអ្នកចុះហត្ថលេខា ដល់ទិដ្ឋការលើនិទ្ទេសទាំងនោះវាគ្រប់គ្រាន់ទៅហើយ ព្រោះវាមានតម្លៃស្មើនឹងវិភាគនៃលិខិតនេះ។លិខិតភ្ជាប់ត្រូវបានសន្មតថាមានបន្ទុកនូវគ្រប់ ការចង្អុលបង្ហាញដែលចាំបាច់នានាសម្រាប់បំភ្លឺចៅក្រមស៊ើបសួរ និងដើម្បីអនុញ្ញាតឲ្យចៅក្រមស៊ើបសួរកំណត់ ពីកម្មវត្ថុពិតប្រាកដព្រមទាំងវិសាលភាពនាំបណ្តឹងដោយផ្អែកទៅលើការចង្អុលបង្ហាញក្នុងលិខិតភ្ជាប់នោះ។ ជាទូទៅ លិខិតភ្ជាប់ គឺជាលិខិតដែលចេញក្នុងពេលស៊ើបសួរអង្កេត ជាក់ស្តែង ឬ ពេលស៊ើបសួរអង្កេតបឋម។ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ជានិច្ចកាលជាលិខិតលាយលក្ខណ៍អក្សរ ដែលត្រូវបានចុះកាលបរិច្ឆេទ និងហត្ថលេខា បើពុំនោះទេនឹងឲ្យមានមោឃភាពទាំងដីកា និងលិខិតផ្សេងៗទៀតដែលចេញក្រោយមកទៀត។

### ១.១.២.ការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីតាមផ្លូវអន្តរាគមន៍

ជនរងគ្រោះនៃ បទឧក្រិដ្ឋ ឬ បទមជ្ឈឹម អាចដាក់ពាក្យប្តឹងដោយតាំងខ្លួន ជាដើមបណ្តឹងរដ្ឋប្បវេណី នៅចំពោះមុខចៅក្រមស៊ើបសួរ។ ពាក្យប្តឹងដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី មានអានុភាពប្តឹងដល់ចៅក្រមស៊ើបសួរ។ចៅក្រមស៊ើបសួរធ្វើការកត់សម្គាល់នូវការដាក់ពាក្យប្តឹងដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីព្រះរាជអាជ្ញាត្រូវប្តឹងទៅចៅក្រមស៊ើបសួរតាមដីកាសន្និដ្ឋានរឿងឲ្យស៊ើបសួរ។ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរនេះ អាចធ្វើប្រឆាំងនឹងអញ្ញាតជន ទោះបីជាបណ្តឹងដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចោទទៅលើបុគ្គលម្នាក់ ឬ ច្រើននាក់ក៏ដោយ។ ព្រះរាជអាជ្ញាអាចសុំដល់ចៅក្រមស៊ើបសួរកុំឲ្យមានស៊ើបសួរ ប្រសិនបើបណ្តឹងអាជ្ញាត្រូវបានផុតរលត់ ឬ ប្រសិនបើអំពើនោះមិនមែនជាបទល្មើសព្រហ្មទណ្ឌទេ។ ក្នុងករណីដែលចៅក្រមស៊ើបសួរសម្រេចមិនស៊ើបសួរ ចៅក្រមរូបនេះត្រូវចេញដីកាសម្រេចដោយមានសំអាងហេតុ ដែលត្រូវជូនដំណឹងជា បន្ទាន់ដល់ដើមបណ្តឹងរដ្ឋប្បវេណី។ ក្នុងករណីដែលចៅក្រមស៊ើបសួរនៅតែសម្រេចស៊ើបសួរ ចៅក្រមរូបនេះត្រូវចេញដីកាសម្រេចដោយមានសំអាងហេតុ ហើយត្រូវជូនដំណឹងជាបន្ទាន់ដល់ព្រះរាជអាជ្ញា[6]។ ដោយផ្អែកទៅលើធនធាននៃដើមបណ្តឹងរដ្ឋប្បវេណី និងទៅលើការលំបាក

[5] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧,មាត្រា៤៤

[6] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧,មាត្រា១៣៩

នៃរឿងដែលអាចមើលឃើញជាមុនចៅក្រមស៊ើបសួរបានកំណត់តាមដីកាសម្រេចនូវចំនួនទឹកប្រាក់ដែលដើមបណ្ដឹងរដ្ឋប្បវេណីពុំមានលទ្ធភាពអាចបង់ ព្រមទាំងរយៈពេលដែលត្រូវបង់ប្រាក់នេះផង។ ប្រសិនបើដើមបណ្ដឹងរដ្ឋប្បវេណី ពុំមានលទ្ធភាពអាចបង់ប្រាក់តម្កល់ទុកបានទេចៅក្រមស៊ើបសួរ អាចលើកលែងមិនឲ្យបង់ប្រាក់នេះបាន។ ដីកានេះត្រូវជូនដំណឹងជាបន្ទាន់ដល់ដើមបណ្ដឹងរដ្ឋប្បវេណី។ ក្នុងករណីដែលមានការបង់ប្រាក់តម្កល់ទុក ដើមបណ្ដឹងរដ្ឋប្បវេណីទទួលបង្កាន់ដៃដែលមានចុះហត្ថលេខាដោយប្រធានតុលាការ ព្រះរាជអាជ្ញា និងក្រឡាបញ្ជី។ ប្រសិនបើប្រាក់តម្កល់ទុក មិនត្រូវបានបង់នៅក្នុងរយៈពេលដែលកំណត់បានដោយចៅក្រមស៊ើបសួរទេពាក្យប្ដឹងដោយមានការតាំងខ្លួនដើមបណ្ដឹងរដ្ឋប្បវេណីត្រូវប្រកាសថាមិនអាចទទួលបានដោយចៅក្រមស៊ើបសួរ។

ចៅក្រមស៊ើបសួរនេះសម្រេចតាមដីកាដែលត្រូវជូនដំណឹងជាបន្ទាន់ដល់ដើមបណ្ដឹងរដ្ឋប្បវេណី។ ប្រាក់តម្កល់ទុកត្រូវបង្វិលទៅសាមីខ្លួននៅពេលបញ្ចប់នីតិវិធី។ ប៉ុន្តែ ប្រសិនបើការស៊ើបសួរដែលបានបើកបន្ទាប់ពីមានពាក្យប្ដឹង ដោយមានការតាំងខ្លួនដើមបណ្ដឹងរដ្ឋប្បវេណីត្រូវបានបិទតាមដីកាលើកលែងការចោទប្រកាន់

ហើយប្រសិនបើចៅក្រមស៊ើបសួរយល់ឃើញថា នីតិវិធីធ្វើឡើងដោយរំលោភ ឬ ដោយប្រកាន់ ហើយប្រសិនបើចៅក្រមស៊ើបសួរយល់ឃើញថា នីតិវិធីធ្វើឡើងដោយរំលោភ ឬ ដោយអូសបន្លាយពេលវេលា នោះចៅក្រមស៊ើបសួរ អាច

សម្រេចតាមដីកាសម្រេចឲ្យ ដើមបណ្ដឹងបង់ប្រាក់ពិន័យរដ្ឋប្បវេណី។ ចំនួនប្រាក់ពិន័យមិនអាចលើសចំនួនទឹកប្រាក់តម្កល់ទុកឡើយ។ ដីកាសម្រេចឲ្យបង់ប្រាក់ពិន័យនេះ ត្រូវឲ្យដំណឹងដល់សាមីខ្លួនជាបន្ទាន់។ប្រាក់តម្កល់ទុក ត្រូវតម្កល់ទុកនៅក្នុងគណនីពិសេស ដែលបើកនៅក្នុងធនាគារ ឬ រក្សាទុកនៅក្នុងទីកន្លែងដែលមានការធានាសន្តិសុខយ៉ាងរឹងមាំ។ ទីកន្លែងនេះត្រូវបានជ្រើសរើសតាមការព្រមព្រៀង គ្នារបស់តុលាការ និងព្រះរាជអាជ្ញា[7]។នៅពេលដែលចៅក្រមស៊ើបសួរ ទទួលពាក្យបណ្ដឹងធម្មតាដោយពុំមានការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ចៅក្រមស៊ើបសួរត្រូវបញ្ជូនពាក្យបណ្ដឹងនេះទៅព្រះរាជអាជ្ញា។ ពាក្យបណ្ដឹងនេះ ត្រូវដោះស្រាយដូចជាបណ្ដឹងដទៃទៀត ដោយមានការពិនិត្យវាយតម្លៃដោយសេរី របស់ព្រះរាជអាជ្ញាទៅលើចំណាត់ការបន្ត(បញ្ជាឲ្យការបើកការស៊ើបអង្កេត ឬ ប្ដឹងទៅចៅក្រមស៊ើបសួរ ឬ តម្កល់រឿងទុកមិនចាត់ការ)។

គ្រប់ជនរងគ្រោះនៃបទល្មើសដែលបានប្ដឹងទៅចៅក្រមស៊ើបសួរ អាចតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីបានគ្រប់ពេលវេលានៃនីតិវិធី ការតាំងខ្លួននេះធ្វើឡើងដោយគ្មានទម្រង់អ្វីទេ។ វាអាចធ្វើឡើងដោយផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរ។

**១.១.៣.អានុភាពនៃបណ្ដឹង**

សេចក្ដីសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ មានអានុភាពដាក់បណ្ដឹងអាជ្ញាឲ្យ មានចលនាចំពោះអំពើដែលចែងក្នុងសេចក្ដីសន្និដ្ឋាននេះ។ ម្យ៉ាងទៀត សេចក្ដីសន្និដ្ឋានបង្អាក់អាជ្ញាយុកាលនៃបណ្ដឹងអាជ្ញា ទៅលើអំពើដែលប្ដឹងទៅចៅក្រមស៊ើបសួរ និងទៅលើបទល្មើសដែលមិនអាចបែងចែកបាន ឬ ដែលទាក់ទងគ្នា ប៉ុន្តែមិនបានចែងក្នុងសេចក្ដីសន្និដ្ឋាន។

ចៅក្រមស៊ើបសួរទទួលពាក្យបណ្ដឹង ដែលមិនអាចដកវិញបាន ពីអំពើដែលចែងក្នុងសេចក្ដីសន្និដ្ឋាន។ ហេតុដូច្នេះ ព្រះរាជអាជ្ញា បាត់បង់នូវសិទ្ធិសម្រេចចំពោះអំពើខាងលើនេះ។ គាត់ពុំអាចតម្កល់រឿងទុកមិនចាត់ការទៀតការទៀតបានទេ។ ម្យ៉ាងទៀត គាត់ក៏លែងមានសិទ្ធិបញ្ជានគរបាល ឬ កងរាជអាវុធហត្ថ ឲ្យធ្វើការស៊ើបអង្កេតទៅលើអំពើតែមួយនេះ

[7] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧,មាត្រា១៤០

ទៀតដែរ។ ទាញចេញពីគោលការណ៍នេះព្រះរាជអាជ្ញាមិន អាចព្យាយមធ្វើឲ្យប៉ះពាល់ដល់វិសាលភាពនៃបណ្តឹង ក្នុងពេលដែលកំពុងស៊ើបសួរទេ។

ដូច្នេះសេចក្តីសន្និដ្ឋានបន្ថែមដែលធ្វើឡើងក្នុងបំណងនេះមិនអាចត្រូវបានអនុវត្តទេទាក់ទងទៅនឹងបុគ្គល ទាំងព្រះរាជអាជ្ញា ទាំងជនរងគ្រោះដែលបានតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី លែងអាចចង្អុលបង្ហាញបុគ្គលណា មួយដោយផ្ទាល់នៅចំពោះមុខសាលាវិនិច្ឆ័យ ក្នុងកំឡុងពេលស៊ើបអង្កេត ឬ បន្ទាប់ពីពេលដែលចៅក្រមស៊ើបសួរបានចេញដីកាលើកលែងចោទប្រកាន់។

ចៅក្រមស៊ើបសួរ ដែលទទួលពាក្យបណ្តឹងដោយត្រឹមត្រូវ មានករណីយកិច្ចត្រូវស៊ើបសួរ។ ដូច្នេះ គាត់មិនអាចបដិសេធស៊ើបសួររឿងអ្វីមួយដោយ សំអាងថាការស៊ើបសួរ ពុំមានប្រយោជន៍ព្រោះរឿងនេះស៊ើបសួររួចហើយ។ គាត់ពុំអាចបដិសេធមិនស៊ើបសួរ ដោយយកលេសថា ការស៊ើបសួរពុំអាចទទួលលទ្ធផល ព្រោះអំពើនោះមិនមែន ជាបទល្មើសដែលចែង ក្នុងសេចក្តីសន្និដ្ឋានទោះបីវា ជាអំពីល្មើសក៏ដោយ។ ចៅក្រមស៊ើបសួរមានកាតព្វកិច្ចផ្ទៀងផ្ទាត់សមត្ថកិច្ចសម្ភារៈនិងសមត្ថកិច្ចដែនដី ជាអាទិ៍ គាត់មិនអាចប្រកាសថាខ្លួនពុំមានសមត្ថកិច្ចខាងដែនដីដរាបណា ចៅក្រមស៊ើបសួរមិនទាន់បានធ្វើការស្រាវជ្រាវចាំបាច់នានា ដើម្បីផ្ទៀងផ្ទាត់សមត្ថកិច្ចរបស់ខ្លួន ជាពិសេសប្រសិនបើចៅក្រមស៊ើបសួរទទួលបណ្តឹង ដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលសរសេរថាម្នាក់ក្នុងចំណោមជនសង្ស័យ និងដែលត្រូវបរិហាររស់នៅក្នុងដែនសមត្ថកិច្ចរបស់គាត់។

ប្រសិន ចៅក្រមស៊ើបសួរយល់ឃើញថា ខ្លួនពុំមានសមត្ថកិច្ច ចៅក្រមស៊ើបសួរចេញដីកាអសមត្ថកិច្ច ប៉ុន្តែបើចៅក្រមស៊ើបសួរទទួលពាក្យបណ្តឹងពីដើមបណ្តឹងរដ្ឋប្បវេណី ចៅក្រមស៊ើបសួរត្រូវតែសម្រេច ដោយយោងតាមសេចក្តីសន្និដ្ឋានរបស់អយ្យការ។ ក្នុងករណីផ្សេងទៀត សមត្ថកិច្ចតាមសាច់រឿង និងតាមដែនដីជាសមត្ថកិច្ចពិតមែន ក៏ប៉ុន្តែចៅក្រមស៊ើបសួរអាចបដិសេធមិនស៊ើបសួរបានជាអាទិ៍ ចៅក្រមស៊ើបសួរត្រូវបដិសេធមិនស៊ើបសួរ ដោយចេញដីកាដែលមានសំអាងហេតុក្នុងខណៈដែលការចោទប្រកាន់ហាក់មិនអាចធ្វើទៅបាន។

ឧទាហរណ៍ៈករណីដែលរឿងមួយមិនអនុញ្ញាតឲ្យមានការស៊ើបសួរ ប្រសិនបើអំពើមិនអាចចាត់ទុកជាបទល្មើសអាជ្ញាយុកាលនៃបណ្តឹងអាជ្ញាផុតរលត់ ឬរឿងរ៉ាវត្រូវបានវិនិច្ឆ័យរួចហើយ។ យោងទៅលើមូលហេតុទាក់ទងនឹងបណ្តឹងអាជ្ញាខ្លួនឯងផ្ទាល់ ព្រះរាជអាជ្ញាអាចប្តឹងទៅចៅក្រមស៊ើបសួរនូវសេចក្តីសន្និដ្ឋានមិនស៊ើបសួរ ប្រសិនបើមិនអនុញ្ញាតឲ្យមានការចោទប្រកាន់ស្របច្បាប់ណាមួយ ឬដោយសន្មតថាអំពើនេះត្រូវបង្ហាញ ប៉ុន្តែវាមិនមែនជាបទល្មើសព្រហ្មទណ្ឌ។ ក្នុងករណីដែលចៅក្រមស៊ើបសួរសម្រេចផ្សេងពីនេះគាត់ត្រូវចេញដីកាដែលមានសំអាងហេតុ។

## ១.២.វិសាលភាពនៃបណ្តឹង

### ១.២.១.ព្រំដែនស៊ើបសួរនៃបណ្តឹងចំពោះអង្គហេតុ

អង្គហេតុ គឺមានលក្ខណៈចាំបាច់ដែលត្រូវតែមាននៅក្នុងដីកា សន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរព្រោះការមិនពេញគ្រប់លក្ខខណ្ឌនៃទម្រង់ការ នឹងធ្វើឲ្យដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរនោះត្រូវទុកជាមោឃភាព។ ការកំណត់ឲ្យច្បាស់លាស់បីទីតាំង និងពេលវេលានៃការប្រព្រឹត្តបទល្មើសនៅ ក្នុងដីកាសន្និដ្ឋានរឿងឲ្យស៊ើបសួរ អាចកំណត់ពីព្រំដែននៃសិទ្ធិក្នុងការស៊ើបសួររបស់ចៅក្រមស៊ើបសួរទៅលើអង្គហេតុ ដើម្បីបញ្ចៀសការស៊ើបសួរហួសការកំណត់ដែលអាចនាំឲ្យមានការយឺតយ៉ាវក្នុងនីតិវិធី។ ចៅក្រមស៊ើបសួរ ទទួលបណ្តឹងអំពីអង្គហេតុដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់ព្រះរាជអាជ្ញា។ចៅក្រមស៊ើបសួរ ត្រូវកំណត់ឲ្យច្បាស់អំពីអង្គហេតុ ហើយដីកានោះនឹងចងចៅក្រមស៊ើប

សួរឲ្យធ្វើការស៊ើបសួរតែទៅលើអង្គហេតុនោះតែប៉ុណ្ណោះ[8]។ ទោះក្នុងករណី ចៅក្រមស៊ើបសួររកឃើញថាមានអង្គហេតុថ្មីក៏ដោយ ក៏ចៅក្រមស៊ើបសួរមិនអាចរំលោភសមត្ថកិច្ចរបស់ខ្លួន ដោយធ្វើការស៊ើបសួរទៅលើអង្គហេតុថ្មីនោះដោយខ្លួនឯងបានទេ។

ការអនុវត្តជាក់ស្តែង ចៅក្រមស៊ើបសួរអាចធ្វើការបែងចែកកិច្ចស៊ើបសួរទាក់ទងទៅនឹងអំពើឬអង្គហេតុនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរៈ

- អំពើដែលរៀបរាប់នៅក្នុងកំណត់ហេតុ ដែលភ្ជាប់ជាមួយដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់ព្រះរាជអាជ្ញា ពោលចៅក្រមស៊ើបសួរ ស៊ើបសួរតែទៅលើអំពើដែលមានកំណត់នៅក្នុងកំណត់ហេតុ ដោយ
- មិនត្រូវស៊ើបសួរអំពើផ្សេង ក្រៅពីអំពើដែលបានរៀបរាប់នៅក្នុងអង្គហេតុ និង ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់ព្រះរាជអាជ្ញា។
  - ការស៊ើបសួរ លើអំពើដែលព្រះរាជអាជ្ញាបានចង្អុលបង្ហាញយ៉ាងជាក់ច្បាស់តែប៉ុណ្ណោះ។
  - ចៅក្រមស៊ើបសួ រមិនចាំបាច់សុំដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមទេ ប្រសិនបើអង្គហេតុថ្មីនោះ ជាស្ថានទម្ងន់ទោសទៅលើអង្គហេតុ ដែលចែងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរដំបូង។

ចំពោះការស្នើសុំស៊ើបសួរបន្ថែម ចំពោះអង្គហេតុថ្មីទៅអយ្យការ ចៅក្រមស៊ើបសួរមិនអាចធ្វើការស៊ើបសួរដោយគ្មានការឯកភាពជាមុនពីព្រះរាជអាជ្ញា ក្នុងករណីដែលមានអង្គហេតុថ្មីដែលមិនមានដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ប៉ុន្តែចៅក្រមស៊ើបសួរ អាចស្នើសុំធ្វើការស៊ើបសួរបន្ថែម ដើម្បីឲ្យមានភាពកាន់តែច្បាស់លាស់។ យន្តការនេះ ដែលតម្រូវឲ្យព្រះរាជអាជ្ញាធ្វើការចោទប្រកាន់ថ្មីមួយ នៅក្នុងករណីលេចចេញនូវអង្គហេតុថ្មីដែលអាចជាបទល្មើសព្រហ្មទណ្ឌនៅក្នុងកិច្ចស៊ើបសួរ ចៅក្រមស៊ើបសួរត្រូវជូនព័ត៌មានអំពីអង្គហេតុថ្មីទៅព្រះរាជអាជ្ញា។ ប្រសិនបើ ព្រះរាជអាជ្ញាមិនបានចេញដីកាបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមទេ ចៅក្រមស៊ើបសួរគ្មានអំណាចស៊ើបសួរអំពីអង្គហេតុថ្មីនោះឡើយ។

**១.២.២.វិសាលភាពស៊ើបសួរចំពោះឯកត្តបុគ្គល**

កាស៊ើបសួរ ដែលមានកំណត់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់ព្រះរាជអាជ្ញា មានវិសាលភាពអាចប្រឆាំងទៅលើបុគ្គលម្នាក់ៗ ឬច្រើនដែលមានចង្អុលប្រាប់ឈ្មោះ ឬ ប្រឆាំងទៅលើអញ្ញាតជន[9]។ ព្រះរាជអាជ្ញាជាម្ចាស់នៃបណ្តឹងអាជ្ញា ជាអ្នកកំណត់បទចោទចំពោះអង្គហេតុដែលកំណត់ឲ្យចៅក្រមស៊ើបសួរកម្រិតចំពោះអង្គហេតុដែលស៊ើបសួរ។ ការចោទប្រកាន់នេះ មិនត្រូវអនុវត្តចំពោះការស៊ើបសួរទៅលើបុគ្គល និងដំណើរការស៊ើបសួររបស់ចៅក្រមស៊ើបសួរទេ។ ការស៊ើបសួរទៅលើបុគ្គលពាក់ព័ន្ធនឹងអង្គហេតុ ដែលត្រូវបានទទួលស្គាល់នៅក្នុងដំណាក់កាលស៊ើបសួរ ដែលខុសគ្នាពីដំណាក់កាលចោទប្រកាន់របស់ព្រះរាជអាជ្ញាចំពោះបុគ្គលដែលបានចោទប្រកាន់ច្បាស់ៗ ក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់ព្រះរាជអាជ្ញា ចៅក្រមស៊ើបសួរត្រូវមានកម្រិតសិទ្ធិនៃការស៊ើបសួរ ទៅលើបុគ្គលដែលបានកំណត់នោះ។

ប៉ុន្តែក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាបានបង្កើតនូវសិទ្ធិស្វែងរកមូលកភាពនៃបទល្មើសដោយមិនចងកាតព្វកិច្ចចៅក្រមស៊ើបសួរ ទៅលើគ្រប់បុគ្គលទាំងអស់ ក្រៅពីជនដែលត្រូវបានចង្អុលបង្ហាញដោយព្រះរាជអាជ្ញាក្នុងន័យនេះករណីចៅក្រមស៊ើបសួររកឃើញ ថាបុគ្គលផ្សេងទៀតពាក់ព័ន្ធនឹងអង្គហេតុដែលត្រូវ ស៊ើបសួរចៅក្រមស៊ើបសួ

[8] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧,មាត្រា១២៥

[9] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧,មាត្រា១២៤

មានសិទ្ធិពន្លាតការស៊ើបសួរទៅលើបុគ្គលនោះដោយមិនទាមទារឲ្យ មានការចោទប្រកាន់ថ្មី ឬដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមពីព្រះរាជអាជ្ញាឡើយ។

## កថាខណ្ឌទី២៖ ការស្រាវជ្រាវរបស់ចៅក្រមស៊ើបសួរ

### ២.១.វិធីសាស្ត្រស្វែងរកភស្តុតាងរបស់ចៅក្រមស៊ើបសួរ

#### ២.១.១.ការដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យ

នៅពេលចូលបង្ហាញខ្លួនលើកដំបូង ចៅក្រមស៊ើបសួរពិនិត្យអត្តសញ្ញាណជន ត្រូវចោទប្រាប់ជននេះឲ្យបានដឹងរឿងរ៉ាវដែលចោទប្រកាន់ និងប្រាប់អំពីឈ្មោះបទល្មើសដែលកំណត់ដោយច្បាប់។

ចៅក្រមស៊ើបសួរប្រាប់ជនត្រូវចោទថា ខ្លួនអាចឆ្លើយ ឬ មិនឆ្លើយបានដោយសេរី។ និទ្ទេសស្ដីពីការប្រាប់នេះ ត្រូវចុះនៅក្នុងកំណត់ហេតុនៅពេលចូលបង្ហាញខ្លួនលើកដំបូង[10]។ ប្រសិនបើជនត្រូវចោទចង់ឆ្លើយនោះ ចៅក្រមស៊ើបសួរត្រូវទទួលចម្លើយនោះភ្លាម។ ចៅក្រមស៊ើបសួរប្រាប់ជនត្រូវចោទ ឲ្យបានដឹងអំពីសិទ្ធិរបស់ខ្លួនក្នុងការជ្រើសរើសមេធាវី ឬក្នុងការសុំឲ្យចាត់តាំងមេធាវីឲ្យខ្លួន ដោយអនុវត្តតាមច្បាប់ស្ដីពីលក្ខន្តិកៈមេធាវី។ ក្រោយពីការចូលបង្ហាញខ្លួនលើកទីមួយជនត្រូវចោទដែលនៅក្រៅឃុំ ត្រូវប្រកាសប្រាប់ដល់ចៅក្រមស៊ើបសួរអំពីអាសយដ្ឋានរបស់ខ្លួន។ ជនត្រូវចោទនេះត្រូវបានទទួលដំណឹងថា៖

- ខ្លួនត្រូវតែជូនព័ត៌មានដល់ចៅក្រមស៊ើបសួរនៅពេលណាដែលខ្លួនផ្លាស់ប្តូរអាសយដ្ឋាន
- គ្រប់ការឲ្យដំណឹងដែលបានធ្វើឡើងតាមអាសយដ្ឋានចុងក្រោយដែលប្រកាសឡើងដោយជនត្រូវចោទនោះ ត្រូវចាត់ទុកថាបានធ្វើឡើងដល់សាមីខ្លួនផ្ទាល់។

ការឲ្យដំណឹង ព្រមទាំងការប្រកាសស្ដីអំពីការផ្លាស់ប្ដូរអាសយដ្ឋាននោះ ត្រូវចុះនៅក្នុងកំណត់ហេតុ នៅពេលចូលបង្ហាញខ្លួនលើកដំបូង។

ក្នុងករណីចាំបាច់ចៅក្រមស៊ើបសួរត្រូវហៅរកអ្នកបកប្រែ។ អ្នកបងប្រែត្រូវស្បថស្របតាមសាសនា ឬ ជំនឿរបស់ខ្លួនថានឹងអាចជួយដល់តុលាការ និងបកប្រែឲ្យបានត្រឹមត្រូវតាមចម្លើយទាំងឡាយ។ ក្នុងករណីណាក៏ដោយ អ្នកបកប្រែមិនអាចត្រូវជ្រើសរើសក្នុងចំណោមចៅក្រម ក្រឡាបញ្ជីនគបាល កងរាជអាវុធហត្ថ ភាគី ឬ សាក្សីទេ។

#### ២.១.២.ការសួរចម្លើយជនត្រូវចោទ

កាលណាជនត្រូវចោទមានមេធាវីអម ចៅក្រមស៊ើបសួរត្រូវកោះហៅមេធាវីយ៉ាងតិចបំផុត ៥ (ប្រាំ) ថ្ងៃ មុនការសួរចម្លើយ។ក្នុងចិរវេលានេះមេធាវីអាចពិនិត្យមើលសំណុំរឿងនៃនីតិវិធី[11]។ជនត្រូវចោទអាចត្រូវសួរចម្លើយបានតែនៅចំពោះមុខមេធាវីរបស់ខ្លួនតែប៉ុណ្ណោះ។ ប៉ុន្តែប្រសិនបើ មេធាវីដែលត្រូវបានកោះហៅ យ៉ាងត្រឹមត្រូវហើយមិនចូលបង្ហាញខ្លួននៅថ្ងៃនិងម៉ោងកំណត់ទេ ចៅក្រមស៊ើបសួរអាចសួរចម្លើយជនត្រូវចោទ ដោយគ្មានវត្តមានរបស់មេធាវី។និទ្ទេសស្ដីអំពីអវត្តមាននេះត្រូវចុះនៅក្នុងកំណត់ហេតុសួរចម្លើយជនត្រូវចោទ។ក្នុងករណីពិសេស ចៅក្រមស៊ើបសួរ អាចសួរចម្លើយជនត្រូវចោទដោយមិនបាច់កោះហៅមេធាវី ប្រសិនបើជនត្រូវចោទបោះបង់ចោលយ៉ាងជាក់លាក់ នូវអវត្តមានរបស់មេធាវីខ្លួន។ការបោះបង់ចោលនេះត្រូវចុះនៅក្នុងកំណត់ហេតុផ្សេងពីកំណត់ហេតុសួរចម្លើយ និងត្រូវហត្ថលេខាដោយជនត្រូវចោទ។ ក្នុងករណីបន្ទាន់ចៅក្រមស៊ើបសួរ ក៏អាចធ្វើការសួរចម្លើយដោយមិនបាច់កោះហៅមេធាវីដែរ។ ភាពបន្ទាន់នេះត្រូវតែបណ្ដាលមកពី គ្រោះថ្នាក់ដល់ស្លាប់ឬ បណ្ដាលមកពីការភ័យខ្លាចបាត់បង់តម្រុយនៃភស្តុតាង។ ប្រភេទនៃភាពបន្ទាន់ ត្រូវតែចុះ

[10] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧,មាត្រា១៤៣

[11] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧,មាត្រា១៤៥

និទ្ទេសនៅក្នុងកំណត់ហេតុ។ ចៅក្រមស៊ើបសួរអាចហៅកអ្នកបកប្រែបាន។នៅពេលសួរចម្លើយជនត្រូវចោទ ព្រះរាជអាជ្ញា និងមេធាវីក៏អាចលើកសំណួរបានដែរ ដោយមានការអនុញ្ញាតពីចៅក្រមស៊ើបសួរ។ ក្នុងករណីនេះត្រូវចុះនិទ្ទេសនៅក្នុងកំណត់ហេតុ។

កាលណាថេរវេលា៤(បួន)ខែបានកន្លងផុតទៅចាប់ពីពេលសួរចម្លើយ នៅពេលបង្ហាញខ្លួនលើកដំបូងជនត្រូវចោទមិនត្រូវបានសួរចម្លើយ ឬសួរតទល់ទេចៅក្រមស៊ើបសួរត្រូវតែទទួលចម្លើយ ប្រសិនបើជនត្រូវចោទបានស្នើសុំ។ បើចៅក្រមស៊ើបសួរមិនព្រមកោះហៅជនត្រូវចោទក្នុងថិរវេលា១(មួយ)ខែបន្ទាប់ពីការសុំទេ នោះជនត្រូវចោទអាចប្តឹងផ្ទាល់ទៅសភាស៊ើបសួរដែលទទួលចម្លើយនេះដោយខ្លួនឯង។ បន្ទាប់មកកំណត់ហេតុត្រូវបញ្ជូនទៅចៅក្រមស៊ើបសួរ [12] ។ មេធាវីរបស់ជនត្រូវចោទដែលជាប់ឃុំ អាចប្រាស្រ័យទាក់ទងដោយសេរីជាមួយកូនក្តីរបស់ខ្លួននៅក្នុងពន្ធនាគារ ឬ នៅក្នុងមណ្ឌលឃុំខ្លួន។ការសន្ទនារវាងមេធាវី និងជនត្រូវចោទមិនអាចត្រូវបានគេស្តាប់ ឬ ថតបានទេ។ មេធាវីអាចអានលិខិតនៃសំណុំរឿងឲ្យកូនក្តីខ្លួនស្តាប់។ ផ្ទុយទៅវិញមេធាវីមិនអាចឲ្យចម្លងលិខិតថតចម្លងពីលិខិតនៃសំណុំរឿងកូនក្តីរបស់ខ្លួនបានឡើយ[13]។

**២.១.៣.ការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សី**

ការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណីអាចត្រូវបានអមដោយមេធាវី។ក្នុងករណីចៅក្រមស៊ើបសួរត្រូវបានកោះហៅមេធាវីរបស់ដើមបណ្តឹងរដ្ឋប្បវេណីយ៉ាងតិចបំផុត ៥(ប្រាំ)ថ្ងៃមុនការស្តាប់ចម្លើយ។ នៅក្នុងថិរវេលានេះ មេធាវីអាចពិនិត្យសំណុំរឿងនៃនីតិវិធីបាន។ ដើមបណ្តឹងរដ្ឋប្បវេណី អាចត្រូវបានស្តាប់ចម្លើយតែនៅចំពោះមុខមេធាវី របស់ខ្លួនប៉ុណ្ណោះ។ ប៉ុន្តែប្រសិនបើមេធាវីដែលត្រូវបានកោះហៅយ៉ាងត្រឹមត្រូវ ហើយមិនចូលបង្ហាញខ្លួននៅថ្ងៃ និងម៉ោងតាមកំណត់ទេ ចៅក្រមស៊ើបសួរ អាចស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណីដោយគ្មានវត្តមានរបស់មេធាវី។ និទ្ទេសស្តីពីអវត្តមានត្រូវចុះនៅក្នុងកំណត់ហេតុស្តាប់ចម្លើយ។

ក្នុងករណីពិសេសចៅក្រមស៊ើបសួរអាចស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណីបាន ដោយមិនបាច់កោះហៅមេធាវី ប្រសិនបើដើម បណ្តឹងរដ្ឋប្បវេណីបោះបង់ចោលយ៉ាងជាក់លាក់ នូវអវត្តមានមេធាវីរបស់ខ្លួន។ ការបោះបង់ចោលនេះត្រូវចុះនិទ្ទេសនៅក្នុងកំណត់ហេតុមួយដោយឡែក ពីកំណត់ហេតុស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី និងត្រូវចុះហត្ថលេខាដោយដើមបណ្តឹងរដ្ឋប្បវេណី។

ក្នុងករណីបន្ទាន់ ចៅក្រមស៊ើបសួរក៏អាចស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ដោយមិនចាំបាច់កោះហៅមេធាវីបានដែរ។ ភាពបន្ទាន់នេះ ត្រូវបណ្តាលមកពីគ្រោះថ្នាក់ដល់ស្លាប់ ឬ បណ្តាលមកពីភ័យខ្លាចបាត់បង់តម្រុយភស្តុតាង។ ប្រភេទនៃ ភាពបន្ទាន់នេះត្រូវតែចុះនិទ្ទេសនៅក្នុងកំណត់ហេតុ[14]។ នៅក្នុងពេលស្តាប់ចម្លើយ ព្រះរាជអាជ្ញា និងមេធាវីអាចលើកសំណួរមកសួរបាន ដោយមានការអនុញ្ញាតពីចៅក្រមស៊ើបសួរ។ ក្នុងករណីមិនអនុញ្ញាត ករណីនេះត្រូវចុះនិទ្ទេសនៅក្នុងកំណត់ហេតុ។ការស្តាប់ចម្លើយសាក្សី ចៅក្រមស៊ើបសួរអាច ស្តាប់ចម្លើយបុគ្គលគ្រប់រូបដែលចម្លើយនេះអាចកើតមានប្រយោជន៍នៅក្នុងការសម្តែងឲ្យឃើញការពិត។ចៅក្រមស៊ើបសួរស្តាប់ចម្លើយសាក្សីដាច់ពីគ្នា ដោយគ្មានវត្តមានជនត្រូវចោទ និងដើមបណ្តឹងរដ្ឋប្បវេណី។ ចៅក្រមស៊ើបសួរក៏អាចសួរតទល់គ្នារវាងជនត្រូវចោទ ដើមបណ្តឹងរដ្ឋប្បវេណី និង

---

[12] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧,មាត្រា១៤៨

[13] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧,មាត្រា១៤៩

[14] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧,មាត្រា១៥០

សាក្សីផងបានដែរ។ បុគ្គលគ្រប់រូប ដែលត្រូវបានចៅក្រមស៊ើបសួរអាចសុំឲ្យកងកម្លាំងសាធារណៈ បង្ខំសាក្សីនេះឲ្យចូលមកបង្ហាញខ្លួនបាន។ ចៅក្រមស៊ើបសួរចេញបញ្ជាឲ្យចូលបង្ហាញខ្លួន។ បញ្ជានេះត្រូវមានអត្តសញ្ញាណរបស់សាក្សីហើយត្រូវចុះកាលបរិច្ឆេទ និង ចុះហត្ថលេខាដោយចៅក្រមស៊ើបសួរ និង មានបោះត្រាផង[15]។ មុននឹងឆ្លើយទៅនឹងសំណួរសាក្សីម្នាក់ៗ ត្រូវស្បថស្របតាមសាសនា ឬ ជំនឿរបស់ខ្លួនថានិយាយតែការពិត។ ចៅក្រមស៊ើបសួរអាចហៅអ្នកប្រែដើម្បីស្តាប់ចម្លើយសាក្សី។

សាក្សីដែលអនុញ្ញាតឲ្យរួចពីសម្បថ មានសាក្សីដូចតទៅនេះ៖

១.ឳពុក ម្តាយ និងបុព្វជនគ្រប់រូបរបស់ជនត្រូវចោទ

២.កូនប្រុស ស្រីនិងបច្ឆាជនគ្រប់រូបផ្សេងទៀតរបស់ជនត្រូវចោទ

៣.បង ប្អូនប្រុស ស្រីរបស់ជនត្រូវចោទ

៤.បង ប្អូនថ្លៃប្រុស ស្រីរបស់ជនត្រូវចោទ

៥.ប្តី ឬ ប្រពន្ធរបស់ជនត្រូវចោទ ទោះបីត្រូវបានលែងលះគ្នាហើយក៏ដោយ

៦.កុមារអាយុតិចជាង១៤ឆ្នាំ[16]។

ដើម្បីគោរពសិទ្ធិការពារខ្លួន ចៅក្រមស៊ើបសួរមិនអាចស្តាប់សួរមិនអាចស្តាច់ចម្លើយក្នុងឋានៈជាសាក្សីនូវបុគ្គលណាមួយដែលមានតម្រុយពិរុទ្ធភាពថាបានប្រព្រឹត្តបទល្មើសនោះទេ។ ប្រសិនបើសាក្សីឈឺ ឬ មិនអាចធ្វើដំណើរបានចៅក្រមស៊ើបសួរ និងក្រឡាបញ្ជី អាចចុះទៅកាន់លំនៅឋាន ឬ ទីកន្លែងដែលសាក្សីនោះនៅ ដើម្បីទទួលចម្លើយ។

**២.១.៤.ការឆែកឆេរ និងការចាប់យកវត្ថុតាង**

វិធានអនុវត្តចំពោះការឆែកឆេរ ចៅក្រមស៊ើបសួរអាចធ្វើការឆែកឆេរបាន[17]។ ចៅក្រមស៊ើបសួរត្រូវឆែកឆេរនៅចំពោះមុខអ្នកកាន់កាប់ទីកន្លែង ឬ បើគ្មានអ្នកកាន់កាប់ទេ ត្រូវធ្វើនៅចំពោះមុខ សាក្សី២ (ពីរ) នាក់ដែលខ្លួនចាត់តាំង។ សាក្សីមិនអាចជានគរបាល ឬ ជាកងរាជអាវុធហត្ថ ដែលជាកងកម្លាំងរួមប្រតិបត្តិការក្នុងការឆែកឆេរនោះបានឡើយ។ ចៅក្រមស៊ើបសួរ មិនអាចផ្តើម ឆែកឆេរមុនម៉ោង ៦(ប្រាំមួយ) ព្រឹក និងក្រោយម៉ោង១៨(ដប់ប្រាំបី) ល្ងាចបានទេ លើកលែងតែ៖

- ក្នុងករណីឆែកឆេរនៅទីកន្លែងដែលបើកចំហរដល់សាធារណជន
- ក្នុងករណីឆែកឆេរនៅគ្រប់ទីកន្លែងដែលផលិតរក្សាទុក ជួញដូរ ចែកចាយ ឬប្រើប្រាស់គ្រឿងញៀន។

ការឆែកឆេរនៅក្នុងការិយាល័យមេធាវី ត្រូវធ្វើនៅចំពោះមុខប្រធានគណៈមេធាវី ឬ ប្រតិភូរបស់គណៈមេធាវី។ ចៅក្រមស៊ើបសួរត្រូវធ្វើកំណត់ហេតុ ស្តីពីការឆែកឆេរដោយមានចុះហត្ថលេខារបស់ខ្លួន និង ក្រឡាបញ្ជី រួមជាមួយអ្នកកាន់កាប់ទីកន្លែង ឬ សាក្សី២(ពីរ) នាក់។ កំណត់ហេតុត្រូវចុះនិទ្ទេស អំពីអត្តសញ្ញាណរបស់អ្នកកាន់កាប់ទីកន្លែង ឬ សាក្សីនីមួយៗ។ កាលបើការឆែកឆេរប្រព្រឹត្តទៅនៅក្នុងការិយាល័យមេធាវី កំណត់ហេតុត្រូវចុះនិទ្ទេសអំពីវត្តមានរបស់ប្រធានគណៈមេធាវី ឬ របស់ប្រតិភូនៃគណៈមេធាវី។

ចៅក្រមស៊ើបសួរអាចចាប់យកវត្ថុតាង។ ចៅក្រមស៊ើបសួរត្រូវតែបិទស្លាកបោះត្រាលើវត្ថុតាង[18]។ ក្រោយពីបង្ហាញវត្ថុដែលបាច់ដល់អ្នកកាន់កាប់ទីកន្លែង ឬ ដល់សាក្សីទាំង២(ពីរ)នាក់រួចមក ចៅក្រមស៊ើបសួរធ្វើកំណត់ហេតុស្តីពីការចាប់ដែលរួមមានបញ្ជីសារពើភ័ណ្ឌនៃវត្ថុដែលចាប់យក។ កំណត់ហេតុស្តីពីការចាប់នេះ ត្រូវចុះហត្ថលេខារបស់ចៅក្រម

[15] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧,មាត្រា១៥៣

[16] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧,មាត្រា១៥៦

[17] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧,មាត្រា១៥៩

[18] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧,មាត្រា១៦០

ស៊ើបសួរ និង ក្រឡាបញ្ជីរួមជាមួយអ្នកកាន់កាប់ទីកន្លែង ឬ សាក្សី (ពីរ)នាក់។ កំណត់ហេតុត្រូវមានចុះនិទ្ទេសអំពីអត្តសញ្ញាណនៃអ្នកកាន់កាប់ទីកន្លែងឬ សាក្សីនីមួយៗ។ នៅពេលដែលមិនទាន់ចេញដីកាដំណោះស្រាយរឿងនៅឡើយទេ ចៅក្រមស៊ើបសួរមានសមត្ថកិច្ចប្រគល់សងម្ចាស់ដើមវិញនូវវត្ថុដែលចាប់បាន កាលណាកម្មសិទ្ធិនេះគ្មានជំទាស់អ្វីប្រាកដប្រជាទេ។ ចៅក្រមស៊ើបសួរសម្រេចតាមដីកាដែលមានសំអាងហេតុ ក្រោយពីបានទទួលមតិពីព្រះរាជអាជ្ញា។ ដីកាសម្រេច ត្រូវឲ្យដំណឹងជាបន្ទាន់ដល់អ្នកប្តឹង និងមេធាវីនៃអ្នកប្តឹងប្រសិនបើមាន។ មិនគួរប្រគល់សងទៅឲ្យអ្នកប្តឹងសុំទេ កាលណាវិធានការនេះ អាចបង្កជាឧបសគ្គដល់ការសម្តែងឲ្យឃើញការពិត។ វត្ថុដែលមានគ្រោះថ្នាក់ដល់បុគ្គល ឬទ្រព្យសម្បត្តិដូចជាអាវុធ ឬ ជាតិផ្ទុះ ព្រមទាំងវត្ថុដែលការកាន់កាប់មិនស្របច្បាប់ មិនអាចត្រូវប្រគល់សងទៅឲ្យសាមីខ្លួនបានទេ។ វត្ថុទាំងនេះរឹបអូសជាកម្មសិទ្ធិរបស់រដ្ឋ។

**២.១.៥.កោសល្យវិច័យ**

នៅក្នុងករណីដែលមាន បញ្ហាបច្ចេកទេសចោទឡើងចៅក្រមស៊ើបសួរអាច បង្គាប់ឲ្យធ្វើកោសល្យវិច័យដោយឯកឯងឬតាមពាក្យសុំរបស់ព្រះរាជអាជ្ញារបស់ជនត្រូវចោទឬដើមបណ្តឹងរដ្ឋប្បវេណី [19] ។កាលណាចៅក្រមស៊ើបសួរបដិសេធមិនព្រមធ្វើតាមពាក្យសុំធ្វើកោសល្យវិច័យចៅក្រមស៊ើបសួរត្រូវសម្រេចតាមដីកាដោយសំអាងហេតុ។ ដីកាសម្រេចក្នុងរយៈពេល៥ (ប្រាំ)ថ្ងៃ ប្រសិនបើពាក្យសុំនោះចេញមកពីព្រះរាជអាជ្ញា និង១(មួយ)ខែ ប្រសិនបើពាក្យសុំនោះចេញមកពីជនត្រូវចោទ ឬ ដើមបណ្តឹងរដ្ឋប្បវេណី។ ដីកាសម្រេចនេះត្រូវជូនដំណឹងឲ្យដល់អ្នកប្តឹងសុំជាបន្ទាន់។ ការធ្វើកោសល្យវិច័យក្នុងរឿងព្រហ្មទណ្ឌ ត្រូវបានបង្កើតឲ្យមានបញ្ជីថ្នាក់ជាតិមួយនៃអ្នកជំនាញ។បញ្ជីនេះត្រូវបានរៀបចំឡើងដោយរដ្ឋ មន្ត្រីក្រសួងយុត្តិធម៌។ បែបបទនៃការចុះឈ្មោះ ឬ លុបឈ្មោះចេញពីបញ្ជីត្រូវកំណត់ដោយប្រកាសរបស់ក្រសួងយុត្តិធម៌។ អ្នកជំនាញដែលត្រូវបានចុះឈ្មោះនៅក្នុងបញ្ជីថ្នាក់ជាតិត្រូវស្បថនៅមុខសាលាឧទ្ធរណ៍ភ្នំពេញ ស្របតាមសាសនា ឬជំនឿរបស់ខ្លួនថានឹងផ្តល់ជំនួយដោយស្មោះត្រង់ ដល់ការស្វែងរកយុត្តិធម៌។

អ្នកជំនាញដែលត្រូវបានចុះឈ្មោះក្នុងបញ្ជីមិនចាំបាច់ ស្បថសាជាថ្មីទៀតទេនៅពេលណា ខ្លួននៅពេលណាខ្លួនត្រូវបានគេចាត់តាំងឲ្យធ្វើកោសល្យវិច្ឆ័យ [20] ។ចៅក្រមស៊ើបសួរ តាមធម្មតាត្រូវជ្រើសរើសអ្នកជំនាញដែលត្រូវបានចុះឈ្មោះនៅក្នុងបញ្ជីថ្នាក់ជាតិនៃអ្នកជំនាញ។ ចៅក្រមស៊ើបសួរ តាមដីកាដោយមានសំអាងហេតុជាពិសេស អាចចាត់តាំងអ្នកជំនាញដែលគ្មានឈ្មោះនៅក្នុងបញ្ជីថ្នាក់ជាតិបាន។

ក្នុងករណីនេះអ្នកជំនាញត្រូវស្បថតាម សាសនា ឬជំនឿរបស់ខ្លួនថា ខ្លួននឹងផ្តល់ជំនួយដោយស្មោះត្រង់សល់ការស្វែងរកយុត្តិធម៌[21] ។អ្នកជំនាញត្រូវបានចាត់តាំងតាមដីការបស់ចៅក្រមស៊ើបសួរ។ដីកាត្រូវបញ្ជាក់អំពីបេសកម្មរបស់អ្នកជំនាញព្រមទាំងរយៈពេល ត្រូវបំពេញបេសកម្មនេះ។ បេសកម្មអាចទាក់ទងទៅនឹងបញ្ហា ដែលមានលក្ខណៈបច្ចេកទេសតែប៉ុណ្ណោះ។ប្រសិនបើជាគួរចៅក្រមស៊ើបសួរប្រគល់វត្ថុដែលចាប់បានមួយផ្នែកឬទាំងអស់នោះជូនអ្នកជំនាញ។ ចៅក្រមស៊ើបសួរត្រូវធ្វើកំណត់ហេតុស្តីពីការប្រគល់វត្ថុដែលចាប់បាន។ អ្នកជំនាញអាចបំបែកស្លាកដែលបិទដើម្បីធ្វើកោសល្យវិច្ឆ័យបាន។

---

[19] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧,មាត្រា១៦២

[20] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧,មាត្រា១៦៣

[21] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧,មាត្រា១៦៤

ប្រសិនបើកោសល្យវិច្ឆ័យនេះ អាចធ្វើឲ្យខូចខាត ឬ វិនាសដល់វត្ថុដែលចាប់បាននោះ អ្នកជំនាញត្រូវជូនព័ត៌មានដល់ចៅក្រមស៊ើបសួរ និងសុំការអនុញ្ញាតពីចៅក្រមនេះ មុននឹងផ្ដើមប្រតិបត្តិការរបស់ខ្លួន [22] ។ អ្នកជំនាញបំពេញបេសកកម្មរបស់ខ្លួន ក្រោមការត្រួតពិនិត្យរបស់ចៅក្រមស៊ើបសួរ។ អ្នកជំនាញត្រូវជូនព័ត៌មានដល់ចៅក្រមស៊ើបសួរ អំពីការប្រព្រឹត្តទៅនៃបេសកកម្មរបស់ខ្លួនជាអាទិ៍ ការលមបាកដែលខ្លួនអាចជួបប្រទះ។ ប្រសិនបើអ្នកជំនាញមិនគោរពរយៈពេលដែលកំណត់ដោយចៅក្រមស៊ើបសួរទេ ចៅក្រមស៊ើបសួរចាត់អ្នកជំនាញផ្សេងទៀតជំនួសអ្នកជំនាញនោះ។

ប៉ុន្តែប្រសិនបើកាលៈទេសៈតម្រូវនោះ ចៅក្រមនោះ ចៅក្រមស៊ើបសួរអាចអនុញ្ញាតតាមដីកាសម្រេចឲ្យធ្វើការពន្យារពេលបាន។ ដើម្បីបំពេញបេសកកម្មរបស់ខ្លួន អ្នកជំនាញអាចស្ដាប់ចម្លើយបុគ្គលគ្រប់រូបក្រៅពីជនត្រូវចោទ។ ចម្លើយដែលអ្នកជំនាញបានទទួលនោះ មានតម្លៃត្រឹមតែជាព័ត៌មានធម្មតា។ បុគ្គលដែលអ្នកជំនាញស្ដាប់ចម្លើយនោះមិនបាច់ស្បថទេ។ ប្រសិនបើខ្លួនយល់ឃើញថាចាំបាច់ត្រូវស្ដាប់ចម្លើយនត្រូវចោទ អ្នកជំនាញត្រូវសុំការអនុញ្ញាតពីចៅក្រមស៊ើបសួរជនត្រូវចោទអាចសុំឲ្យអ្នកជំនាញស្ដាប់ចម្លើយរបស់ខ្លួននចំពោះមុខមេធាវី។ ប៉ុន្តែ កាលណាចៅក្រមស៊ើបសួរចាត់តាំងគ្រូពេទ្យ ឬ អ្នកចិត្តសាស្ត្រដើម្បីពិនិត្យជនត្រូវចោទនោះការពិនិត្យវេជ្ជសាស្ត្រ ឬ ចិត្តសាស្ត្រ ត្រូវធ្វើដោគ្មានវត្តមានមេធាវី[23]។ កាលណាប្រតិបត្តិការកោសល្យវិច្ឆ័យបានបញ្ចប់ អ្នកជំនាញធ្វើរបាយការណ៍ដែលនៅក្នុងនោះ ត្រូវពណ៌នាយ៉ាងច្បាស់លាស់អំពីប្រតិបត្តិការរបស់ខ្លួន ហើយនិងធ្វើសេចក្ដីសន្និដ្ឋាន។ អ្នកជំនាញត្រូវបញ្ជាក់ថាបានធ្វើដោយផ្ទាល់ខ្លួន នូវប្រតិបត្តិការដែលពណ៌នានៅក្នុងរបាយការណ៍។របាយការណ៍ត្រូវចុះកាលបរិច្ឆេទ និងចុះហត្ថលេខា។ កាលណាអ្នកជំនាញបានបំបែកស្លាកដើម្បីពិនិត្យវត្ថុដែលចាប់យក អ្នកជំនាញត្រូវចុះនិទ្ទេសអំពីបញ្ហានេះនៅ ក្នុងរបាយការណ៍របស់ខ្លួន។ កាលណាអ្នកជំនាញប្រគល់របាយការណ៍របស់ខ្លួននោះ អ្នកជំនាញត្រូវប្រគល់ដល់ចៅក្រមស៊ើបសួរវិញនូវវត្ថុដែលចាប់យក។

ប្រសិនបើស្លាកត្រូវបានបំបែក ចៅក្រមស៊ើបសួរត្រូវបិទស្លាកជាថ្មីនៅលើវត្ថុនោះ។កំណត់ហេតុស្ដីពីការប្រគល់ស្ដីពីការប្រគល់សងនូវវត្ថុនិងជាយថាហេតុ ការបិទស្លាកជាថ្មីលើវត្ថុនោះត្រូវធ្វើឡើងវិញ។ កាលណាកោសល្យវិច្ឆ័យធ្វើឲ្យខូចខាត ឬ វិនាសនូវវត្ថុដែលចាប់បាន អ្នកជំនាញត្រូវចុះនិទ្ទេសនៅក្នុងរបាការណ៍របស់ខ្លួនអំពីការអនុញ្ញាតរបស់ចៅក្រមស៊ើបសួរ។ក្នុងករណីដែលអាចធ្វើបាននោះ អ្នកជំនាញត្រូវធ្វើសេចក្ដីចម្លងរបាការណ៍ ហើយជូនទៅចៅក្រមស៊ើបសួរ[24]។ប្រសិនបើកាលៈទេសៈតម្រូវ ចៅក្រមស៊ើបសួរអាចចាត់តាំងអ្នកជំនាញច្រើននាក់។ នៅក្នុងករណីនេះ ប្រសិនបើអ្នកជំនាញនេះមានយោបល់ខុសគ្នានោះម្នាក់ៗ ត្រូវសរសេរអំពីយោបល់ខ្លួនផ្ទាល់ ឬការមិនយល់ព្រមរបស់ខ្លួន។

កាលណារបាយការណ៍កោសល្យវិច្ឆ័យត្រូវបានធ្វើរួចហើយ ចៅក្រមស៊ើបសួរត្រូវជូនព័ត៌មានដល់ព្រះរាជអាជ្ញា។ របាយការណ៍កោសល្យវិច្ឆ័យត្រូវដាក់ចូលក្នុងសំណុំរឿងស៊ើបសួរ។ ចៅក្រមស៊ើបសួរអាចកោះហៅជនត្រូវចោទ និងមេធាវី ដើម្បីប្រាប់ឲ្យដឹងពីសេចក្ដីសន្និដ្ឋាននៃកោសល្យវិច័យនេះ។ ចៅក្រមស៊ើបសួរអាចកោះហៅដើមបណ្ដឹងរដ្ឋប្បវេណីនិងមេធាវីផងដែរ ដើម្បីប្រាប់ឲ្យដឹងពីសេចក្ដីសន្និដ្ឋាននៃកោសល្យវិច័យ។ ចៅក្រមស៊ើបសួរកំណត់រយៈពេលដែលអនុញ្ញាតឲ្យព្រះរាជអាជ្ញា ជនត្រូវចោទ ឬ ដើមបណ្ដឹងរដ្ឋប្បវេណីដាក់ពាក្យសុំធ្វើកោសល្យវិច័យបន្ថែម ឬ ប្រតិកោសល្យវិច័យ។ រយៈពេលនៃការអនុញ្ញាតដាក់ពាក្យស្នើសុំ មិនតិចជាង ១០ (ដប់) ថ្ងៃទេ។ ក្នុងរយៈពេលនេះ សំណុំរឿងដែលរួម

---

[22] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧,មាត្រា១៦៥

[23] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧,មាត្រា១៦៧

[24] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧,មាត្រា១៦៨

មានរបាយការណ៍កោសល្យវិច័យ អាចត្រូវបានពិនិត្យមើលដោយមេធាវី។ គ្រប់ពាក្យសុំដីកោសល្យវិច័យបន្ថែម ឬ ប្រតិកោសល្យវិច័យ ត្រូវតែមានសំអាងហេតុ និងធ្វើឡើងដោយលាយលក្ខណ៍អក្សរ។ កាលណាចៅក្រមស៊ើបសួរមិនព្រមធ្វើតាមពាក្យសុំកោសល្យវិច័យបន្ថែម ឬ ប្រតិកោសល្យវិច័យទេ ចៅក្រមស៊ើបសួរត្រូវសម្រេចតាមដីកាដោយសំអាងហេតុ។ ដីកាត្រូវតែសម្រេចក្នុងរយៈពេល ៥(ប្រាំ) ថ្ងៃ ប្រសិនបើពាក្យសុំចេញមកពីព្រះរាជអាជ្ញានិង ១(មួយ) ខែ ប្រសិនបើពាក្យនេះចេញពីជនត្រូវចោទ ឬ ដើមបណ្ដឹងរដ្ឋប្បវេណី។ដីកាត្រូវឲ្យដំណឹងជាបន្ទាន់ដល់អ្នកប្ដឹងសុំ។ គ្រប់ពាក្យសុំធ្វើកោសល្យវិច័យបន្ថែម ឬ ប្រតិកោសល្យវិច័យដែលធ្វើឡើងក្រោយផុតរយៈ ពេលដែលកំណត់ដោយចៅក្រមស៊ើបសួរ ត្រូវដាក់បញ្ចូលក្នុងសំណុំរឿង។ប្រសិនបើចៅក្រមស៊ើបសួរដែលបានទទួលពាក្យសុំឲ្យធ្វើកោសល្យវិច័យធ្វើកោសល្យវិច័យបន្ថែម ឬប្រតិកោសល្យវិច័យមិនព្រមសម្រេចក្នុងរយៈពេលដែលបានកំណត់នេះទេ អ្នកសុំអាចធ្វើពាក្យប្ដឹងដោយផ្ទាល់តាមរយៈពាក្យ សុំដល់សភាស៊ើបសួរដែលសម្រេចជំនួសចៅក្រមស៊ើបសួរ។

សោហ៊ុយក្នុងការធ្វើកោសល្យវិច័យជាបន្ទុករបស់អ្នកស្នើសុំ។ កាលណា ចៅក្រមស៊ើបសួរ ព្រះរាជអាជ្ញា ឬ មន្ត្រីនគរបាលយុត្តិធម៌ ស្នើសុំឲ្យធ្វើកោសល្យវិច័យ កោសល្យវិច័យបន្ថែម ឬ ធ្វើប្រតិកោសល្យវិច័យ សោហ៊ុយទាំងនេះជាបន្ទុករបស់រដ្ឋ។

**២.១.៦.ការស្ដាប់ទូរស័ព្ទ**

តាមការចាំបាច់ដើម្បីសំដែង ឲ្យឃើញនូការពុតចៅក្រមស៊ើបសួរអាចបង្គាប់ឲ្យស្ដាប់ និងថតការសន្ទនាតាមទូរស័ព្ទ។ ចៅក្រមស៊ើបសួរក៏អាចឲ្យចាប់ និងថតគ្រប់ការឆ្លើយឆ្លងគ្នាតាមបច្ចេកវិធីទូរគមនាគមន៍ផងដែរដូចជា សារតាមទូរសារ ឬ សារតាមអិនធើណែត[25]។ ចៅក្រមស៊ើបសួរបញ្ជាក់នៅក្នុងដីកាសម្រេចរបស់ខ្លួនអំពីប្រភេទនៃទំនាក់ទំនងដែលត្រូវចាប់ ព្រមទាំងអំពីរយៈពេលនៃបេសកកម្ម។អង្គភាពសាធារណៈមន្ត្រីរាជការដែលចាត់តាំង ត្រូវបំពេញតាមពាក្យសុំរបស់ចៅក្រមស៊ើបសួរ នៅក្នុងពេលអនុវត្តបេសកកម្ម អង្គភាព សាធារណៈឬ គ្រប់មន្ត្រីរាជការដែលចាត់តាំងត្រូវជូនព័ត៌មានដល់ចៅក្រមស៊ើបសួរអំពីការប្រព្រឹត្តទៅនៃបេសសកម្មជាអាទិ៍អំពីការលំបាកជាយថាហេតុ។

កាលណាបេសកកម្មត្រូវបានបំពេញតួនាទីរួចរាល់ហើយអង្គភាពសាធារណៈ ឬគ្រប់មន្ត្រីរាជការនោះត្រូវសម្លេងជាលាយលក្ខណ៍អក្សរនូវសំឡេងដែលថតបាន។ ការធ្វើឲ្យទៅជាលាយលក្ខណ៍អក្សរនេះ ត្រូវឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវនូវខ្លឹមសារនៃសំឡេងដែលថតបាន។ សំឡេងដែលថតបាននេះត្រូវប្រគល់ជូនទៅចៅក្រមស៊ើបសួរ និងបិទស្លាក។គ្រប់ពេលវេលាចៅក្រមស៊ើបសួរអាច ចុះទៅកាន់ទីកន្លែងដែលធ្វើការចាប់និងថត។ ការចូលរួមទៅក្នុងទីកន្លែងទាំងនេះមិនអាចត្រូវបានហាមឃាត់ដល់ចៅក្រមស៊ើបសួ រដោយសំអាងលើមូលហេតុអ្វីបានទេទោះបីជាទីកន្លែងយោធាក៏ដោយ។ ចៅក្រមស៊ើបសួរក៏អាចធ្វើកិច្ចការនេះតាមដីកាចាត់ឲ្យស៊ើបសួរជំនួសបានដែរ។

**២.២.សិទ្ធិអំណាចរបស់ចៅក្រមស៊ើបសួរក្នុងការចាត់ចែងអង្គហេតុ**

**២.២.១.ការបំពេញកិច្ចស៊ើបសួរដោយផ្ទាល់របស់ចៅក្រមស៊ើបសួរ**

នៅក្នុងចំណាត់ការនៃកិច្ចនីតិវិធីស៊ើបសួរ ជាភារកិច្ចផ្ដាច់មុខរបស់ចៅក្រមស៊ើបសួរ អាស្រ័យហេតុនេះ មានតែចៅក្រមស៊ើបសួរទេ ដែលអាចចាត់ចែងគ្រប់សកម្មភាព ឬនីតិវិធីដែលមានចែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ។ ក្រមនីតិវិធីព្រហ្មទណ្ឌ បានផ្ដល់សិទ្ធិដល់ចៅក្រមស៊ើបសួរប្រើប្រាស់គ្រប់មធ្យោបាយក្នុងការស៊ើបសួរទៅលើរឿង ក្ដីដែលខ្លួនគិតថា អាចជួយដោះស្រាយរឿងក្ដីដែលកំពុងធ្វើការស៊ើបសួរ។ ក្នុងដំណាក់ការស៊ើបសួរ ចៅក្រមស៊ើបសួរធ្វើការស្វែងរកទាំងភស្តុតាងដាក់បន្ទុកផង និងភស្តុតាងដោះបន្ទុកផង ចំពោះជនត្រូវចោទ។ ចំណាត់ការនៃកិច្ចនីតិវិធីរបស់ចៅក្រមស៊ើបសួរ មានសារៈសំខាន់ក្នុងការស្វែងរកការពិតដល់ជនរងគ្រោះ និងធានាស្វែងរកភាពស្អាតស្អំនៃជនត្រូវចោទ។

[25] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧,មាត្រា១៧២

ក្រោយពីការធ្វើពិនិត្យទៅលើអង្គហេតុក្នុងការស្វែងរកការពិតបុគ្គលិកលក្ខណៈរបស់បុគ្គលម្នាក់ជាកត្តាសំខាន់មួយ។ កិច្ចស៊ើបសួរទាក់ទងទៅនឹងបុគ្គលក្ខណៈរបស់ជនត្រូវចោទមានសារៈសំខាន់ចំពោះកិច្ចស៊ើបសួរ ដោយហេតុថា តុលាការអាចធ្វើការស្វែងយល់ពីកម្រិតគ្រោះថ្នាក់នៃជនត្រូវចោទចំពោះសង្គម។ កាលៈទេសៈនៃការប្រព្រឹត្តបទល្មើស ឬ បុគ្គលក្ខណៈនៃជនត្រូវចោទ ជាកត្តាដែលឲ្យជនជាប់ចោទទទួលបានស្ថានសម្រាលទោស[26]។

ឧទាហរណ៍៖ ដីកាសម្រេចបញ្ជូនរឿងឲ្យស៊ើបសួរចំពោះបុគ្គលឈ្មោះ"ក"ដែលតំណាងអយ្យការធ្វើការចោទប្រកាន់ពីបទលួច។ ក្រោយកិច្ចស៊ើបសួររបស់ចៅក្រមស៊ើបសួរ តាមដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ របស់ព្រះរាជអាជ្ញា ចៅក្រមស៊ើបសួរបានរកឃើញថាមូលហេតុដែលនាំឲ្យលោក "ក" សម្រេចចិត្តលួចម្ហូបអាហារ ដែលលោក "ខ" លក់ក្បែរចិញ្ចើមផ្លូវព្រោះ លោក "ក" ស្រេកឃ្លានអាហារជាខ្លាំងហើយគ្មានប្រាក់។ ក្នុងករណីនេះ ចៅក្រមស៊ើបសួរអាចសម្រេចធ្វើការ ចោទប្រកាន់អមជាមួយនឹងលក្ខខណ្ឌដែលទទួលបាន ដែលទទួលបានស្ថានសម្រាលទោស ឬអាចសម្រេចលើកលែងការចោទប្រកាន់។

**២.២.២.ដីកាចាត់ឲ្យស៊ើបសួរជំនួស**

ក្រមនីតិវិធីព្រហ្មទណ្ឌបានផ្តល់សិទ្ធិដល់ចៅក្រមស៊ើបសួរ ក្នុងការធ្វើការផ្ទេរស៊ើបសួររបស់ខ្លួនឲ្យស៊ើបសួរជំនួសតាមរយៈដីកាចាត់ឲ្យស៊ើបសួរជំនួសបាន[27]។ ទោះបីជាមានការផ្ទេរសិទ្ធិក្នុងការស៊ើបសួរជំនួសក៏ដោយតែដែនសមត្ថកិច្ចក្នុងការអនុវត្តត្រូវស្ថិតដដែលពោល គឺត្រូវគោរពទៅតាមដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបស់អយ្យការដែរ។ ក្នុងការស៊ើបសួរជំនួសនេះ គឺចៅក្រមស៊ើបសួរ ត្រូវធ្វើការបញ្ជាក់ពីកិច្ចដែលខ្លួនបានផ្ទេរសម្រាប់ការស៊ើបសួរជំនួសនោះ។ ជាងនេះទៅទៀតនោះដីកាចាត់ឲ្យស៊ើបសួរជំនួសក៏ត្រូវធ្វើការណែនាំឲ្យបានច្បាស់លាស់ដើម្បីជៀសវាងនូវ ការអនុវត្តខុសពីនីតិវិធីនៃកិច្ចស៊ើបសួរ។

ម្យ៉ាងទៀតក្នុងករណីណាក៏ដោយ ក្រឡាបញ្ជីមិនអាចបំពេញកិច្ចដែល ជាសមត្ថកិច្ចរបស់ចៅក្រមស៊ើបសួរបានទេ។ ជាគោលការណ៍ ក្រមនីតិវិធីព្រហ្មទណ្ឌបានធ្វើការបែងចែកយ៉ាង ច្បាស់លាស់ពីសមាសភាពនៃស្ថាប័នដែល អាចបើកការស៊ើបសួរជំនួសព្រះរាជអាជ្ញានិងបញ្ជាក់ពីនីតិវិធីក្នុងការបំពេញកិច្ចស៊ើបសួរជំនួសចៅក្រមស៊ើបសួរផងដែរ។

ដូច្នេះដើម្បីសិក្សាពីកិច្ចនៃការស៊ើបសួរជំនួសគេត្រូវធ្វើការពិនិត្យទៅលើជនដែលអាចទទួលចាត់ឲ្យស៊ើបសួរជំនួស និងកម្មវត្ថុនៃការចាត់ឲ្យស៊ើបសួរជំនួស។

**ក.ជនដែលអាចទទួលការ**

ដើម្បីធានានូវភាពយុត្តិធម៌ ក្នុងបណ្តឹងព្រហ្មទណ្ឌក្រមនីតិវិធីព្រហ្មទណ្ឌ ក៏បានធ្វើការបែងចែកដាច់ពីគ្នានូវអំណាចនៅក្នុងដំណាក់កាលនីមួយៗនៃចំណាត់ការរឿងព្រហ្មទណ្ឌ។ វិសមតិភាពនៃការបែងចែអំណាចមានសារៈសំខាន់ណាស់ ព្រោះជាគោលការណ៍សម្រាប់បញ្ចៀសនូវ ការគ្រប់គ្រងទៅលើរឿងក្តីនៃបណ្តឹងព្រហ្មទណ្ឌដោយបុគ្គលតែម្នាក់។ គោលការណ៍វិសមតិភាពនៃការបែងចែកអំណាច ក៏ត្រូវបានយកមកប្រើប្រាស់ក្នុងដំណាក់កាលនសការស៊ើបសួរនេះផងដែរ។

ក្នុងដំណាក់កាលស៊ើបសួរ ស្ថាប័នអយ្យការមិនត្រូវបានអនុញ្ញាតឲ្យធ្វើការស៊ើបសួរជំនួសបានឡើយ ព្រោះការចោទចាត់ឲ្យស៊ើបសួរជំនួសប្រកាន់គឺ ត្រូវធ្វើឡើងដោយព្រះរាជអាជ្ញា ដូច្នេះប្រសិនមានការអនុញ្ញាតឲ្យព្រះរាជអាជ្ញាមានសិទ្ធិក្នុងការស៊ើបសួរនោះ ព្រះរាជអាជ្ញានឹងធ្វើការស្វែងរកភស្តុតាងដាក់បន្ទុកដែលនេះធ្វើឲ្យ មានភាពលំអៀងនៅក្នុងការស្វែងរកការពិត។

---

[26] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧,មាត្រា៩៣

[27] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧,មាត្រា១៧៣

តាមមាត្រា ១៧៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌបានបញ្ញត្តិថា ចៅក្រមស៊ើបសួរអាចធ្វើការផ្ទេរសិទ្ធិក្នុងការបំពេញកិច្ចស៊ើបសួរឬទៅឲ្យចៅក្រមនៃតុលាការជាមួយគ្នា ឬ តុលាការផ្សេងទៀត មន្ត្រីនគរបាលយុត្តិធម៌ ឬ ដល់អង្គភាពនៃមន្ត្រីនគរបាលយុត្តិធម៌[28]។

**ខ.ការផ្ទេរអំណាចស៊ើបសួរទៅឲ្យចៅក្រមតុលាការជាមួយគ្នា ឬ តុលាការផ្សេងទៀត**

ក្រមនីតិវិធីព្រហ្មទណ្ឌបានធ្វើ ការអនុញ្ញាតឲ្យចៅក្រមស៊ើបសួរ អាចធ្វើការផ្ទេរនូវសិទ្ធិក្នុងការបំពេញកិច្ចទៅឲ្យចៅក្រមនៅក្នុងតុលាការជាមួយគ្នា ឬចៅក្រមនៃតុលាការផ្សេង ឲ្យបើកការស៊ើបសួរទៅលើកិច្ចការជំនួសឲ្យខ្លួនបាន។ ទោះជាការផ្ទេរនូវសមត្ថកិច្ចពីចៅក្រមអាសនៈមួយទៅចៅក្រមមួយរូបទៀត ដែលមានឋានានុក្រម និងស្ថិតនៅស្ថាប័នដូចគ្នាក៏ដោយ ក៏ការផ្ទេរនូវអំណាចត្រូវធ្វើតាមដីកាចាត់ឲ្យស៊ើបសួរជំនួសដែរ ហើយលើសពីនេះទៅទៀត នៅក្នុងដីកាក៏ត្រូវធ្វើការបញ្ជាក់ ឲ្យបានច្បាស់ពីកិច្ចដែលត្រូវបានចាត់ឲ្យស៊ើបសួរជំនួស ក៏ដូចជាការបញ្ជាក់ពីការកំណត់បង្ហាញពីនិតិវិធីដែលត្រូវធ្វើការស៊ើបសួរជំនួសផងដែរ។

**គ.ការផ្ទេរអំណាចស៊ើបសួរទៅឲ្យចៅក្រម**

ក្រៅពីការផ្ទេរសិទ្ធិ នៅក្នុងកិច្ចស៊ើបសួរជំនួសទៅឲ្យចៅក្រម ដែលមានឋានានុក្រមដូចគ្នាក្រមនីតិវិធីបានអនុញ្ញាតឲ្យមានការផ្ទេរអំណាចនគរបាលយុត្តិធម៌ ឬ ស្ថាប័នមន្ត្រីនគរបាលយុត្តិធម៌ផងដែរ។ ការផ្ទេរសិទ្ធិទៅឲ្យមន្ត្រីនគរបាលយុត្តិធម៌ឲ្យស៊ើបសួរជំនួស ត្រូវធ្វើឡើងតាមរយៈដីកាចាត់ឲ្យស៊ើបសួរជំនួស ដោយក្នុងនោះត្រូវមានតែបញ្ជាក់នូវកិច្ចដែលត្រូវបំពេញ និងការកំណត់បង្ហាញពីចំណាត់ការនៃកិច្ចទៅតាមអ្វីដែលចៅក្រមស៊ើបសួរចង់ឲ្យធ្វើ។

**ឃ.កម្មវត្ថុនៃការចាត់ឲ្យស៊ើបសួរ**

គោលការណ៍ណែការផ្ទេរអំណាចក្នុងដំណាក់ការស៊ើបសួរ ក៏បានធ្វើការចែងបន្ថែមនូវសមត្ថកិច្ចដោយឡែកទៅលើចំណាត់ការនៃកិច្ចក្នុងការបណ្ដឹងអាជ្ញា ក្នុងដំណាក់កាលស៊ើបសួរផងដែរ។ដោយឡែក ដើម្បីធ្វើការកំណត់ឲ្យកាន់តែច្បាស់នៃនីតិវិធីនិងចំណាត់ការនៃការស៊ើបសួរជំនួសផងដែរ។ ការបញ្ញត្តិនូវបទបញ្ញត្តិក្នុងការបំពេញកិច្ចទៅតាមសមាសភាពនៃស្ថាប័នដែលត្រូវបានចាត់តាំងឲ្យធ្វើការស៊ើបសួរជំនួស ជាការកំណត់ទៅលើសមត្ថកិច្ចដែលតួអង្គជំនួសអាចធ្វើបានតែមិនអាចធ្វើការរំលោភបំពានបានឡើយ។

**ង.កម្មវត្ថុនៃការចាត់ឲ្យស៊ើបសួរជំនួសដោយចៅក្រមតុលាការតែមួយ ឬតុលាការផ្សេង**

ទូទៅក្នុងការបំពេញកិច្ចត្រូវបានបំពេញដោយចៅក្រមស៊ើបសួរចៅក្រមដែលត្រូវមានជ្រើសតាំងឲ្យធ្វើការស្រាវជ្រាវជំនួសមានសិទ្ធិក្នុងការបើកការស៊ើបសួរទៅលើរាល់កិច្ចជាដែលមានចែងស្ដីពីនីតិវិធីនៃការស៊ើបសួរដោយចៅក្រមជំនួសមានសិទ្ធិដូចទៅនឹងចៅក្រមស៊ើបសួរដែរ។

ដោយសារតែ ចៅក្រមស៊ើបសួរក៏ជាចៅក្រមអាសនៈនៅតុលាការដែរហេតុនេះក្នុងឋានានុក្រមនេះចៅក្រមអាសនៈដែលត្រូវបានតែងតាំងឲ្យ ធ្វើការស៊ើបសួរជំនួសត្រូវបានផ្ដល់សិទ្ធិ និងអំណាចទាំងអស់របស់ចៅក្រមស៊ើបសួរ ក្នុងការបំពេញកិច្ចដែលត្រូវបាវចាត់តាំង តែការបំពេញកិច្ចត្រូវតែស្ថិតនៅក្នុងការណែនាំតាមដីកាចាត់ឲ្យស៊ើបសួរជំនួសរបស់ចៅក្រមដែលទទួលបន្ទុករឿងក្ដីដែរ។

**ច.កម្មវត្ថុនៃការចាត់ឲ្យស៊ើបសួរជំនួសដោយមន្ត្រីនគរបាលយុត្តិធម៌**

[28] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧,មាត្រា១៧៣

ជាគោលការណ៍ចៅក្រមស៊ើបសួរអាចផ្ទេរសិទ្ធិទៅឲ្យមន្ត្រីនគរបាលយុត្តិធម៌បានមួយចំនួនតែក្នុងនោះ សិទ្ធិក្នុងការសួរជនត្រូវចោទ និងសិទ្ធិក្នុងការស្តាប់ចម្លើយនៃបណ្តឹងរដ្ឋប្បវេណីមិនត្រូវបានអនុញ្ញាតឲ្យផ្ទេរទៅឲ្យព្រះរាជអាជ្ញាឡើយ។ ការមិនអនុញ្ញាតឲ្យមន្ត្រីនគរបាលយុត្តិធម៌ បំពេញនូវកិច្ចទាំងពីរខាងលើដោយសារក្នុងវិធានខាងលើ មន្ត្រីនគរបាលយុត្តិធម៌បានបំពេញរួចទៅហើយនៅក្នុងដំណាក់កាលនៃការស៊ើបអង្កេតមកហើយ។ ដូចនេះ បើមានការអនុញ្ញាតឲ្យមន្ត្រីនគរបាលយុត្តិធម៌ធ្វើបំពេញកិច្ចផ្សេងៗ ក្រមនីតិវិធីក៏បានកំណត់ពីកិច្ចដែលជាកម្មវត្ថុនៃការផ្ទេរអំណាចក្នុងការស៊ើបសួរទៅឲ្យមន្ត្រីនគរបាលយុត្តិធម៌ដែលក្នុងនោះមានដូចជាវិធានទាក់ទងនឹងការស្តាប់ចម្លើយ ការឆែកឆេរនិងការចាប់យកវត្ថុតាងការឃាត់ខ្លួនក្នុងក្របខណ្ឌនៃការស៊ើបសួរការស្តាប់ទូរសព្ទដែលក្នុងនោះ។ក្នុងចំណាត់ការនៃការបំពេញកិច្ចស៊ើបសួរជំនួសតម្រូវឲ្យមន្ត្រីនគរបាលធ្វើកំណត់ហេតុស្តីពីកិច្ចស្រាវជ្រាវនិងពិនិត្យរបស់ខ្លួនឲ្យបានច្បាស់លាស់ចំពោះកំណត់ហេតុដែលត្រូវធ្វើឡើងដោយមន្ត្រីនគរបាលយុត្តិធម៌នៅក្នុងក្របខណ្ឌ នៃការស៊ើបសួរជំនួស ត្រូវមានចុះនិទ្ទេសដូចប្រការដែលបានចែងក្នុងមាត្រា១០៨ និង នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

### ២.៣..សិទ្ធិអំណាចបង្ខំរបស់ចៅក្រមស៊ើបសួរ ឬ វិធានការនិរន្តរាយ

#### ២.៣.១.ការបង្ខំឲ្យចូលខ្លួនក្នុងដំណើរការកិច្ចនីតិវិធី

##### ក.ដីកាបង្គាប់ឲ្យចូលខ្លួន

ចៅក្រមស៊ើបសួរ អាចចេញដីកាបង្គាប់ឲ្យចូលខ្លួន[29]។ ដីកាបង្គាប់ឲ្យចូលខ្លួនគឺជាបញ្ជាសល់បុគ្គលណាម្នាក់ឲ្យចូលខ្លួននៅមុខចៅក្រមស៊ើបសួរ។ ដីកាបង្គាប់ឲ្យចូលខ្លួន អាចចេញទៅលើជនត្រូវចោទឬ ទៅលើបុគ្គលណាម្នាក់ដែលមានតម្រុយពិរុទ្ធភាព។ ដីកាបង្គាប់ឲ្យចូលខ្លួនមាននិទ្ទេសដូចតទៅៈ

- អត្តសញ្ញាណនៃបុគ្គលដែលពាក់ព័ន្ធ
- បទល្មើសដែលចោទប្រកាន់និង អត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើសនេះ
- ថ្ងៃ ខែ ឆ្នាំ ម៉ោង និងទីកន្លែងដែលត្រូវចូលបង្ហាញខ្លួននៅមុខចៅក្រមស៊ើបសួរ
- ឈ្មោះ និងឋានៈរបស់ចៅក្រមដែលចេញដីកា

ដីកាបង្គាប់ឲ្យចូលខ្លួនត្រូវមានចុះកាលបរិច្ឆេទ និងចុះហត្ថលេខាដោយចៅក្រមស៊ើបសួរ និងមានបោះត្រាផង[30]។

ដីកាបង្គាប់ឲ្យចូលខ្លួន ត្រូវឲ្យដំណឹងដល់បុគ្គលដែលពាក់ព័ន្ធ ដោយមន្ត្រីនគរបាលយុត្តិធម៌ ភ្នាក់ងារនគរបាលយុត្តិធម៌ ឬ ដោយអាជ្ញាសាលា។ បុគ្គលដែលពាក់ព័ន្ធទទួលចុងដីកា ហើយត្រូវចុះហត្ថលេខានៅលើដើមដីកា ដែលត្រូវបង្វិលជូនចៅក្រមស៊ើបសួរវិញ។ មន្ត្រីនគរបាលយុត្តិធម៌ភ្នាក់ងារនគរបាលយុត្តិធម៌ ឬ អាជ្ញាសាលាត្រូវជូនដំណឹងដល់ចៅក្រមស៊ើបសួរអំពីគ្រប់ការលំបាកក្នុងការអនុវត្តបេសសកម្មរបស់ខ្លួន[31]។

##### ខ.ដីកាបង្គាប់ឲ្យនាំខ្លួន

ចៅក្រមស៊ើបសួរអាចចេញដីកាបង្គាប់ឲ្យនាំខ្លួនបាន[32]។ ដីកាបង្គាប់ឲ្យនាំខ្លួន គឺជាបញ្ជាដល់កងកម្លាំងសាធារណៈឲ្យចាប់ខ្លួននិងនាំខ្លួនបុគ្គលណាម្នាក់ទៅចំពោះមុខចៅក្រមស៊ើបសួរ។ដីកាបង្គាប់ឲ្យនាំខ្លួនអាចត្រូវចេញទៅលើជនត្រូវចោទ ឬទៅលើបុគ្គលណាម្នាក់ដែលមានតម្រុយពិរុទ្ធភាព។ដីកាបង្គាប់ឲ្យនាំខ្លួនមាននិទ្ទេសដូចតទៅៈ

[29] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧,មាត្រា១៨៦

[30] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧,មាត្រា១៨៧

[31] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧,មាត្រា១៨៨

[32] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧,មាត្រា១៨៩

- អត្តសញ្ញាណនៃបុគ្គលដែលពាក់ព័ន្ធ
- បទល្មើសដែលចោទប្រកាន់ និងអត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើសនេះ

ឈ្មោះ និងឋានៈរបស់ចៅក្រមដែលចេញដីកាបង្គាប់ឲ្យនាំខ្លួន ត្រូវចុះកាលបរិច្ឆេទ និងចុះហត្ថលេខាដោយចៅក្រមស៊ើបសួរ និងមានបោះត្រាផង[33]។

ការអនុវត្តបង្គាប់ឲ្យនាំខ្លួនត្រូវប្រគល់ឲ្យមន្ត្រីនគរបាលយុត្តិធម៌។

ក្នុងករណីបន្ទាន់ដីកាបង្គាប់ឲ្យនាំខ្លួនត្រូវផ្សព្វផ្សាយដល់អង្គភាពនគរបាល ឬកងរាជអាវុធហត្ថតាមគ្រប់មធ្យោបាយ។ ដើមដីកានេះ ត្រូវប្រគល់ជូនជាបន្ទាន់ដល់មន្ត្រីនគរបាលយុត្តិធម៌ ដែលទទួលបន្ទុកអនុវត្តដីកានេះ។ មន្ត្រីនគរបាលយុត្តិធម៌ មិនអាចចូលទៅក្នុងលំនៅឋានរបស់បុគ្គលដែលពាក់ព័ន្ធមុនម៉ោង៦ (ប្រាំមួយ) ព្រឹក និងក្រោយម៉ោង១៨ (ដប់ប្រាំបី) ល្ងាចបានទេ។មន្ត្រីនគរបាលយុត្តិធម៌ត្រូវជូនតំណឹងដល់ចៅក្រមស៊ើបសួរអំពីការលំបាកក្នុងការអនុវត្តបេសកកម្មរបស់ខ្លួន[34]។

ប្រសិនបើមូលហេតុនៃកាលៈទេសៈ បុគ្គលដែលពាក់ព័ន្ធមិនអាចត្រូវនាំ ទៅបង្ហាញខ្លួនដល់ចៅក្រមស៊ើបសួរក្រោយពេលចាប់ខ្លួនបានទេ បុគ្គលនេះត្រូវតែនាំខ្លួនទៅអង្គភាពនគរបាល ឬ កងរាជអាវុធហត្ថ ក្នុងមណ្ឌលឃុំខ្លួន ឬ ទៅក្នុងពន្ធនាគារ។ បុគ្គលនេះ ត្រូវតែនាំខ្លួនទៅបង្ហាញខ្លួនយ៉ាងយូរបំផុតថ្ងៃបន្ទាប់ដល់ចៅក្រមស៊ើបសួរ ឬ ដល់អ្នកជំនួស។ ប្រសិនបើការបង្ហាញខ្លួនមិនបានប្រព្រឹត្តទៅនៅថ្ងៃបន្ទាប់ទេ បុគ្គលពាក់ព័ន្ធត្រូវដោះលែងឲ្យមានសេរីភាពវិញ។ កាលណាបុគ្គលណាម្នាក់ ដែលត្រូវបានចាប់ខ្លួនដោយអនុវត្តតាមដីកាបង្គាប់ឲ្យនាំខ្លួនត្រូវបានឃុំខ្លួននោះថិរវេលានៃការឃុំខ្លួននេះត្រូវបានដាក់បញ្ចូលទៅក្នុងថិរវេលានៃកាឃុំខ្លួនបណ្តោះអាសន្ន ប្រសិនបើមាន។

**គ.ដីកាបង្គាប់ឲ្យចាប់ខ្លួន**

ចៅក្រមស៊ើបសួរអាចចេញដីកាបង្គាប់ខ្លួន [35] ។ដីកាបង្គាប់ឲ្យចាប់ខ្លួនអាចចេញទៅលើជនត្រូវចោទឬ បុគ្គលណាម្នាក់ដែលមានតម្រុយពិរុទ្ធភាព។

ចៅក្រមស៊ើបសួរនឹងអាចចេញដីកាបង្គាប់ឲ្យចាប់ខ្លួនបានលុះត្រាតែះ

១.បទល្មើសដែលចោទប្រកាន់ ជាបទឧក្រិដ្ឋ ឬ បទមជ្ឈិម ដែលត្រូវផ្តន្ទាទោសដាក់ពន្ធពន្ធនាគារ។

២.បុគ្គលដែលពាក់ព័ន្ធបានគេចខ្លួនមិនដឹងជាស្ថិតនៅទីកន្លែងណាឬស្ថិតនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា។

ដីកាបង្គាប់ឲ្យចាប់ខ្លួន គឺជាបញ្ជាះ

- ដល់កងកម្លាំងសាធារណៈឲ្យស្រាវជ្រាវរកចាប់ និងឲ្យនាំខ្លួនបុគ្គលនោះទៅក្នុងពន្ធនាគារ ឬមណ្ឌលឃុំខ្លួនដល់ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួនឲ្យទទួល និងឃុំខ្លួនបុគ្គល[36]។

មុននឹងចេញដីកាបង្គាប់ឲ្យចាប់ខ្លួន ចៅក្រមស៊ើបសួរត្រូវតែទទួល ការយោបល់ព្រះរាជអាជ្ញា។ ចៅក្រមស៊ើបសួរត្រូវចេញដីកានេះដោយមានចែង មូលហេតុក្រោយពីបានទទួលយោបល់ពីព្រះរាជអាជ្ញា។ ព្រះរាជអាជ្ញាត្រូវធានារ៉ាប់រប់ផ្សព្វផ្សាយដីកាបង្គាប់ឲ្យចាប់ខ្លួន។

[33] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧,មាត្រា១៩១

[34] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧,មាត្រា១៩២

[35] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧,មាត្រា១៩៥

[36] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧,មាត្រា១៩៦

ដីកាបង្គាប់ឲ្យចាប់ខ្លួនមាននិទ្ទេសដូចតទៅ៖

- អត្តសញ្ញាណនៃបុគ្គលដែលពាក់ព័ន្ធ
- បទល្មើសដែលចោទប្រកាន់ និងអត្ថបទច្បាប់ដែលកំណត់បង្ក្រាបបទល្មើសនេះ
- ឈ្មោះ និងឋានៈរបស់ចៅក្រមដែលចេញដីកា។

ដីកាបង្គាប់ឲ្យចាប់ខ្លួនត្រូវចុះកាលបរិច្ឆេទ និងចុះហត្ថលេខាដោយចៅក្រមស៊ើបសួរ និងមានបោះត្រាផង[37]។ការអនុវត្តដីកាបង្គាប់ឲ្យចាប់ខ្លួនត្រូវប្រគល់ឲ្យមន្ត្រីនគរបាលយុត្តិធម៌។ ក្នុងករណីបន្ទាន់ដីកាបង្គាប់ឲ្យចាប់ខ្លួនត្រូវផ្សព្វផ្សាយទៅតាមអង្គភាពនគរបាលឬកងរាជអាវុធហត្ថតាមគ្រប់មធ្យោបាយ។ដើមដីកាត្រូវប្រគល់ក្នុងរយៈពេលយ៉ាងខ្លីបំផុតឲ្យដល់មន្ត្រី នគរបាលយុត្តិធម៌ដែលទទួលបន្ទុកអនុវត្តដីកានេះ។ មន្ត្រីនគរបាលយុត្តិធម៌ មិនអាចចូលទៅក្នុងលំនៅខានរបស់បុគ្គលដែលពាក់ព័ន្ធមុនម៉ោង ៦ (ប្រាំមួយ) ព្រឹក និងក្រោយម៉ោង ១៨(ដប់ប្រាំបី) ល្ងាចបានទេ។ មន្ត្រីនគរបាលយុត្តិធម៌ ត្រូវឲ្យជូនដំណឹងដល់ចៅក្រមស៊ើបសួរអំពីការលំបាកទាំងអស់ក្នុងពេលអនុវត្តបេសកកម្មរបស់ខ្លួន [38] ។ក្នុងករណីចាំបាច់ដីកាបង្គាប់ឲ្យចាប់ខ្លួន អាចផ្សព្វផ្សាយជាអន្តរជាតិតាមរយៈក្រសួងយុត្តិធម៌ដោយ ប្រើយន្តការនានាដែលមានប្រសិទ្ធិភាព។ ប្រធានពន្ធនាគារឬ មណ្ឌលឃុំខ្លួនត្រូវតែទទួល និងឃុំខ្លួនជនត្រូវចោទដែលជា កម្មវត្ថុណនៃដីកាបង្គាប់ឲ្យចាប់ខ្លួន។

ប្រធានពន្ធនាគារ ឬ មណ្ឌលឃុំខ្លួនរក្សាទុកដើមដីកា ឬ ចុងដីកា ដែលមានបញ្ជាក់ថាត្រឹមត្រូវតាមច្បាប់ដើម។ បុគ្គលដែលពាក់ព័ន្ធត្រូវតែបានគេនាំទៅបង្ហាញដល់ចៅក្រមស៊ើបសួរ ឬ អ្នកជំនួសចៅក្រមស៊ើបសួរ ក្នុងរយៈពេលយ៉ាងខ្លី ប្រសិនបើស្ថិតក្នុងដំណាក់កាលស៊ើបសួរនៅឡើយ។

ប្រសិនបើការនាំខ្លួនទៅបង្ហាញនេះ តម្រូវឲ្យមានការផ្ទេរបុគ្គលពាក់ព័ន្ធទៅពន្ធនាគារ ឬ ទៅមណ្ឌលឃុំខ្លួនមួយផ្សេងទៀតការផ្ទេរនេះត្រូវចាត់ចែងដោយអយ្យការ។ប្រសិនបើបុគ្គលពាក់ព័ន្ធមិនត្រូវបានគេនាំខ្លួនទៅបង្ហាញដល់ចៅក្រមស៊ើបសួរឬ អ្នកជំនួសចៅក្រមស៊ើបសួរនៅថ្ងៃពីការចាប់ខ្លួនបុគ្គលនេះត្រូវតែបានព្រះរាជអាជ្ញានាទីកន្លែងឃុំខ្លួនស្តាប់ចម្លើយ។ព្រះរាជអាជ្ញានេះធ្វើកំណត់ហេតុស្តីពីការស្តាប់ចម្លើយ ដែលត្រូវបញ្ជូនទៅចៅក្រមស៊ើបសួរ[39]។ កាលណាបុគ្គលណាម្នាក់ដែលត្រូវបានចាប់ខ្លួន ដោយអនុវត្តតាមដីកាបង្គាប់ឲ្យចាប់ខ្លួនត្រូវបានឃុំខ្លួននោះថិរវេលានៃការឃុំខ្លួននេះត្រូវរាប់បញ្ចូលទៅក្នុងថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នប្រសិនបើមាន។

**២.៣.២.សិទ្ធិអំណាចត្រួតពិនិត្យថែរក្សាជនត្រូវចោទ**

**ក.ការឃុំខ្លួនបណ្តោះអាសន្ន**

ជាគោលការណ៍ជនត្រូវចោទត្រូវតែមានសេរីភាព។ក្នុងករណីពិសេសជនត្រូវចោទអាចត្រូវឃុំខ្លួនបណ្តោះអាសន្ន[40] ការឃុំខ្លួនបណ្តោះអាសន្នអាចអនុវត្តបានតែ ក្នុងករណីចោទប្រកាន់ពីបទឧក្រិដ្ឋ ឬបទមជ្ឈឹម ដែលច្បាប់កំណត់ផ្តន្ទាទោសដាក់ពន្ធនាគារ ស្មើ ឬ លើសពី១ (មួយ) ឆ្នាំ។ ការឃុំខ្លួនបណ្តោះអាសន្នអាចត្រូវបានបង្គាប់ កាលណាការឃុំខ្លួនបណ្តោះអាសន្ននេះជាការចាំបាច់៖

- ដើម្បីបញ្ឈប់បទល្មើស ឬបង្ការបទល្មើសកុំឲ្យកើតជាថ្មី

[37] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧,មាត្រា១៩៨

[38] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧,មាត្រា១៩៩

[39] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧,មាត្រា២០១

[40] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧,មាត្រា២០៣

- ដើម្បីរារាំងកុំឲ្យមានការគៀបសង្កត់លើសាក្សី ឬ ជនរងគ្រោះ ឬ ដើម្បីរារាំងកុំឲ្យមានការត្រូវរ៉ូវគ្នារវាងជនត្រូវចោទ និងអ្នកសមគំនិត។
- ដើម្បីរក្សាភស្តុតាង ឬ តម្រុយជាសម្ភារៈ
- ដើម្បីធានារក្សាជនត្រូវចោទទុកជូនតុលាការចាត់ការតាមនីតិវិធី
- ដើម្បីការពារសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ កុំឲ្យមានការច្របូកច្របល់ ដែលបណ្តាលមកពីបទល្មើស[41]។

ចៅក្រមស៊ើបសួរដែលសម្រេចថានឹងត្រូវឃុំខ្លួនបណ្តោះអាសន្ន ដោយគំនិតផ្តើមរបស់ខ្លួនផ្ទាល់ ឬ តាមសេចក្តីសន្និដ្ឋានរបស់ព្រះរាជអាជ្ញា ត្រូវឲ្យដំណឹងដល់ជនត្រូវចោទ និងទទួលការកត់សម្គាល់របស់ជនត្រូវចោទនោះ។ កាលណាជនត្រូវចោទមានមេធាវីនោះ មេធាវីត្រូវបង្ហាញមធ្យោបាយការពារខ្លួន។ ចៅក្រមស៊ើបសួរសម្រេចសួរសម្រេចឃុំខ្លួនជនត្រូវចោទបណ្តោះអាសន្ន តាមដីកា ដោយមានសំអាងហេតុ។ ដីកាបង្គាប់ឃុំខ្លួនបណ្តោះអាសន្ន ត្រូវបានជូនដំណឹងភ្លាមដល់ ព្រះរាជអាជ្ញា និងដល់ជនត្រូវចោទ។

កាលណាចៅក្រមស៊ើបសួរ ដែលទទួលបណ្តឹងតាមសេចក្តីសន្និដ្ឋានរបស់ព្រះរាជអាជ្ញាដែលសុំឲ្យឃុំខ្លួនជនត្រូវចោទបណ្តោះអាសន្ននោះ មិនព្រមធ្វើតាមការសុំឲ្យឃុំខ្លួននោះទេ ចៅក្រមស៊ើបសួរ ត្រូវចេញក្នុងរយៈពេលពេល ៥(ប្រាំ) ថ្ងៃ នូវដីកាសម្រេចមិនឃុំខ្លួនបណ្តោះអាសន្ន ដោយមិនចាំបាច់មានសំអាងហេតុទេ។ ដីកានេះត្រូវជូនដំណឹងជាបន្ទាន់ដល់អ្នកប្តឹងសុំ។ ប្រសិនបើចៅក្រមស៊ើបសួរមិនបានសម្រេចនៅក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ ព្រះរាជអាជ្ញាអាចធ្វើពាក្យប្តឹងទៅសភាស៊ើបសួរ ដែលនឹងសម្រេចជំនួសចៅក្រមស៊ើបសួរ[42]។

ចំពោះនីតិជនដែលត្រូវចោទប្រកាន់ពីបទឧក្រិដ្ឋ ការឃុំខ្លួនបណ្តោះអាសន្ន មិនអាចលើសពី ៦(ប្រាមួយ)ខែ បានទេ។ ប៉ុន្តែនៅពេលផុតចិរវេលានេះ ចៅក្រមស៊ើបសួរអាចពន្យាពេលការឃុំខ្លួនបណ្តោះអាសន្នបានម្តង ៦(ប្រាំមួយ) ខែ ដោយដីកាមានសំអាងហេតុត្រឹមត្រូវនិងច្បាស់លាស់។ ចៅក្រមស៊ើបសួរអាចសម្រេចពន្យារការឃុំខ្លួនបណ្តោះអាសន្នបាន២(ពីរ)ដងគត់[43]។

ចំពោះនីតិជនត្រូវចោទប្រកាន់បទមជ្ឈឹមការឃុំខ្លួនបណ្តោះអាសន្នមិនអាចលើសពី៤(បួន) ខែបានទេ។ ប៉ុន្តែ នៅពេលផុតចិរវេលានេះ ចៅក្រមស៊ើបសួរអាចពន្យារពេលការឃុំខ្លួនបណ្តោះអាសន្នបានតែម្តងគត់មិនឲ្យលើសពី(ពីរ)ខែ ដោយដីកាមានសំអាងហេតុត្រឹមត្រូវនិងច្បាស់លាស់។ចិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នខាងលើនេះ មិនត្រូវលើសពីពាក់កណ្តាលនៃអប្បបរមាណនៃទោសដែលច្បាប់បានកំណត់ឡើយ [44] ។ក្នុងករណីដែលមានការចោទប្រកាន់ពី បទឧក្រិដ្ឋប្រឆាំងមនុស្សជាតិឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឬ បទឧក្រិដ្ឋកម្មសង្គ្រាម ការឃុំខ្លួនមិនអាចលើសពី១(មួយ) ឆ្នាំបានទេចំពោះបទល្មើសនីមួយៗ ។

ប៉ុន្តែនៅពេលផុតចិរវេលានេះចៅក្រមស៊ើបសួរអាចពន្យាពេលការឃុំខ្លួនបណ្តោះអាសន្នម្តងបាន១(មួយ)ឆ្នាំ ដោយដីកាមានសំអាងហេតុត្រឹមត្រូវនិងច្បាស់លាស់។

ចៅក្រមស៊ើបសួរអាចបង្គាប់ឲ្យពន្យារពេលឃុំខ្លួនជាបណ្តោះអាសន្នបាន២(ពីរ)ដងគត់។ កាលណាចៅក្រមស៊ើបសួរសម្រេចថាពន្យារពេលឃុំខ្លួនជាបណ្តោះអាសន្ន ចៅក្រមស៊ើបសួរត្រូវឲ្យដំណឹងដល់ជនត្រូវចោទ និងទទួលការកត់

---

[41] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧,មាត្រា២០៥

[42] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧,មាត្រា២០៧

[43] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧,មាត្រា២០៨

[44] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧,មាត្រា២០៩

សំគាល់របស់ជននេះ។ កាលណាជនត្រូវចោទមានមេធាវីអម នោះមេធាវីត្រូវបង្ហាញមធ្យោបាយការពារខ្លួនកូនក្តីរបស់ខ្លួន។ ចៅក្រមស៊ើបសួរពន្យារការឃុំខ្លួនបណ្តោះអសន្ន តាមដីកាដោយមានសំអាងហេតុ។ ដីកានេះត្រូវឲ្យដំណឹងជាបន្ទាន់ដល់ជនត្រូវចោទ[45]។

អនីតិជនអាយុតិចជាង១៤(ដប់បួន)ឆ្នាំ មិនអាចត្រូវឃុំខ្លួនបណ្តោះអាសន្នទេ។ ចៅក្រមស៊ើបសួរអាចសម្រេចប្រគល់អនីតិជននេះឲ្យឪពុកម្តាយ អ្នកអាណាព្យាបាល ឬ ក្នុងករណីគ្មានអ្នកអាណាព្យាបាល ត្រូវប្រគល់ទៅមណ្ឌលអប់រំថែរក្សាបណ្តោះអាសន្ន រង់ចាំសេចក្តីសម្រេចរបស់តុលាការ[46]។

ចំពោះអនីតិជនអាយុចាប់ពី១៤ (ដប់បួន)ឆ្នាំ ដល់ក្រោម១៨ (ដប់ប្រាំបី) ឆ្នាំ និងត្រូវចោទប្រកាន់ពីបទឧក្រិដ្ឋ ចិរវេលាឃុំខ្លួនបណ្តោះអាសន្នមានដូចតទៅ៖

១.ការឃុំខ្លួនបណ្តោះអាសន្នមិនអាចលើសពី ៤(បួន)ខែបានទេ កាលណាអនីតិជននេះមានអាយុតិចជាង១៦ (ដប់ប្រាំមួយ)ឆ្នាំ។

២.ការឃុំខ្លួនបណ្តោះអាសន្នមិនអាចលើសពី៦(ប្រាំមួយ)ខែបានទេកាលណាអនីតិជននេះមានអាយុចាប់ពី១៦ (ដប់ប្រាំមួយ) ឆ្នាំ ដល់ក្រោម ១៨(ដប់ប្រាំបី)ឆ្នាំ[47]។

ចំពោះអនីតិជនអាយុចាប់ពី ១៤(ដប់បួន) ឆ្នាំ ដល់ក្រោម ១៨(ដប់ប្រាំបី) ឆ្នាំ និងត្រូវចោទប្រកាន់ពីបទមជ្ឈិម ចិរវេលាឃុំខ្លួនបណ្តោះអាសន្នមានដូចតទៅ៖

១.ការឃុំខ្លួនបណ្តោះអាសន្នមិនអាចលើសពី ២(ពីរ) ខែបានទេ កាលណាអនីតិជននេះមានអាយុតិចជាង១៦ (ដប់ប្រាំមួយ)ឆ្នាំ។

២.ការឃុំខ្លួនបណ្តោះអាសន្ន មិនអាចលើសពី ៤(បួន)ខែ បានទេកាលណាអនីតិជននេះមានអាយុចាប់ពី១៦(ដប់ប្រាំមួយ) ឆ្នាំ ដល់ក្រោម ១៨(ដប់ប្រាំបី)ឆ្នាំ។

ចិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នខាងលើនេះមិនត្រូវលើសពីពាក់កណ្តាលនៃអប្បបរមានទោស ដែលច្បាប់បានកំណត់ សម្រាប់អនីតិជននោះឡើយ[48]។ ចៅក្រមស៊ើបសួរអាចបង្គាប់ឲ្យដោះលែងជនត្រូវចោទ ឲ្យនៅក្រៅឃុំវិញបានគ្រប់ពេលវេលា។ កាលណាចៅក្រមស៊ើបសួរមាន បំណងដោះលែងជនត្រូវចោទ ឲ្យនៅក្រៅឃុំនោះ ចៅក្រមស៊ើបសួរត្រូវជូនព័ត៌មានដល់ព្រះរាជអាជ្ញា ដើម្បីសុំយោបល់ហើយបញ្ជូលសំណុំរឿងឲ្យព្រះរាជអាជ្ញាពិនិត្យ។ ព្រះរាជអាជ្ញាត្រូវផ្តល់យោបល់របស់ខ្លួនក្នុងរយៈពេលយ៉ាងខ្លីបំផុត។

ចៅក្រមស៊ើបសួរសម្រេចយ៉ាងយូរបំផុតក្នុងរយៈពេល៥(ប្រាំ)ថ្ងៃបន្ទាប់បីការបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញា។ ក្នុងករណីបន្ទាន់ចៅក្រមស៊ើបសួរ អាចបង្គាប់ឲ្យដោះលែងជនត្រូវចោទភ្លាម ដោយមិនរង់ចាំយោបល់របស់ព្រះរាជអាជ្ញា។ ចៅក្រមស៊ើបសួរត្រូវចង្អុលប្រាប់មូលហេតុសវានាការបន្ទាន់នេះនៅក្នុងដីកាសម្រេចរបស់ខ្លួន។ ព្រះរាជអាជ្ញាអាចសុំឲ្យដោះលែងជនត្រូវចោទបានគ្រប់ពេលវេលា។ ចៅក្រមស៊ើបសួរត្រូវសម្រេចក្នុងរយៈពេល៥(ប្រាំ)ថ្ងៃ។ ប្រសិនបើចៅក្រមស៊ើបសួរមិនបានសម្រេចក្នុងរយៈពេល៥(ប្រាំ)ថ្ងៃទេ ព្រះរាជអាជ្ញាអាចប្តឹងសុំតាមរយៈពាក្យសុំទៅសភាស៊ើបសួរ

[45] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧,មាត្រា២១១

[46] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧,មាត្រា២១២

[47] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧,មាត្រា២០១៣

[48] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧,មាត្រា២១៤

ដែលសម្រេចជំនួសចៅក្រមស៊ើបសួរ។ ដីកាដែលសម្រេចមិនព្រមដោះលែងត្រូវមានសំអាងហេតុ។ជនត្រូវចោទអាចដាក់ពាក្យសុំឲ្យដោះលែងនៅក្រៅឃុំបានគ្រប់ពេលវេលា។

ចៅក្រមស៊ើបសួរបញ្ជូនពាក្យនោះភ្លាម ទៅព្រះរាជអាជ្ញាដើម្បីផ្តល់យោបល់ និងបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញាដើម្បីពិនិត្យ។ ព្រះរាជអាជ្ញាត្រូវផ្តល់យោបល់ក្នុងរយៈពេលខ្លីបំផុត។ ចៅក្រមស៊ើបសួរសម្រេចយ៉ាងយូរបំផុតក្នុងរយៈពេល៥(ប្រាំ)ថ្ងៃ បន្ទាប់ពីពេលបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញា។ ជនត្រូវចោទអាចដាក់ពាក្យសុំនៅក្រៅឃុំសាជាថ្មីម្តងទៀត ទៅចៅក្រមស៊ើបសួរ ឬទៅសភាស៊ើបសួរក្នុងរយៈពេល ១(មួយ) ខែ បន្ទាប់ពីមានសេចក្តីសម្រេចបដិសេធពាក្យសុំលើកមុន។ ចៅក្រមស៊ើបសួរ ឬ សភាស៊ើបសួរ ត្រូវសម្រេចលើពាក្យនេះក្នុងរយៈពេល ៥(ប្រាំ) ថ្ងៃ បន្ទាប់ពីបានទទួលពាក្យសុំ។ ដីកាដែលមិនព្រមដោះលែងឲ្យនៅក្រៅឃុំត្រូវតែមានសំអាងហេតុ។ ប្រសិនបើចៅក្រមស៊ើបសួរមិនបានសម្រេចក្នុងរយៈពេល ៥(ប្រាំ) ថ្ងៃទេ ជនត្រូវចោទអាចធ្វើពាក្យប្តឹងផ្ទាល់ទៅសភាស៊ើបសួរ ដែលសម្រេចជំនួសចៅក្រមស៊ើបសួរ[49]។ ដីកាសម្រេចឲ្យដោះលែងឲ្យនៅក្រៅឃុំត្រូវតែជូនដំណឹងភ្លាមដល់ព្រះរាជអាជ្ញា និងដល់ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួន។ ដីកាមិនព្រមដោះលែងឲ្យនៅក្រៅឃុំត្រូវតែជូនដំណឹងក្នុងរយៈពេលយ៉ាងខ្លីបំផុតរបស់ព្រះរាជអាជ្ញានិងជនត្រូវចោទ។កាលណាចៅក្រមស៊ើបសួរសម្រេចឲ្យដោះលែងជនត្រូវចោទឲ្យនៅក្រៅឃុំចៅក្រមនេះឲ្យនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ។

**ខ.ការត្រួតពិនិត្យតាមផ្លូវតុលាការ**

ចៅក្រមស៊ើបសួរ អាចដាក់ជនត្រូវចោទឲ្យនៅក្រោម ត្រួតពិនិត្យតាមផ្លូវតុលាការ បានគ្រប់ពេលវេលា ប្រសិនបើជនត្រូវចោទនេះត្រូវបានចោទប្រកាន់អំពីបទល្មើស ដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ [50] ។ ការត្រួតពិនិត្យតាមផ្លូវតុលាការ មានអានុភាពបង្គាប់ជនត្រូវចោទដែលនៅក្រៅឃុំឲ្យគោរពកាតព្វកិច្ចមួយ ឬ ច្រើនទៅៈ

១.មិនត្រូវចេញក្រៅព្រំប្រទល់ដែនដីកំណត់ដោយចៅក្រមស៊ើបសួរ

២.មិនត្រូវផ្លាស់ប្តូរលំនៅឋានដោយគ្មានការអនុញ្ញាតពីចៅក្រមស៊ើបសួរ

៣.មិនត្រូវទៅកាន់ទីកន្លែងខ្លះដែលកំណត់ដោយចៅក្រមស៊ើបសួរ

៤.ត្រូវចូលបង្ហាញខ្លួនតាមការកំណត់នៅអង្គភាពនគរបាល ឬ កងរាជអាវុធហត្ថដែលចាត់តាំងដោយចៅក្រមស៊ើបសួរ

៥.ត្រូវឆ្លើយតបនឹងការកោះហៅពីគ្រប់បុគ្គលដែលចាត់តាំងដោយចៅក្រមស៊ើបសួរ

៦.ប្រគល់ជូនដល់ការិយាល័យក្រឡាបញ្ជីគ្រប់ឯកសារបញ្ជាក់អំពីអត្តសញ្ញាណ

៧.មិនត្រូវបើកបររថយន្ត

៨.មិនត្រូវទទួល ឬជួបបុគ្គលមួយចំនួនដែលចង្អុលបង្ហាញដោយចៅក្រមស៊ើបសួរ

៩.ដាក់ប្រាក់ធានាដែលចំនួនប្រាក់ធានា និងថិរវេលាបង់ប្រាក់នេះ ត្រូវបានំណត់ចៅក្រមស៊ើបសួឬដោយផ្អែកទៅលើធនធានរបស់ជនត្រូវចោទ

១០.មិនត្រូវកាន់កាប់ ឬយកតាមខ្លួននូវអាវុធ។ ត្រូវប្រគល់ជូនការិយាល័យក្រឡាបញ្ជីនូវអាវុធដែលជនត្រូវចោទកាន់កាប់

---

[49] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧,មាត្រា២១៧

[50] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧,មាត្រា២២៣

១១.ត្រូវប្រគល់ខ្លួនឲ្យពេទ្យពិនិត្យព្យាបាល និងជាយថាហេតុ ដាក់ឲ្យស្ថិតនៅក្រោមរបបព្យាបាលរោគក្នុងមន្ទីរពេទ្យ

១២.មិនត្រូវធ្វើសកម្មភាពខាងវិជ្ជាជីវៈ

ដើម្បីអនុវត្តចំណុចទី១២ ខាងលើចៅក្រមស៊ើបសួរ មិនអាចហាមឃាត់ការអនុវត្តនូវអាណត្តិបោះឆ្នោត ឬសកម្មភាពខាងសហជីពបានទេ។

អនីតិជនអាយុតិចជាង១៤(ដប់បួន)ឆ្នាំ មិនអាចត្រូវបានដាក់ឲ្យស្ថិតនៅ ក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការបានទេ។នៅក្នុងករណីដែលមានចែងត្រង់ចំណុចទី៦ ទី៩ និងចំណុចទី១០ នៃចំណុចខាងលើនេះជនត្រូវចោទទទួលបង្កាន់ដៃស្ដីពីការប្រគល់ឯកសារអត្តសញ្ញាណ ប្រាប់ធានា ឬអាវុធ។ បង្កាន់ដៃប្រគល់ឯកសារបញ្ជាក់អំពីអត្តសញ្ញាណត្រូវហត្ថលេខាដោយក្រឡាបញ្ជី។

បង្កាន់ដៃប្រគល់ប្រាក់ធានាត្រូវតម្កល់ទុកនៅគណនីពិសេសបើនៅធនាគារ ឬ ត្រូវរក្សាទុកនៅទីកន្លែងមួយ ដែលមានការធានាសន្តិសុខរឹងមាំ។ ទីកន្លែងនេះត្រូវជ្រើសរើសតាមការឯកភាពគ្នាដោយប្រធានតុលាការ និងព្រះរាជអាជ្ញា។ អាវុធត្រូវរក្សានៅទីកន្លែងដូចបានពោលខាងលើ [51] ។ ចៅក្រមស៊ើបសួរដាក់ជនត្រូវចោទឲ្យស៊ើបសួរជនត្រូវចោទឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការតាមគំនិតផ្ដើមផ្ទាល់ខ្លួនឬ តាមសេចក្ដីសន្និដ្ឋានសរុបរបស់ព្រះរាជអាជ្ញា។ ចៅក្រមស៊ើបសួរបញ្ជាក់នៅក្នុងដីកាសម្រេចរបស់ខ្លួន អំពីកាតព្វកិច្ចដែលតម្រូវទៅលើជនត្រូវចោទ។ ដីកាសម្រេចដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការត្រូវជូនដំណឹងក្នុងរយៈពេលខ្លីបំផុតដល់ព្រះរាជអាជ្ញា និងជនត្រូវចោទ។

កាលណាចៅក្រមស៊ើបសួរ ដែលទទួលបណ្ដឹងតាមសេចក្ដីសន្និដ្ឋានពីព្រះរាជអាជ្ញា សុំឲ្យដាក់ខ្លួនជនត្រូវចោទឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ មិនព្រមសម្រេចតាមការសុំទេ ចៅក្រមស៊ើបសួរត្រូវចេញដីកាសម្រេចបដិសេធការសុំនេះក្នុងរយៈពេល៥ (ប្រាំ) ថ្ងៃ។ ដការសម្រេចនេះត្រូវជូនដំណឹងក្នុងរយៈពេលយ៉ាងខ្លីបំផុតដល់ព្រះរាជអាជ្ញា។ ប្រសិនបើចៅក្រមស៊ើបសួរមិនបានសម្រេចក្នុងរយៈពេល៥(ប្រាំ) ថ្ងៃទេ ព្រះរាជអាជ្ញាអាចធ្វើពាក្យប្ដឹងទៅសភាស៊ើបសួរ ដែលសម្រេចជំនួសចៅក្រមស៊ើបសួរ[52]។

ចៅក្រមស៊ើបសួរ អាចកែប្រែខ្លឹមសារនៃកាតព្វកិច្ច អាចលុបចោល ឬបញ្ចូលកាតព្វកិច្ចថ្មីបានគ្រប់ពេលវេលា។ ចៅក្រមស៊ើបសួរក៏អាចបញ្ចប់ការត្រួតពិនិត្យតាមផ្លូវតុលាការបានដែរ។ ចៅក្រមស៊ើបសួរសម្រេចដីកា ដែលត្រូវជូនដំណឹងក្នុងរយៈពេលដ៏ខ្លីបំផុតដល់ព្រះរាជអាជ្ញានិងជនត្រូវចោទ។ ព្រះរាជអាជ្ញាអាចសុំឲ្យលើកលែង ឬ កែប្រែការត្រួតពិនិត្យតាមផ្លូវតុលាការបានគ្រប់ពេល វេលា។ ចៅក្រមស៊ើបសួរត្រូវសម្រេចក្នុងរយៈពេល៥(ប្រាំ)ថ្ងៃ។ ដីកាសម្រេចនេះត្រូវជូនដំណឹងក្នុងរយៈពេលនេះទេ ព្រះរាជអាជ្ញា។

ប្រសិនបើចៅក្រមស៊ើបសួរ ក្នុងរយៈពេលនេះទេព្រះរាជអាជ្ញាអាចធ្វើពាក្យសុំទៅសភាស៊ើបសួរ ដែលសម្រេចជំនួសចៅក្រមស៊ើបសួរ។ ដីកាដែលសម្រេចមិនព្រមធ្វើតាមបណ្ដឹងសុំរបស់ព្រះរាជអាជ្ញា ត្រូវតែមានសំអាងហេតុ។ ជនត្រូវចោទអាចធ្វើសុំពាក្យឲ្យលើកលែង ឬ កែប្រែត្រួតពិនិត្យតាមផ្លូវតុលាការបានគ្រប់ពេលវេលា។ ចៅក្រមស៊ើបសួរបញ្ជូនពាក្យសុំរបស់ព្រះរាជអាជ្ញា ដើម្បីសុំយោបល់និងជូនសំណុំរឿងទៅព្រះរាជអាជ្ញាដើម្បីពិនិត្យ។ ចៅក្រមស៊ើបសួរសម្រេចយ៉ាងយូរបំផុតក្នុងរយៈពេល៥(ប្រាំ)ថ្ងៃ គិតពីថ្ងៃបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញា។

[51] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧,មាត្រា២២៥

[52] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧,មាត្រា២២៦

ដីកាសម្រេចនេះត្រូវជូនដំណឹងក្នុងរយៈពេលខ្លីបំផុតដល់ព្រះរាជអាជ្ញា និងជនត្រូវចោទ។ កាលណាមានពាក្យសុំឲ្យលើកលែង ឬ ឲ្យកែប្រែការត្រួតពិនិត្យតាមផ្លូវតុលាការបានធ្វើជាថ្មី មុនពេលចៅក្រមគិតពីពេលចេញសេចក្តីសម្រេចលើពាក្យសុំពីមុន។ ដីកាដែលសម្រេចមិនព្រមធ្វើតាមពាក្យសុំ ត្រូវតែមានសំអាងហេតុ។ ប្រសិនបើចៅក្រមស៊ើបសួរមិនបានសម្រេចក្នុងរយៈពេល៥(ប្រាំ)ថ្ងៃនេះទេជនត្រូវចោទ អាចធ្វើពាក្យប្តឹងទៅសភាស៊ើបសួរដែល សម្រេចជំនួសចៅក្រមស៊ើបសួរ[53]។

ករណីប្រសិនបើជនត្រូវចោទគេចវេសដោយ ចេតនាពីកាតព្វកិច្ចត្រួតពិនិត្យតាមផ្លូវតុលាការចៅក្រមស៊ើបសួរអាចសម្រេចឲ្យឃុំខ្លួនជនត្រូវចោទបណ្តោះអាសន្នបាន ទោះបីទោសជាប់ពន្ធនាគារ ដែលត្រូវរងនោះមានថិរវេលាប៉ុន្មានក៏ដោយ ហើយទោះជាជនត្រូវចោទត្រូវបានឃុំខ្លួនបណ្តោះអាសន្នអស់រយៈពេលអតិបរមា ដែលមានចែងដោយ មាត្រា ២០៨ ដល់មាត្រា២១០ មាត្រា២១៣ និងមាត្រា២១៤ នៃក្រមនេះក៏ដោយ។ កាលណាចៅក្រមស៊ើបសួរ សម្រេចថានឹងឃុំខ្លួនបណ្តោះអាសន្នដោយមូលហេតុខាងលើនេះ ចៅក្រមស៊ើបសួរ ត្រូវជូនដំណឹងដល់ជនត្រូវចោទនិងទទួលការកត់សម្គាល់របស់ជននោះ។ប្រសិនបើជនត្រូវចោទមានមេធាវីអមនោះ មេធាវីត្រូវមធ្យោបាយការពារកូនក្តីរបស់ខ្លួន។ ចៅក្រមស៊ើបសួរត្រូវជូនដំណឹងភ្លាមដល់ព្រះរាជអាជ្ញា និងដល់ជនត្រូវចោទ។ ការឃុំខ្លួនបណ្តោះអាសន្នដែលសម្រេចនេះ មិនអាចឲ្យលើសពី ៤(បួន) ខែ ចំពោះនីតិជន និង២(ពីរ) ខែចំពោះអនីតិជន[54]។

**កថាខណ្ឌទី៣៖ ការបិទបញ្ចប់នីតិវិធីស៊ើបសួរ**

**៣.១.លំហូរនីតិវិធីបិទបញ្ចប់ការស៊ើបសួរ**

**៣.១.១ដីកាជូនព័ត៌មាននៃការបញ្ចប់ការស៊ើបសួរ**

ដោយអនុលោមទៅតាមមាត្រា ២១៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ ព្រមទាំងរូបមន្តនៃលិខិតជូនព័ត៌មានអំពីការបិទបញ្ចប់ការស៊ើបសួរ យើងឃើញថាសេចក្តីជូនដំណឹងនេះ គឺធ្វើនៅក្រោយពីពេលដែលមានការយល់ឃើញថាការស៊ើបសួរបានបញ្ចប់ពីសំណាក់ចៅក្រមស៊ើបសួរ ហើយគាត់នឹងត្រូវធ្វើនូវលិខិតជូនដំណឹងទៅតំណាងអយ្យការដោយមានបញ្ជាក់អំពីការសម្រេចបញ្ចប់បិទការស៊ើបសួរ។ជាមួយគ្នានេះដែរ ការជូនដំណឹងត្រូវបានធ្វើជូនដោយភាគីដើមបណ្តឹងរដ្ឋប្បវេណី ជនត្រូវចោទ និងមេធាវី ដោយបញ្ជាក់ពីការសម្រេចបិទបញ្ចប់ការស៊ើបសួរលើសពីនេះទៅទៀតចំពោះលិខិតជូនដំណឹងអំពីការបិទបញ្ចប់ការស៊ើបសួរទៅកាន់ភាគីដើមបណ្តឹងរដ្ឋប្បវេណី ជនត្រូវចោទ និងមេធាវី ក៏ត្រូវបានបញ្ជាក់ឲ្យច្បាស់អំពីអ្នកដែលប្រគល់ និងអ្នកដែលទទួលលិខិតជូនដំណឹងដោយមានការចុះហត្ថលេខា និងស្នាមមេដៃផងដែរ។

ការបញ្ជូនរឿងឲ្យព្រះរាជអាជ្ញាត្រួតពិនិត្យ ដាច់ខាតត្រូវធ្វើឡើងនៅក្នុងដំណាក់កាល បិទបញ្ចប់នៃនីតិវិធីស៊ើបសួររបស់ចៅក្រមស៊ើបសួរ ប៉ុន្តែនីតិវិធីនៃការបញ្ជូនរឿងឲ្យ ព្រះរាជអាជ្ញាត្រួតពិនិត្យនេះអាចធ្វើឡើងគ្រប់ពេលវេលា នៅពេលដែលព្រះរាជអាជ្ញាស្នើឲ្យបញ្ជូនរឿងឲ្យពិនិត្យ។ ក្នុងករណីនេះ ព្រះរាជអាជ្ញាត្រូវបង្វិលសំណុំរឿងនេះ ឲ្យទៅចៅក្រមស៊ើបសួរវិញក្នុងរយៈពេល ២៤(ម្ភៃបួន)ម៉ោង។ ហេតុដូច្នេះ នៅក្នុងដំណាក់កាលបិទបញ្ចប់ការស៊ើបសួរ នៅពេលក្រោយពីបានរយៈពេល២(ពីរ)ថ្ងៃ ក្រោយចៅក្រមស៊ើបសួរបានជូនដំណឹងទៅព្រះរាជអាជ្ញាព្រមទាំងអស់ ចៅក្រមស៊ើបសួរត្រូវបញ្ជូនសំណុំរឿងឲ្យពិនិត្យ ជាមួយគ្នានេះដែរ គាត់ត្រូវភ្ជាប់នូវសំណុំរឿងទាំងមូលដែលនៅក្នុងនោះក៏មាន៖

- សេចក្តីថ្លែងអំពីអង្គហេតុ

[53] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧,មាត្រា២២៩

[54] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧,មាត្រា២៣០

- ប្រវត្តិរូបនៃបុគ្គលដែលពាក់ព័ន្ធនឹងបទល្មើសដែលត្រូវបានចោទប្រកាន់
- ចម្លើយដែលបានពីបុគ្គលផ្សេងៗ
  - ដើមបណ្តឹងរដ្ឋប្បវេណី ឬមេធាវី
  - ចម្លើយរបស់សាក្សីដាក់បន្ទុក និងដោះបន្ទុក និងសាក្សីតាមឆន្ទានុសិទ្ធិរបស់តុលាការ
  - ចម្លើយរបស់ជនត្រូវចោទ
- ឯកសារពាក់ព័ន្ធនានា ព្រមទាំងវត្ថុតាងផ្សេងទៀត

#### ៣.១.២ដីកាសន្និដ្ឋានស្ថាពរ

ដីកាសន្និដ្ឋានស្ថាពរត្រូវបានចេញដោយព្រះរាជអាជ្ញាដីកានេះមានរយៈពេល១៥(ដប់ប្រាំ) ប្រសិនបើជនត្រូវចោទត្រូវឃុំខ្លួន និង៣០(សាមសិប)ថ្ងៃ នៅក្នុងករណីដែលជនត្រូវចោទស្ថិតនៅក្រៅឃុំ។ ម្យ៉ាងវិញទៀត មុនពេលដែលព្រះរាជអាជ្ញាចេញដីកាសន្និដ្ឋានស្ថាពរនេះកាលណាបើការយល់ឃើញថាការស៊ើបសួរពុំទាន់មានលក្ខណៈគ្រប់គ្រាន់ ឬ ប្រសិនបើព្រះរាជអាជ្ញាយល់ឃើញថា ការស៊ើបសួរបន្ថែមធ្វើឲ្យមានប្រយោជន៍នោះ ព្រះរាជអាជ្ញាអាចស្នើឲ្យមានប្រយោជន៍នោះ ព្រះរាជអាជ្ញាអាចស្នើឲ្យចៅក្រមសួរបំពេញកិច្ចបន្ថែម។ ម្យ៉ាងវិញទៀត ប្រសិនបើព្រះរាជអាជ្ញាយល់ឃើញដូចចៅក្រមស៊ើបសួរគាត់ ត្រូវចេញដីកាសន្និដ្ឋានស្ថាពរជាលាយលក្ខណ៍អក្សរ និងដោយមានសំអាងហេតុដោយដីកានោះ គាត់អាចប្តឹងចៅក្រមស៊ើបសួរដោយបញ្ជូនរឿងទៅជំនុំជម្រះ ឬលើកលែងការចោទប្រកាន់[55]។

នៅពីក្រោយពីបានទទួលដីកាសន្និដ្ឋានស្ថាពររបស់ព្រះរាជអាជ្ញា ដោយមានការប្តឹងឲ្យចៅក្រមស៊ើបសួរ បញ្ជូនរឿងទៅជំនុំជម្រះ ឬ លើកលែងចោទប្រកាន់ក៏ដោយ ចៅក្រមស៊ើបសួរមានសិទ្ធិអំណាចឯករាជ្យ មានន័យថាដីកាសន្និដ្ឋានស្ថាពរនេះពុំមានអំណាចចាប់ចងកាតព្វកិច្ចចៅក្រមស៊ើបសួរត្រូវតែអនុវត្តតាមការប្តឹងពីតំណាងអយ្យការនោះឡើយ។ ផ្ទុយទៅវិញច្បាប់បានបើកផ្លូវឲ្យមាន ការប្តឹងឧទ្ធរណ៍ទៅកាន់សភាស៊ើបសួរ នៃសាលាឧទ្ធរណ៍ ដោយតំណាងអយ្យការដើម្បីប្រឆាំងនឹងសេចក្តីសម្រេចរបស់ចៅក្រមស៊ើបសួរ ដែលផ្ទុយពីឆន្ទៈរបស់ព្រះរាជអាជ្ញា។

### ៣.២.ដីកាដំណោះស្រាយ

#### ៣.២.១.ដីកាលើកលែងការចោទប្រកាន់

នៅពេលដែលចៅក្រមស៊ើបសួរចេញសេចក្តីសម្រេច ចៅក្រមស៊ើបសួរត្រូវផ្អែកទៅលើមូលហេតុមួយចំនួនដូចជា៖

- អំពើប្រព្រឹត្តមិនមែនជាបទល្មើសឧក្រិដ្ឋ បទមជ្ឈិម ឬ បទលហុ
- ជនដែលប្រព្រឹត្តអំពើនោះនៅតែមិនស្គាល់
- គ្មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់ទៅលើជនត្រូវចោទ[56]។

គ្មានការលើកលែងការចោទប្រកាន់ អាចទាំងស្រុង ឬមួយផ្នែក គឺទាក់ទងទៅនឹងអំពើទាំងអស់ដែលដាក់ឲ្យពិនិត្យទៅលើបុគ្គល ឬ ទាក់ទងត្រឹមតែមួយផ្នែកនៃអំពើនេះ។ ដីកាលើកលែងការចោទប្រកាន់ ដកសមត្ថកិច្ចរបស់ចៅក្រមស៊ើបសួរខ្លួនឯងពីសំណុំរឿង និងបញ្ចប់ការត្រួតពិនិត្យតាមផ្លូវតុលាការ និងការឃុំខ្លួនបណ្តោះអាសន្ន។ កាលណាចៅក្រមស៊ើបសួរ សម្រេចដោះលែងជនត្រូវចោទដែលជាប់ឃុំបណ្តោះអាសន្ន ជនត្រូវចោទនោះត្រូវបានរក្សាទុកនៅក្នុងពន្ធនាគាររហូតដល់ផុតរយៈពេលសម្រាប់បណ្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញា លើកលែងតែព្រះរាជអាជ្ញាយល់ព្រមឲ្យដោះលែងជនត្រូវចោទភ្លាមៗ។

---

[55] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧,មាត្រា២៤៦

[56] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧,មាត្រា២៤៧

ប្រសិនបើព្រះរាជអាជ្ញាប្តឹងឧទ្ធរណ៍ ពីដីកាលើកលែងចោទ ប្រកាន់របស់ចៅក្រមស៊ើបសួរនោះ ជនត្រូវចោទដែលជាប់ឃុំត្រូវរក្សានៅក្នុងពន្ធនាគាររហូតដល់ពេលដែលសភាស៊ើបសួរសម្រេចអំពីបណ្តឹងឧទ្ធរណ៍នេះ។ កាលណា សភាស៊ើបសួរប្រគល់ភារកិច្ចទៅសមាជិករបស់ខ្លួនម្នាក់ ដែលប្រើប្រាស់អំណាចជាចៅក្រមស៊ើបសួរ លើកលែងតែមានអំណាចដែលមានចែងនៅក្នុងជំពូកទី៥ ស្តីពីការបិទការស៊ើបសួរនៃមាតិកាទី១ ស្តីពីចៅក្រមស៊ើបសួរក្នុងគន្តីនេះ។ កាលណា ការស៊ើបសួរហាក់ដូចជាត្រូវបានបញ្ចប់ សំណុំរឿងនៃនីតិវិធីត្រូវតម្កល់ទុកនៅការិយាល័យក្រឡាបញ្ជីនៃសភាស៊ើបសួរ។ ប្រធាននៃសភាស៊ើបសួរ កំណត់កាលបរិច្ឆេទនៃសវនាការ។ សភាស៊ើបសួរ បិទការស៊ើបសួរ តាមសាលដីកាដំណោះស្រាយ។ ក្នុងករណីដែលសភាស៊ើបសួរ សម្រេចដោះលែងជនត្រូវចោទដែលជាប់ឃុំ សេចក្តីសម្រេចត្រូវមានអានុភាពអនុវត្តភ្លាមៗ។ ដើមបណ្តឹងរដ្ឋប្បវេណីអាចធ្វើបណ្តឹងឧទ្ធរណ៍ពីដីកាលើកលែងចោតប្រកាន់ និងដីកានានាមួយចំនួនទៀតរបស់ចៅក្រមស៊ើបសួរ។ ចំណែកឯភាគីតំណាងអយ្យការ(ព្រះរាជអាជ្ញា ឬ អគ្គព្រះរាជអាជ្ញា) មានអំណាចធ្វើបណ្តឹងឧទ្ធរណ៍ពីគ្រប់ដីកាចៅក្រមស៊ើបសួរ។ ក្រោយពេលដែលដីកាលើកលែងចោទប្រកាន់របស់ចៅក្រមស៊ើបសួរ ឬសាលដីកាលើកលែងចោទប្រកាន់របស់ភាគីស៊ើបសួរបានចូលជាស្ថាពរ ប្រសិនបើលេចចេញនូវបន្ទុកថ្មីឡើងការស៊ើបសួរអាចបើកឡើងវិញតាមដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់តំណាងអយ្យការ។

**៣.២.២.ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះ**

នៅពេលដែលចៅក្រមស៊ើបសួរយល់ឃើញថា មានបន្ទុកគ្រប់គ្រាន់អំពីអំពើល្មើសជាបទឧក្រិដ្ឋបទមជ្ឈឹម ឬបទលហុ ចៅក្រមស៊ើបសួរចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះនៅសវនាការ [57]។ដីកាបញ្ជូនទៅជំនុំជម្រះ ក៏ដូចជាដីកាលើកលែងការចោទប្រកាន់ដែរ ដោយដកសមត្ថកិច្ចរបស់ចៅក្រមស៊ើបសួរ ទៅឲ្យតុលាការដែលសំណុំរឿងត្រូវបានបញ្ជូនទៅចៅក្រមជំនុំជម្រះដើម្បីជំនុំជម្រះ។ ដីកានេះបញ្ចប់ការត្រួតពិនិត្យតាមផ្លូវតុលាការ និងការឃុំខ្លួនបណ្តោះអាសន្ន។ ប៉ុន្តែយោងតាមសេចក្តីសម្រេចដោយឡែកនៃដីកាដំណោះស្រាយ និងក្រោមក្របខណ្ឌមួយចំនួនចៅក្រមស៊ើបសួរ អាចសម្រេចរក្សាជនត្រូវចោទឲ្យ នៅជាប់ឃុំរហូតដល់ពេលចូលបង្ហាញខ្លួននៅចំពោះមុខចៅក្រមជំនុំជម្រះ។

ក្នុងករណីនេះចៅក្រមស៊ើបសួរត្រូវនៅសំអាងហេតុទៅលើសេចក្តីសម្រេចរក្សាទុកជនត្រូវចោទឲ្យនៅក្នុងឃុំដោយមានមូលហេតុណាមួយក្នុងចំណោមមូលហេតុ ទាំងអស់ដូចជាដើម្បីបញ្ចប់បទល្មើស ឬដើម្បីបង្ការ និងទប់ស្កាត់បទល្មើសកើតជាថ្មី រារាំងកុំឲ្យមានការគាបសង្កត់លើសាក្សី ឬជនរងគ្រោះ ឬរារាំងកុំឲ្យមានការត្រូវរ៉ូវគ្នារវាងជាជនត្រូវចោទ និងអ្នកសមគំនិតដើម្បីធានារក្សាជនត្រូវចោទទុកជូនតុលាការចាត់ការ តាមនីតិវិធីដើម្បីការពារជនត្រូវចោទដើម្បីការពារជនត្រូវចោទដើម្បីរក្សាសណ្តាប់ធ្នាប់សាធារណៈកុំឲ្យមានការច្របូកច្របល់ដែលបណ្តាលមកពីបទល្មើស។

សេចក្តីសម្រេចរក្សាជន ត្រូវចោទក្នុងការឃុំបណ្តោះអាសន្ននេះ លែងមានអានុភាពក្នុងរយៈពេល ៤(បួន)ខែ ប្រសិនបើជនត្រូវចោទមិនត្រូវបាននាំចូលបង្ហាញខ្លួននៅចំពោះមុខចៅក្រមជំនុំជម្រះក្នុងរយៈពេល៤(បួន)ខែ នោះទេ ជនត្រូវចោទត្រូវបានដោះលែងឲ្យនៅក្រៅឃុំដោយឯកឯង។ប្រសិនបើ ចៅក្រមស៊ើបសួរ សម្រេចចេញដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះចៅក្រមស៊ើបសួរឬបញ្ជូនសំណុំរឿងជាបន្ទាន់ទៅប្រធានតុលាការ ដើម្បីកំណត់ពេលនៅក្នុងការបើកសវនាការជំនុំជម្រះ។

[57] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧,មាត្រា២៤៧

# ជំពូកទី២

# សភាសេរីបស្សរនៃសាលាឧទ្ទរណ៍

# ជំពូកទី ២
# សភាស៊ើបសួរនៃសាលាឧទ្ធរណ៍

## ផ្នែកទី១៖ សញ្ញាណនៃសភាស៊ើបសួរ

### កថាខណ្ឌទី១៖ តួនាទីនៃសភាពិសេសនៃសាលាឧទ្ធរណ៍

#### ១.១.ការកិច្ចរដ្ឋបាលនៃសភាស៊ើបសួរ

សាលាឧទ្ធរណ៍មានសភាពិសេសមួយដែលមានឈ្មោះ ថាសភាស៊ើបសួរដែលសភានេះ មានសមត្ថកិច្ចជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ដែលធ្វើឡើងប្រឆាំង នឹងសេចក្តីសម្រេចរបស់ចៅក្រមស៊ើបសួរ[58]។ សមាជិកនៅសភាស៊ើបសួរពុំអាចចូលរួមក្នុងការជំនុំជម្រះរឿងក្តីព្រហ្មទណ្ឌដែលខ្លួនបានចាត់ការឋានៈចៅក្រមស៊ើបសួរបានទេបើ មិនដូច្នេះទេសាលដីកានោះត្រូវចាត់ទុកជាមោឃៈ។ ផ្សារភ្ជាប់នៃកិច្ចដំណើរការប្រព្រឹត្តទៅបានល្អ របស់កិច្ចនីតិវិធីស៊ើបសួររបស់មន្ទីរស៊ើបសួរព្រមទាំងសភាស៊ើបសួរខ្លួនឯងផង ច្បាប់បានអនុញ្ញាតផ្តល់អំណាចឲ្យប្រធានសភាស៊ើបសួរនៃ សាលាឧទ្ធរណ៍មានអំណាចធ្វើគ្រប់អធិការកិច្ចនៃមន្ទីរស៊ើបសួរដោយផ្ទៀងផ្ទាត់មើលជាអាទិ៍លក្ខខណ្ឌនៃការអនុវត្តបទប្បញ្ញត្តិស្តីពីការឃុំខ្លួនបណ្តោះអាសន្ន ដីកាតុលាការផ្សេងៗ ដីកាចាត់ឲ្យស៊ើបសួរ និងកោសល្យវិច័យ។

ជាមួយគ្នានេះដែរ បើពិនិត្យមើលលើទំនាក់ទំនងរវាងសភាស៊ើបសួរ និងភាគី ក្នុងនោះរួមមានជនត្រូវចោទនិងដើមបណ្តឹងរដ្ឋប្បវេណីលើផ្នែករដ្ឋបាល គូភាគីអាចធ្វើការប្តឹងសុំឲ្យបិទសំណុំរឿង។ កាលណានៅពេលផុតចិរវេលា១(មួយ)ឆ្នាំ គិតពីថ្ងៃទទួលពាក្យសុំនេះ ចៅក្រមស៊ើបសួរត្រូវតែសម្រេច។ ប្រសិនបើចៅក្រមស៊ើបសួរមិនសម្រេចនៅក្នុងរយៈពេលនោះទេ ជនត្រូវចោទអាចប្តឹងទៅប្រធានសភាស៊ើបសួរ ដែលធ្វើអធិបញ្ញាសល់ពីចៅក្រមស៊ើបសួរឲ្យ សម្រេចជំនួសចៅក្រមស៊ើបសួរ។

លុះផុតចិរវេលា ១(មួយ) ឆ្នាំ គិតពីថ្ងៃតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដើមបណ្តឹងរដ្ឋប្បវេណីអាចសុំឲ្យចៅក្រមស៊ើបសួរបិទការស៊ើបសួរ។ ក្នុងរយៈពេល១(មួយ)ខែ គិតពីថ្ងៃទទួលពាក្យប្តឹងចៅក្រមស៊ើបសួរត្រូវតែសម្រេច។ អំណាចដែលទទួលស្គាល់ដោយក្រមនីតិវិធីរដ្ឋប្បវេណីអាចប្រើប្រាស់បានដោយមេធាវី[59]។

ប្រធានសភាស៊ើបសួរពិនិត្យផ្ទៀងផ្ទាត់មើលថា តើសំណុំមានលក្ខណៈគ្រប់គ្រាន់ល្មម ជំនុំជម្រះបានឬទេ រួចហើយកំណត់កាលបរិច្ឆេទបើកសវនាការ។ ប្រធានសភាស៊ើបសួរជូនដំណឹងដោយផ្ទាល់មាត់អំពីកាលបរិច្ឆេទនៃការបើកសវនាការ ដល់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍។ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ជូនដំណឹងអំពីការបរិច្ឆេទនៃសវនាការនេះ ដល់គូភាគី និងដល់មេធាវី។

ការជូនដំណឹងដល់ជនត្រូវចោទដែលត្រូវបានឃុំខ្លួនត្រូវធ្វើដូចតទៅនេះ៖

- ដោយផ្ទាល់មាត់
- តាមរយៈប្រធានពន្ធនាគារ ឬ មណ្ឌលឃុំខ្លួន
- ការជូនដំណឹងដល់ជនត្រូវចោទនៅក្រៅឃុំ ដល់ដើមបណ្តឹងរដ្ឋប្បវេណី និងដល់មេធាវីត្រូវធ្វើដូចតទៅ៖
- ដោយផ្ទាល់មាត់ ឬ
- តាមផ្លូវរដ្ឋបាល ឬ
- តាមរយៈអង្គភាពនគរបាលកងរាជអាវុធហត្ថ

---

[58] ច្បាប់ស្តីពីការរៀបចំអង្គតុលាការ ឆ្នាំ២០១៤,មាត្រា ៤៥

[59] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧,មាត្រា២៨៦

កាលណាការជូនដំណឹងធ្វើឡើងដោយផ្ទាល់មាត់ ក្រឡាបញ្ជីត្រូវចុះនិទ្ទេសអំពីការបរិច្ឆេទ នៃការជូនដំណឹងនៅទំព័រនៃដីកា។ ជនត្រូវចោទ ដើមបណ្តឹងរដ្ឋប្បវេណី ឬមេធាវីចុះហត្ថលេខារបស់ខ្លួន។ ក្នុងករណីដទៃទៀត ការជូនដំណឹងត្រូវធ្វើដោយការប្រគល់សេចក្តីចម្លងដីកា ដោយមានចំណារទទួល[60]។

**១.២.ការត្រួតពិនិត្យនិយ័តភាពនៃកិច្ចស៊ើបសួររបស់មន្ទីរស៊ើបសួរ**

ភាពដែលមិនអាចយក នៃពាក្យប្តឹងសុំមោឃកម្ម គឺសភាស៊ើបសួរអាចប្រកាសមិនទទួលពាក្យប្តឹងសុំឲ្យមោឃកម្មនៅក្នុងករណីដូចតទៅ៖

– ពាក្យប្តឹងសុំគ្មានសំអាងហេតុ
– ពាក្យសុំទាក់ទងនឹងដីកាដែលអាចប្តឹងឧទ្ធរណ៍បាន
– ពាក្យប្តឹងគ្មានមូលកភាពយ៉ាងជាក់ស្តែង។

សេចក្តីសម្រេចរបស់ សភាស៊ើបសួរមិនអាចតវ៉ាបានទេ។ កាលណាពាក្យប្តឹងសុំត្រូវបានប្រកាស មិនអាចទទួលបានទេ សំណុំរឿងត្រូវបង្វិលភ្លាមទៅចៅក្រមស៊ើបសួរ[61]។

នៅគ្រប់ពេលវេលា ដែលសភាស៊ើបសួរបានទទួលបណ្តឹងសុំឲ្យ ពិនិត្យពីនិយ័តភាពនៃកិច្ចនីតិវិធី និងការប្រព្រឹត្តទៅដ៏ល្អនៃនីតិវិធីហើយនៅក្រោយពីបានពិនិត្យឃើញអំពីមូលហេតុនៃមោឃភាព សភាស៊ើបសួរអាចចាត់ទុកថាមោឃៈឯកឯង នូវនីតិវិធីទាំងមូល ឬផ្នែកណាមួយ។ នីតិវិធីនៃមោឃភាពបែបនេះត្រូវធ្វើឡើងដោយ៖

– កាលណាបានទទួលបណ្តឹងសុំមោឃកម្ម ចំពោះកិច្ច ឬ លិខិតណាមួយនៃនីតិវិធី ប្រសិនបើសភាស៊ើបសួរយល់ព្រមពាក្យប្តឹងនេះ សភាស៊ើបសួរសម្រេចថា តើមោឃកម្មនេះត្រូវធ្វើទៅលើកិច្ច ឬ លិខិតផ្សេងទៀតដែរឬទេ។
– កិច្ច ឬ លិខិតដែលត្រូវចាត់ទុកជាមោឃៈត្រូវដកចេញពីសំណុំរឿង ហើយតម្កល់ទុកនៅការិយាល័យក្រឡាបញ្ជីនៃសភាស៊ើបសួរ។

មោឃភាពក៏អាចត្រូវបានធ្វើផងដែរ នៅក្នុងករណីដែលមិនគោរពវិធានបញ្ញត្តិមួយចំនួនដូចខាងក្រោម៖

- ការរំលោភលើដែនសមត្ថកិច្ចរបស់ចៅក្រមដែលមានសមត្ថកិច្ចគឺ៖
- ចៅក្រមស៊ើបសួរនាទីកន្លែងបទល្មើស
- ចៅក្រមស៊ើបសួរនាទីលំនៅឋាន ឬ ទីសំណាក់របស់បុគ្គលដែលសង្ស័យថាបានប្រព្រឹត្តបទល្មើស
- ចៅក្រមស៊ើបសួរនាទីកន្លែងចាប់ខ្លួនបុគ្គលដែលសង្ស័យថាបានប្រព្រឹត្តបទល្មើស

ក្នុងករណី ដែលមានទំនាស់រវាងចៅក្រមស៊ើបសួរច្រើនរូប នៅសាលាដំបូងខុសគ្នា ហើយទទួលបណ្តឹងទាំងអស់គ្នាអំពីរឿងព្រហ្មទណ្ឌតែមួយដូចគ្នា

ទំនាស់នេះត្រូវបញ្ជូនទៅប្រធានសភាស៊ើបសួរ។ វិវាទសមត្ថកិច្ចដែនដីរវាងសភាស៊ើបសួរច្រើន ត្រូវសម្រេចដោយប្រធានតុលាការកំពូល(ការសម្រេចបិទផ្លូវតវ៉ា)។

- ការបើកការស៊ើបសួរដោយ ចៅក្រមស៊ើបសួរពុំមានការ ស្នើបំពេញកិច្ចស៊ើបសួរណា មួយដោយគ្មានដីកាសន្និដ្ឋានបញ្ជូនរឿង ឲ្យស៊ើបសួររបស់ព្រះរាជអាជ្ញា ឬការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីបាននោះឡើយ។

[60] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧,មាត្រា២៥៨

[61] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧,មាត្រា២៧៩

- វិសាលភាពនៃបណ្តឹង ក៏មានឥទ្ធិពលមួយផងដែរ ដែលវាតម្រូវឲ្យចៅក្រមស៊ើបសួរទទួលបណ្តឹងអំពីអង្គហេតុ ដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់ព្រះរាជអាជ្ញា។ ចៅក្រមស៊ើបសួរ ត្រូវតែស៊ើបសួរអំពីអង្គហេតុនោះប៉ុណ្ណោះ។ ប្រសិនបើមានលេចអង្គហេតុថ្មី ដែលអាចជាបទល្មើសព្រហ្មទណ្ឌនៅក្នុងពេលស៊ើបសួរ ចៅក្រមស៊ើបសួរត្រូវជូនព័ត៌មានអំពីអង្គហេតុនេះទៅព្រះរាជអាជ្ញា។ ព្រះរាជអាជ្ញាអាចប្តឹងសុំឲ្យស៊ើបសួរបន្ថែមបើគ្មានដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមទេ ចៅក្រមស៊ើបសួរគ្មានអំណាចស៊ើបសួរអំពីអង្គហេតុថ្មីនោះឡើយ។
- ចៅក្រមស៊ើបសួរត្រូវមានក្រឡាបញ្ជីម្នាក់អមជានិច្ច។ ក្នុងករណីណាក៏ដោយ ក្រឡាបញ្ជីមិនអាចបំពេញកិច្ចដែលជាសមត្ថកិច្ចរបស់ចៅក្រមស៊ើបសួរបានទេ។
- នាំឲ្យមានមោឃភាពផងដែរ កាលណាការបំពានវិធាន ឬទម្រង់ការសំខាន់ណាមួយដែលចែងដោយក្រមនេះ ឬបទប្បញ្ញត្តិទាំងឡាយស្តីពីនីតិវិធីព្រហ្មទណ្ឌធ្វើឲ្យប៉ះពាល់ដល់ផលប្រយោជន៍របស់ភាគីដែលទទួលរងបំពាននេះ។ វិធាន និងទម្រង់ការដែលមានលក្ខណៈ សំខាន់នោះមានជាអាទិ៍ វិធានទម្រង់ការដែលមានបំណងធានាការគោរពសិទ្ធិមនុស្សការពារខ្លួន។

កាលណាបានទទួលបណ្តឹងសុំមោឃកម្មចំពោះកិច្ច ឬ លិខិតណាមួយនៃនីតិវិធី ប្រសិនបើសភាស៊ើបសួរ យល់ព្រមតាមពាក្យប្តឹងសុំនេះ សភាស៊ើបសួរសម្រេចថា តើមោឃកម្មនេះត្រូវធ្វើលើកិច្ច ឬលិខិតផ្សេងទៀតដែរឬទេ។

កិច្ច ឬ លិខិតដែលត្រូវចាត់ទុកជាមោឃៈ ត្រូវដកចេញពីសំណុំរឿង ហើយតម្កល់ទុកនៅ ការិយាល័យក្រឡាបញ្ជីនៃសភាស៊ើបសួរ។ ជាផលវិបាកមួយចំនួនក្រោយបីបានធ្វើមោឃកម្មរួចសភាស៊ើបសួរអាចៈ

- បង្វិលសំណុំរឿងទៅឲ្យចៅក្រមស៊ើបសួរវិញ
- ដកសមត្ថកិច្ចរបស់ចៅក្រមស៊ើបសួរ ហើយបញ្ជូនសំណុំរឿងឲ្យទៅចៅក្រមស៊ើបសួរម្នាក់ទៀត ឬបន្តការស៊ើបសួរដោយខ្លួនឯងលើរឿងនេះ[62]។

កាលណា សភាស៊ើបសួរ សម្រេចថាបន្តការស៊ើបសួរដោយខ្លួនឯងនោះ សភាស៊ើបសួរប្រគល់ភារកិច្ច ទៅឲ្យសមាជិកខ្លួនម្នាក់ដែលប្រើសប្រាស់អំណាចចៅក្រមស៊ើបសួរ លើកលែងតែអំណាចផ្ទាល់របស់ប្រធានសភាស៊ើបសួរ។

កាលណាស៊ើបសួរហាក់ដូចជាត្រូវបញ្ចប់ សំណុំរឿងនៃនីតិវិធីត្រូវតម្កល់ទុកនៅការិយាល័យក្រឡាបញ្ជីនៃសភាស៊ើបសួរ។ ប្រធាននៃសភាស៊ើបសួរ កំណត់កាលបរិច្ឆេទនៃសវនាការ។ ក្នុងករណី សភាស៊ើបសួរសម្រេចដោះលែងជនត្រូវចោទដែលជាប់ឃុំ សេចក្តីសម្រេចនោះត្រូវមានអានុភាពអនុវត្តភ្លាមៗ។សភាស៊ើបសួរ បិទការស៊ើបសួរតាមសាលដីកាដំណោះស្រាយដែល ក្នុងនោះមានការលើកលែងចោទប្រកាន់ ឬ សាលដីកាបញ្ជូនរឿងទៅជំនុំជម្រះ។

ប្រធានសភាស៊ើបសួរ ជាអ្នកពិនិត្យទៅលើបណ្តឹងឧទ្ធរណ៍ដែលប្រឆាំងនឹង សេចក្តីសម្រេចរបស់ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីខេត្ត។ នៅក្នុងការត្រួតពិនិត្យលើបណ្តឹងនេះ ប្រសិនបើប្រធានសភាស៊ើបសួរយល់ឃើញថាបណ្តឹងណាដែលស្របទៅតាមនីតិវិធី ឬ សំណុំរឿងនោះមានលក្ខណៈគ្រប់គ្រាន់ល្មមក្នុងការជំនុំជម្រះបាន បណ្តឹងនោះត្រូវបានចាត់ទុកថាបានការដោយប្រធានសភាស៊ើបសួរកំណត់ថ្ងៃ កាលបរិច្ឆេទក្នុងការបើកសវនាការ។

### កថាខណ្ឌទី២៖ អំណាចរបស់សភាស៊ើបសួរ

#### ២.១.អំណាចយុត្តាធិការនៃសភាស៊ើបសួរ

[62] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧,មាត្រា២៨១

ទោះបីជាច្បាប់បានកំណត់ថាបុគ្គលគ្រប់រូបអាចប្តឹងឧទ្ធរណ៍ទៅសភាស៊ើបសួរចំពោះសេចក្តីសម្រេចរបស់ចៅក្រមស៊ើបសួរដូចគ្នាក៏ពិតមែន តែរយៈពេល និងទំហំនៃការប្តឹងនោះមិនដូចគ្នាទេ គឺវាអាស្រ័យទៅលើបុគ្គលដែលជាអ្នកប្តឹង។

អគ្គព្រះរាជអាជ្ញាមានថិរវេលាមួយ ខែ គិតពីថ្ងៃប្រកាសដីកា ដើម្បីប្តឹងឧទ្ធរណ៍ ចំពោះសេចក្តីសម្រេចរបស់ចៅក្រមស៊ើបសួរ ចំណែកព្រះរាជអាជ្ញា ឬ ជនត្រូវចោទ ឬ ដើមបណ្តឹងរដ្ឋប្បវេណីមានថិរវេលានៃការប្តឹងឧទ្ធរណ៍ គឺមានរយៈពេល ៥(ប្រាំ) ថ្ងៃ យ៉ាងយូរគិតពីថ្ងៃប្រកាសអំពីដីកា[63]។

បែបបទនៃការជូនដំណឹងទៅភាគី អំពីការបរិច្ឆេទនៃសវនាការមានចែងក្នុងមាត្រា២៦៧ ក្រមនីតិវិធីព្រហ្មទណ្ឌ។ រីឯសវនាការចំពោះមុខសភាស៊ើបសួរ ត្រូវប្រព្រឹត្តទៅក្នុងបន្ទប់សំងាត់មាននំយថា ពុំមានវត្តមានសាធារណជនហើយ និងចេញសាលដីកា ក៏ត្រូវប្រកាសនៅពេលសវនាការអសាធារណៈ។ ក្នុងសវនាការនេះ អគ្គព្រះរាជអាជ្ញា និងមេធាវីរបស់ភាគីធ្វើការបញ្ចេញមតិ តែក្នុងការកត់សម្គាល់របស់ខ្លួន ចំណែកសភាស៊ើបសួរអាចបង្គាប់ឲ្យគូភាគីចូលបង្ហាញខ្លួន។ តួនាទីរបស់សភាស៊ើបសួរមិនកំណត់ត្រឹមការពិនិត្យឧទ្ធរណ៍ ទៅលើសេចក្តីសម្រេចរបស់ចៅក្រមស៊ើបសួរបាននោះទេ តែសភាស៊ើបសួរមានតំណែងធំជាងនេះទៅទៀតដូចជា៖

- ជំនួសចៅក្រមស៊ើបសួរ ដោយបង្គាប់ឲ្យចៅក្រមស៊ើបសួរ ឬ សមាជិកណាម្នាក់នេះរបស់សភា ធ្វើកិច្ចស៊ើបសួរតាមការយល់ឃើញរបស់ខ្លួន[64]។
- ចោទប្រកាន់បុគ្គលដទៃ ក្រៅពីអ្នកដែលបានលើកឡើងដោយចៅក្រមស៊ើបសួរ[65]។
- ពង្រីកការចោទប្រកាន់ ទៅលើបទល្មើសផ្សេងៗទាក់ទងទៅនឹងបទល្មើសដែលគេប្តឹងទៅចៅក្រមស៊ើបសួរ កាណាបទល្មើសនោះលេចចេញសំណុំរឿងនីតិវិធី។
- ឃ្លាំមើលនិយ័តភាព និងការប្រព្រឹត្តទៅរបស់នីតិវិធី សភាស៊ើបសួរអាចបដិសេធចោលដោយខ្លួនឯងនូវនីតិវិធីទាំងមូល ឬមួយផ្នែកប្រសិនមិនយល់ឃើញថាមានភាពមិនប្រក្រតីកើតឡើង។

## ២.២.អំណាចផ្ទាល់របស់ប្រធានសភាស៊ើបសួរ និងន្ទាប់បន្សំ

### ២.២.១អំណាចផ្ទាល់របស់ប្រធានសភាស៊ើបសួរ

នៅក្នុងក្រមនីតិវិធីប្រហ្មទណ្ឌបានចែងពីអំណាចរបស់ប្រធានសភាស៊ើបសួរ ដែលត្រូវទទួលសិទ្ធិអំណាចត្រួតពិនិត្យដោយផ្ទាល់ទៅលើចៅក្រមស៊ើបសួរ។ ការត្រួតពិនិត្យរបស់ប្រធានសភាស៊ើបសួរទៅ លើមន្ទីរស៊ើបសួរមានគោលដៅធានារ៉ាប់រងនូវ ការប្រព្រឹត្តទៅដ៏ល្អរបស់មន្ទីរស៊ើបសួរ ដើម្បីជៀសវាងការយឺតយ៉ាវនៃនីតិវិធីដោយពុំសមហេតុផលនិងដើម្បីឲ្យការគោរពលក្ខខណ្ឌនៃការឃុំខ្លួនបណ្តោះអាសន្ន នៃដីកានានារបស់តុលាការ ដីកាចាត់ឲ្យស៊ើបសួរសាក្សី និងកោសល្យវិច័យ[66]។

ការត្រួតពិនិត្យនេះធ្វើឡើងដំបូងតាមរយៈកាតព្វកិច្ចដែលចៅក្រមស៊ើបសួរប្រគល់តារាងរាយឈ្មោះរឿងទាំងអស់ដោយមានចុះនិទ្ទេសស្តីពី កិច្ចចុងក្រោយដែលបានបំពេញទៅបំណាច់ត្រីមាសនីមួយៗ[67]។ ជាការពិតបើគាត់ពិនិត្យ

---

[63] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧,មាត្រា២៧០

[64] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧,មាត្រា២៦២

[65] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧,មាត្រា២៨៣

[66] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧,មាត្រា២៨៣

[67] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧,មាត្រា២៨៤

ឃើញមានភាពមិនប្រក្រតីនៅពេលអានតារាងរាយ នាមឈ្មោះរឿងគាត់អាចសុំការបកស្រាយ បំភ្លឺទៅចៅក្រមស៊ើបសួរ និងប្ដឹងទៅសភាស៊ើបសួរ។ ម្យ៉ាងវិញទៀតប្រធានស៊ើបសួរអាចធ្វើអធិការកិច្ចនៅមន្ទីរស៊ើបសួរ នៅពេលបញ្ចប់អធិការកិច្ចហើយត្រូវធ្វើរបាយការណ៍បញ្ជូនទៅប្រធានសាលាឧទ្ធរណ៍[68]។

ច្បាប់អនុញ្ញាតឲ្យផ្តល់អំណាចឲ្យប្រធានសភាស៊ើបសួរនៃសលាឧទ្ធរណ៍ មានអំណាចធ្វើគ្រប់អធិការកិច្ចនៅមន្ទីរស៊ើបសួរ និងធានារ៉ាប់រងការប្រព្រឹត្តទៅ បាននៃមន្ទីរស៊ើបសួររបស់ចៅក្រមស៊ើបសួរដែលផ្ទៀងផ្ទាត់ មើលលើលក្ខខណ្ឌនៃការអនុវត្តបទប្បញ្ញត្តិស្តីពី ការឃុំខ្លួនបណ្តោះអាសន្នដីកាតុលាការផ្សេងៗ ដីកាចាត់ឲ្យស៊ើបសួរជំនួស និងកោសល្យវិច័យ[69]។

នៅក្នុងនោះផងដែរ ភាគីមួយៗត្រូវទទួលដំណឹងអំពីអំណះអំណាងដែល ធ្វើឡើងដោយភាគីម្ខាងទៀត ដោយសារតែមានកាតព្វកិច្ចតម្រូវឲ្យគូភាគីផ្លាស់ប្តូរសារណាគ្នាលទ្ធផលទទួលបានព័ត៌មានអំពីសំណុំរឿង និងកាតព្វកិច្ចជូនដំណឹងដល់គូភាគីអំពីកាលបរិច្ឆេទសវនាការ។ ចំពោះការជូនដំណឹងជនត្រូវចោទដែលត្រូវឃុំខ្លួនត្រូវធ្វើឡើង ដោយផ្ទាល់មាត់ ឬតាមរយៈពេលប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួន។ ចំណែកឯការជូនដំណឹងដល់ជនត្រូវចោទដែលនៅក្រៅឃុំ ដល់ដើបណ្តឹងរដ្ឋប្បវេណី និងមេធាវីត្រូវធ្វើតាមរយៈដោយផ្ទាល់មាត់ តាមផ្លូវរដ្ឋបាល ឬតាមរយៈអង្គភាពនគរបាល ឬកម្លាំងអាវុធហត្ថ។ អំណាចបន្ទាប់បន្សំរបស់សភាស៊ើបសួរ[70]។

**២.២.២.អំណាចបន្ទាប់បន្សំរបស់ប្រធានសភាស៊ើបសួរ**

សភាស៊ើបសួរនៃ សាលាឧទ្ធរណ៍រាជធានីភ្នំពេញ ត្រូវបានផ្តល់នូវសិទ្ធិអំណាចដែលមានសមត្ថកិច្ចខាងផ្នែកបត្យាប័ន។ ចំពោះបត្យាប័នជនបរទេសអាចធ្វើទៅបានលុះត្រា តែបុគ្គលនោះត្រូវបានចោទប្រកាន់តាមផ្លូវតុលាការឬត្រូវបានតុលាការនៃរដ្ឋដទៃប្រកាសផ្តន្ទាទោស។ ម្យ៉ាងវិញទៀតបត្យាប័នអាចធ្វើ ទៅបានលុះត្រាតែអំពើដែលត្រូវបានចោទប្រកាន់ ទៅលើបុគ្គលដែលទាមទារយកមកនោះចាត់ទុកជាបទល្មើសតាមច្បាប់ នៃព្រះរាជណាចក្រកម្ពុជាហើយនឹងត្រូវផ្តន្ទាទោសដាក់ពន្ធនាគារយ៉ាងតិច២(ពីរ)ឆ្នាំតាមច្បាប់នៃរដ្ឋដែលដាក់សំណើ។

ប៉ុន្តែ បត្យាប័នក៏អាចធ្វើទៅបានដែរ ក្នុងករណីដែលបុគ្គលដែលត្រូវបានទាមទារនោះ ត្រូវបានតុលាការនៃរដ្ឋធ្វើសំណើសម្រេចផ្តន្ទាទោស ដាក់ពន្ធនាគារយ៉ាងតិចបំផុតស្មើនឹង៦(ប្រាំមួយ)ខែ ម្យ៉ាងទៀតសេចក្តីសម្រេចនេះបានចូលជាស្ថាពររួចហើយ[71]។

នៅក្នុងនោះផងដែរ ពាក្យសុំធ្វើបត្យាប័នត្រូវប្រគល់ទៅឲ្យរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជាដែលបញ្ជូនបន្តទៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។ សភាស៊ើបសួរនិងទទួលបណ្តឹងអំពីពាក្យសុំធ្វើបត្យាប័ន ដែលនឹងត្រូវពិនិត្យពិភាក្សាក្នុងសវនាការ។ សភាស៊ើបសួរធ្វើការសម្រេច ក្រោយបានស្តាប់ចម្លើយរស់បុគ្គលដែលត្រូវបានធ្វើបត្យាប័ន សេចក្តីសន្និដ្ឋានសុំរបស់អគ្គព្រះរាជអាជ្ញានិងសេចក្តីសន្និដ្ឋានការពាររបស់មេធាវី[72]។សភាស៊ើបសួរ ផ្តល់យោបល់លើពាក្យសុំធ្វើបត្យាប័នដែលសំអាងហេតុដែលមានទម្រង់សាលដីកា។សភាស៊ើបសួរក៏ធានារ៉ាប់រងនូវការគោរពលក្ខខណ្ឌនេះនីត្យានុកូល ដែលកំណត់អំពីការអនុវត្តបត្យាប័ន។

---

[68] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧,មាត្រា២៨៥

[69] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧,មាត្រា២៥៨

[70] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧,មាត្រា២៥៨

[71] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧,មាត្រា៥៧១

[72] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧,មាត្រា៥៩១

ម្យ៉ាងវិញទៀត សាលដីកាសភាស៊ើបសួរត្រូវបញ្ជូនទៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។ ទោះបីជាសេចក្តីសម្រេចរបស់សភាស៊ើបសួរមានលក្ខណៈជាការផ្តល់យោបល់ប៉ុន្តែវាជា ដំណាក់កាលនៃការសម្រេចចិត្តមួយផងដែរ។ដូច្នេះបើសភាស៊ើបសួរផ្តល់យោបល់ មិនយល់ព្រមនោះរាជរដ្ឋាភិបាលមិនអាចធ្វើបត្យាប័នបានទេ[73]។

សភាស៊ើបសួរក៏មានសមត្ថកិច្ច វាយតម្លៃពីភាពនៃការធ្វើបត្យាប័នដែលទទួលដោយរាជរដ្ឋាភិបាលកម្ពុជា នៅពេលដែលបុគ្គលបញ្ហាដែលគេមកលើអំពីលើកអំពីមោឃភាពនីតិវិធី[74]។

## ផ្នែកទី២៖ ដំណើរការនិតិវិធីនៃបណ្តឹងឧទ្ធរណ៍

### កថាខណ្ឌទី១៖ គុណវុឌ្ឍន៍នៃបណ្តឹងឧទ្ធរណ៍

#### ១.១.តំណាងអយ្យការ

ព្រះរាជអាជ្ញាអមសាលាដំបូង និងអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍អាច ប្តឹងឧទ្ធរណ៍ចំពោះដីកាសម្រេចរបស់ចៅក្រមស៊ើបសួរបានទាំងអស់ ដូចជាបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាសម្រេចរបស់ចៅក្រមស៊ើបសួរ នៅក្នុងវិធានការនិរន្តរាយ ដីកាដំណោះស្រាយ។ល។

ឧទាហរណ៍៖ចំពោះករណីមានបណ្តឹងឧទ្ធរណ៍ពីតំណាងអយ្យការនៅក្នុងការជំទាស់នឹងសេចក្តីសម្រេចលើកលែងការចោទប្រកាន់ នោះដីកាលើកលែងចោទប្រកាន់របស់ចៅក្រមស៊ើបសួរនោះ ជនត្រូវចោទ ដែលជាប់ឃុំត្រូវរក្សាទុកនៅក្នុងពន្ធនាគាររហូតដល់ពេលដែលសភាស៊ើបសួរសម្រេចអំពីបណ្តឹងឧទ្ធរណ៍។

#### ១.២.ភាគី

##### ១.២.១.ជនត្រូវចោទ

ជនត្រូវចោទ ក៏មានសិទ្ធិប្តឹងឧទ្ធរណ៍ចំពោះដីកាដូចតទៅ៖

- ដីកាបដិសេធពាក្យសុំធ្វើឲ្យធ្វើកិច្ចការស៊ើបសួរនៅគ្រប់ពេលវេលានៃការស៊ើបសួរ ជនត្រូវចោទអាចសុំឲ្យចៅក្រមស៊ើបសួរធ្វើការស៊ើបសួរស្តាប់ចម្លើយរបស់ខ្លួនស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ឬសាក្សីសួរតទល់គ្នា ឬ ចុះទៅដល់ទីកន្លែង។ ពាក្យសុំត្រូវធ្វើជាលាយលក្ខណ៍អក្សរនិងត្រូវមានសំអាងហេតុ។ ប្រសិនបើចៅក្រមស៊ើបសួរមិនព្រមធ្វើតាមពាក្យសុំនេះទេចៅក្រមរូបនេះចេញដីកាបដិសេធក្នុងចិរវេលា ១(មួយ) ខែ បន្ទាប់ពីពេលទទួលពាក្យសុំនោះ។ ដីកានេះត្រូវតែមានសំអាងហេតុ និងត្រូវជូនដំណឹងជាបន្ទាន់ដល់ព្រះរាជាអាជ្ញា និងដល់ជនត្រូវចោទ។ ប្រសិនបើចៅក្រមស៊ើបសួរមិនបានសម្រេចក្នុងរយៈពេល១(មួយ)ខែទេ ជនត្រូវចោទអាចប្តឹងដោយផ្ទាល់ តាមរយៈពាក្យសុំដល់ភាគីស៊ើបសួរដែលសម្រេចជំនួសចៅក្រមស៊ើបសួរ។
- ដីកាមិនប្រគល់វត្ថុ ដែលចាប់ឲ្យទៅម្ចាស់ដើមវិញ គឺនៅពេលមិនទាន់ចេញដីកាដំណោះស្រាយ រឿងនៅឡើយទេ ចៅក្រមស៊ើបសួរមានសមត្ថកិច្ចប្រគល់សងទៅម្ចាស់ដើមវិញនូវវត្ថុដែលចាប់បាន កាលណាកម្មសិទ្ធិនេះគ្មានជំទាស់អ្វីប្រាកដប្រជាទេ។ ចៅក្រមស៊ើបសួរសម្រេចតាមដីកាដែលមានសំអាងហេតុ ក្រោយពីបានទទួលមតិពីព្រះរាជអាជ្ញា។ ដីកាសម្រេចត្រូវឲ្យដំណឹងជាបន្ទាន់ដល់អ្នកប្តឹង និងមេធាវីនៃអ្នកប្តឹងប្រសិនបើមាន។ មិនប្រគល់សងទៅឲ្យអ្នកប្តឹងសុំទេ កាលណាវិធានការនេះ អាចបង្កជាឧបសគ្គដល់កាសម្តែងឲ្យឃើញការពិត។ វត្ថុដែលមានគ្រោះថ្នាក់ដល់បុគ្គល ឬ ទ្រព្យសម្បត្តិដូចជាអាវុធ ឬជាតិផ្ទុះព្រមទាំងវត្ថុដែលកាន់កាប់មិនស្របច្បាប់មិនអាចត្រូវប្រគល់សងទៅឲ្យសាមីខ្លួនបានទេ។ វត្ថុទាំងនេះត្រូវរឹបអូសជាកម្មសិទ្ធិរបស់រដ្ឋ។

[73] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧,មាត្រា៥៨៩

[74] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧,មាត្រា៥៩០

- នៅក្នុងដីកាដំណោះស្រាយ ចៅក្រមស៊ើបសួរសម្រេចអំពីការប្រគល់សងទៅឲ្យម្ចាស់ដើមវិញ នូវវត្ថុដែលចាប់យក។ ក៏ត្រូវយកមកអនុវត្តផងដែរ ក្នុងករណីអាជ្ញាធរមានសមត្ថកិច្ចបង្គាប់ឲ្យប្រគល់វត្ថុជូន ម្ចាស់ដើមវិញគឺព្រះរាជអាជ្ញាមាន សមត្ថកិច្ចបង្គាប់ឲ្យប្រគល់វត្ថុដែល បានចាប់បាននៅពេលស៊ើបសួរអង្កេតទៅម្ចាស់ដើមវិញ ប្រសិនបើវត្ថុទាំងនោះពុំមានប្រយោជន៍ សម្រាប់ការសម្តែងការពិតទេនោះ ហើយប្រសិនបើ កម្មសិទ្ធិលើវត្ថុនោះគ្មានការជំទាស់អ្វីប្រាកដប្រជាទេ។ ប៉ុន្តែវត្ថុដែលមានគ្រោះថ្នាក់ចំពោះមនុស្សទូទៅ ឬ ចំពោះទ្រព្យសម្បត្តិ ដូចជាអាវុធ ឬជាតិផ្ទុះ ព្រមទាំងវត្ថុដែលត្រូវបានកាន់កាប់ដោយខុសច្បាប់ មិនអាចប្រគល់ឲ្យវិញបានទេ។ វត្ថុទាំងនោះត្រូវរឹបអូសទុកសម្បត្តិរដ្ឋ ឬបំផ្លាញចោល។ ក្នុងករណីមិនព្រមប្រគល់ឲ្យវិញទេ អាចប្ដឹងតវ៉ាទៅអគ្គព្រះរាជអាជ្ញាបាន។ ព្រះរាជអាជ្ញា និងអគ្គព្រះរាជអាជ្ញា គ្មានសមត្ថកិច្ចក្នុងការ ប្រគល់ទេកាលណាមានការចោទប្រកាន់ធ្វើឡើងនៅចំពោះមុខយុត្តាធិការស៊ើបសួរ ឬ យុត្តាធិការជំនុំជម្រះ។ ព្រះរាជអាជ្ញា និងអគ្គព្រះរាជអាជ្ញា នៅតែមានសមត្ថកិច្ចកាលណាការស៊ើបសួរត្រូវបានបញ្ចប់ដោយសេចក្ដីសម្រេចលើកលែងការចោទប្រកាន់ជាស្ថាពរ។
- ដីកាស្តីរឿងឃុំខ្លួនបណ្តោះអាសន្ន និងការត្រួតពិនិត្យតាមផ្លូវតុលាការៈដីកាដំណោះស្រាយបញ្ចប់ការឃុំខ្លួនជាបណ្តោះអាសន្ន។ ក្នុងករណីនេះ ក៏ត្រូវយកមកអនុវត្តផងដែរចំពោះការដោះលែងជនត្រូវចោទដែលជាប់ឃុំឲ្យមានសេរីភាព គឺកាលណាចៅក្រមស៊ើបសួរសម្រេចឲ្យដោះលែងជនត្រូវចោទដែលជាប់ឃុំបណ្តោះអាសន្ន ជនត្រូវចោទនោះ ត្រូវបានរក្សាទុកនៅក្នុងពន្ធនាគារ រហូតផុតរយៈពេលសម្រាប់បណ្ដឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញា លើកលែងតែព្រះរាជអាជ្ញា ត្រូវដាក់បញ្ចូលក្នុងសំណុំរឿងនៃនីតិវិធី។ ត្រូវធ្វើដូចគ្នានេះដែរ ចំពោះដីកាលើកលែងចោទប្រកាន់នោះ ជនត្រូវចោទ ជាប់ឃុំត្រូវរក្សាទុកក្នុងពន្ធនាគារ រហូតទាល់តែសភាស៊ើបសួរបានសម្រេចអំពីបណ្តឹងឧទ្ធរណ៍។ ប៉ុន្តែតាមសេចក្តីសម្រេចដោយឡែកនៃដីកាដំណោះស្រាយចៅក្រមស៊ើបសួរ អាចរក្សាជនត្រូវចោទឲ្យនៅជាប់បណ្តោះអាសន្ន រហូតដល់ពេលចូលបង្ហាញខ្លួននៅមុខតុលាការ។

នៅក្នុងដីកានេះ ចៅក្រមស៊ើបសួរ ត្រូវយោងតាមលក្ខខណ្ឌនៃមូលហេតុនៃការឃុំខ្លួនកាលណាការឃុំខ្លួនបណ្តោះអាសន្ននេះជាការចាំបាច់៖

- ដើម្បីបញ្ចប់បទល្មើស ឬបង្ការបទល្មើសកុំឲ្យមានជាថ្មី
- ដើម្បីរារាំងកុំឲ្យមានការគាបសង្កត់លើសាក្សី ឬជនរងគ្រោះ ឬដើម្បីរារាំងកុំឲ្យមានការត្រូវរ៉ូវគ្នារវាងជនត្រូវចោទ និងសមគំនិត
- ដើម្បីរក្សាភស្តុតាង ឬតម្រុយសម្ភារៈ
- ដើម្បីធានារក្សាជនត្រូវចោទទុកជូនតុលាការចាត់ការតាមនីតិវិធី
- ដើម្បីការពារសន្តិសុខឲ្យជនត្រូវចោទ
- ដើម្បីធានារក្សាសណ្តាប់ធ្នាប់សាធារណៈ កំឲ្យមានការច្របូកច្របល់ ដែលបណ្តាលមកបទល្មើស

សេចក្តីសម្រេចរក្សាទុកជនត្រូវចោទក្នុងឃុំជាបណ្តោះអាសន្នលែងមានអានុភាពក្នុង រយៈពេល៤(បួន)ខែ។ ប្រសិនបើជនត្រូវចោទមិនបានចូលបង្ហាញខ្លួននៅមុខតុលាការក្នុងរយៈពេល៤(បួន)ខែនោះទេជនត្រូវចោទនេះត្រូវបានដោះលែងឲ្យនៅក្រៅឃុំបណ្តោះអាសន្នដោយឯកឯង។ ដីកាដំណោះស្រាយ បញ្ចប់ការត្រួតពិនិត្យតាមផ្លូវតុលាការ។

កាលណាចៅក្រមស៊ើបសួរបាន ដាក់កំហិតដល់ជនត្រូវចោទឲ្យបង់ប្រាក់ធានាឲ្យ ប្រគល់ឯកសារបញ្ជាក់អំពីអត្តសញ្ញាណ ឬឲ្យប្រគល់វត្ថុហត្ថលេខា ដោយជនត្រូវចោទុកជាសម្គាល់។ ប៉ុន្តែ តាមសេចក្តីសម្រេចដោយឡែកនៃដីកា

ដំណោះស្រាយ ចៅក្រមស៊ើបសួរអាចរក្សាទុកជនឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ រហូតដល់ពេលចូលបង្ហាញខ្លួននៅចំពោះមុខតុលាការ។

ដីកាបដិសេធពាក្យសុំឲ្យធ្វើកោសល្យវិច័យនៅក្នុងករណីដែលមានបញ្ហាបច្ចេកទេសចោទឡើង ចៅក្រមស៊ើបសួរអាចបង្គាប់ឲ្យធ្វើកោសល្យវិច័យដោយឯកឯង ឬតាមពាក្យសុំរបស់ព្រះរាជអាជ្ញា របស់ជនត្រូវចោទ ឬដើមបណ្តឹងរដ្ឋប្បវេណី។កាលណាចៅក្រមស៊ើបសួរបដិសេធមិនព្រមធ្វើតាមពាក្យសុំកោសល្យវិច័យទេចៅក្រមស៊ើបសួរសម្រេចដីកា ដោយមានសំអាងហេតុ។ ដីកាត្រូវសម្រេចក្នុងរយៈបេល៥(ប្រាំ)ថ្ងៃ ប្រសិនបើពាក្យសុំនោះចេញមកពីព្រះរាជអាជ្ញានិង១(មួយ)ខែប្រសិនបើពាក្យសុំនោះចេញមកពីជនត្រូវចោទ ឬដើមបណ្តឹងរដ្ឋប្បវេណី។ ដីកាសម្រេចនេះ ត្រូវជូនដំណឹងឲ្យដល់អ្នកប្តឹងសុំជាបន្ទាន់។

**១.២.២.ដើមបណ្តឹងរដ្ឋប្បវេណី**

ដើមបណ្តឹងរដ្ឋប្បវេណីអាចប្តឹងឧទ្ធរណ៍ចំពោះដីកាដូចតទៅ៖

- ដីកាបដិសេធពាក្យសុំឲ្យធ្វើកិច្ចស៊ើបសួរ៖ប្រសិនបើចៅក្រមស៊ើបសួរមិនព្រមធ្វើតាមពាក្យសុំនេះទេ ចៅក្រមរូបនេះត្រូវចេញដីកាបដិសេធក្នុងចិរវេលា១(មួយ)ខែក្រោយពេលទទួលពាក្យសុំ។ដីកានេះត្រូវតែមានសំអាងហេតុ ហើយត្រូវជូនដំណឹងជាបន្ទាន់ដល់ព្រះរាជអាជ្ញា និងដើមបណ្តឹងរដ្ឋប្បវេណីអាចប្តឹងដោយផ្ទាល់ តាមាយៈពាក្យសុំដល់សភាស៊ើបសួរដែលសម្រេចជំនួសចៅក្រមស៊ើបសួរ។
- ការមិនព្រមស៊ើបសួរ៖ក្នុងករណីដែលចៅក្រមស៊ើបសួរសម្រេចមិនស៊ើបសួរ ចៅក្រមរូបនេះត្រូវចេញដីកាសម្រេចដោយមានសំអាងហេតុ ដែលត្រូវជូនដំណឹងជាបន្ទាន់ដល់ដើមបណ្តឹងរដ្ឋប្បវេណី
- ដីកាកំណត់ចំនួនប្រាក់កក់៖ ដោយផ្អែកលើធនធានរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងការលំបាកដែលអាចមើលឃើញជាមុន ចៅក្រមស៊ើបសួរកំណត់តាមដីកាសម្រេច នូវចំនួនទឹកប្រាក់ដែលដើមបណ្តឹងរដ្ឋប្បវេណីត្រូវបង់ព្រមទាំងរយៈពេលនៃការបង់នេះផងដែរ។
- ដីកាប្រកាសមិនទទួលពាក្យប្តឹង ដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី៖ ដោយផ្អែកទៅលើធនធាននៃដើមបណ្តឹងរដ្ឋប្បវេណី និងទៅលើការលំបាកនៃរឿងដែលអាចមើលឃើញ ជាមុនចៅក្រមស៊ើបសួរកំណត់តាមដីកាសម្រេចនូវចំនួនទឹកប្រាក់ដែលដើមបណ្តឹងរដ្ឋប្បវេណីត្រូវបង់ព្រមទាំងរយៈពេលដែលបង់ប្រាក់នេះផងដែរ។
- ដីកាផ្តន្ទាទោសដើមបណ្តឹងរដ្ឋប្បវេណី៖ ប្រសិនបើការស៊ើបសួរដែលបានបើក បន្ទាប់ពីមានពាក្យប្តឹង ដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ត្រូវបានបិទតាមដីកាលើកលែងចោទ ប្រកាន់ហើយប្រសិនបើចៅក្រមស៊ើបសួររកឃើញថា នីតិវិធីដោយរំលោភ ឬអូសបន្លាយពេលវេលានោះចៅក្រមស៊ើបសយរអាចសម្រេចតាមដីកាសម្រេច ឲ្យដើមបណ្តឹងរដ្ឋប្បវេណីបង់ប្រាក់ពិន័យ។ ចំនួនប្រាក់ពិន័យមិនអាចលើសចំនួនទឹកប្រាក់តម្កល់ទុកឡើយ។ដីកាសម្រេចឲ្យបង់ប្រាក់ពិន័យនេះត្រូវឲ្យដំណឹងដល់សាមីខ្លួនជាបន្ទាន់។
- ដីកាមិនព្រមប្រគល់សងវត្ថុដែលចាប់យកទៅម្ចាស់ដើមវិញនៅពេលដែលមិនទាន់ចេញដីកាដំណោះស្រាយរឿងនៅឡើយទេ ចៅក្រមស៊ើបសួរមានសមត្ថកិច្ចប្រគល់សងទៅម្ចាស់ដើមវិញនូវវត្ថុដែលចាប់បាន កាលណាកម្មសិទ្ធិនេះគ្មានការជំទាស់អ្វីប្រាកដប្រជាទេ។ ចៅក្រមស៊ើបសួរសម្រេចដីកា ដែលមានសំអាងហេតុ ក្រោយពីបានទទួលមតិពីព្រះរាជអាជ្ញា។ ដីកាសម្រេចត្រូវឲ្យដំណឹងជាបន្ទាន់ដល់អ្នកប្តឹង និងមេធាវីដែលមិនគួរប្រគល់សងទៅឲ្យអ្នកប្តឹងសុំទេ កាលណា វិធានការនេះអាចបង្កជាឧបសគ្គ ដល់ការសំដែងឲ្យឃើញការពិត។ វត្ថុដែលមានគ្រោះថ្នាក់ដល់បុគ្គល ឬទ្រព្យសម្បត្តិ ដូចជាអាវុធ ឬជាតិផ្ទុះព្រមទាំងវត្ថុ ដែលការកាន់កាប់មិន

ស្របសច្បាប់ មិនអាចត្រូវប្រគល់សងទៅឲ្យសាមីខ្លួនបានទេ។ វត្ថុទាំងនេះ ត្រូវរឹបអូសជាកម្មសិទ្ធិរបស់រដ្ឋ។ នៅក្នុងដំណោះស្រាយ ចៅក្រមស៊ើបសួរសម្រេចអំពីការប្រគល់សងទៅម្ចាស់ដើមវិញនូវវត្ថុដែលចាប់មក។ ការអនុវត្តដីកាបង្គាប់ឲ្យចាប់ខ្លួន ត្រូវប្រគល់ឲ្យមន្ត្រីនគរបាលយុត្តិធម៌។ ក្នុងករណីបន្ទាន់ដីកាបង្គាប់ឲ្យចាប់ខ្លួនត្រូវផ្សព្វផ្សាយតាមអង្គភាពនគរបាល ឬកងរាជអាវុធហត្ថតាមគ្រប់មធ្យោបាយ។ ដើមដីកា ត្រូវប្រគល់ក្នុងរយៈពេលយ៉ាងខ្លីបំផុតឲ្យមន្ត្រីនគរបាលយុត្តិធម៌ ដែលទទួលបន្ទុកអនុវត្តដីកានេះ។ មន្ត្រីនគរបាលយុត្តិធម៌មិនអាចចូលទៅក្នុងលំនៅឋានរបស់បុគ្គលពាក់ព័ន្ធមុនម៉ោង៦(ប្រាំមួយ)ព្រឹក និងក្រោយម៉ោង១៨(ដប់ប្រាំបី)បានទេ។ មន្ត្រីនគរបាលយុត្តិធម៌ ត្រូវជូនដំណឹងដល់ចៅក្រមស៊ើបសួរអំពីការលំបាកទាំងអស់ក្នុងពេលអនុវត្តបេសកកម្មរបស់ខ្លួន។

- ដីកាបដិសេធពាក្យសុំឲ្យធ្វើដីកោសល្យវិច័យៈកាលណាចៅក្រមស៊ើបសួរបដិសេធមិនព្រមតាមពាក្យសុំធ្វើកោសល្យវិច័យទេ ចៅក្រមស៊ើបសួរត្រូវសម្រេចតាមដីកាដោយសំអាងហេតុ។
- ហើយដីកាត្រូវសម្រេចនេះក្នុងរយៈពេល៥(ប្រាំ)ថ្ងៃ ប្រសិនបើពាក្យសុំនោះចេញមកពីព្រះរាជអាជ្ញា និង១(មួយ)ខែ ប្រសិនបើពាក្យសុំនោះចេញមកជនត្រូវចោទ ឬដើមបណ្ដឹងរដ្ឋប្បវេណី ។ ដីកាសម្រេចនេះត្រូវជូនដំណឹងឲ្យដល់ប្ដឹងសុំជាបន្ទាន់។
- ដីកាបដិសេធពាក្យសុំធ្វើកោសល្យវិច័យបន្ថែម ឬ សុំឲ្យធ្វើប្រតិកោសល្យវិច័យៈ គ្រប់ពាក្យសុំធ្វើកោសល្យវិច័យបន្ថែមឬប្រតិកោសល្យវិច័យដែលធ្វើឡើងក្រោយផុតរយៈពេលដែលកំណត់ដោយចៅក្រមស៊ើបសួរ ដែលបានបញ្ចូលក្នុងសំណុំរឿង។
- ដីកាដំណោះស្រាយចៅក្រមស៊ើបសួរ បិទការស៊ើបសួរតាមដីកាដំណោះស្រាយ ដីកានេះអាចជាដីកាបញ្ជូនទៅជំនុំជម្រះ ឬដីកាលើកលែងចោទប្រកាន់ ប្រសិនបើយល់ឃើញថាអំពើនោះជា បទឧក្រិដ្ឋ បទលហុ ចៅក្រមស៊ើបសួរសម្រេចបញ្ជូនជនត្រូវចោទទៅមុខតុលាការជំនុំជម្រះ។

## កថាខណ្ឌទី២ៈយន្តការរបស់សភាស៊ើបសួរ

### ២.១.ដំណើរការសវនាការរបស់សភាស៊ើបសួរ

ត្រូវបើកឲ្យមានកាន់បញ្ជីបណញដឹងឧទ្ធរណ៍ និងពាក្យសុំមួយនៅការិយាល័យ ក្រឡាបញ្ជីនៃសភាស៊ើបសួរ។ បន្ទាប់បីបានទទួលពាក្យបណ្ដឹង ក្រឡាបញ្ជីនៃតុលាការជាន់ដំបូងត្រូវតែឲ្យដំណឹង ភ្លាមទៅចៅក្រមស៊ើបសួរ។ កាលណាសភាស៊ើបសួរត្រូវបានប្ដឹងផ្ទាល់តាមរយៈពាក្យសុំក្រឡាបញ្ជីនៅសភាស៊ើបសួរ សុំក្រឡាបញ្ជីនៃចៅក្រមស៊ើបសួរ ផ្ញើមកឲ្យនូវសំណុំរឿងនសនីតិវិធី ឬ សំណុំរឿងបង្ការទុក។ ប្រធានសភាស៊ើបសួរពិនិត្យផ្ទៀងផ្ទាត់មើលថា តើសំណុំមានលក្ខណៈគ្រប់គ្រាន់ល្មមជំនុំចម្រះបានឬទេ រយចហើយកំណត់កាលបរិច្ឆេទនៃការបើកសវនាការដល់វត្តព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍។ អគ្គព្រះរាជាអាជ្ញាអមសាលាឧទ្ធរណ៍ ជូនដំណឹងអំពីកាលបរិច្ឆេទនៃសវនាការនេះដល់គូភាគី និងដល់មេធាវី។

ការជូនដំណឹងដល់ជនត្រូវចោទដែលត្រូវបានឃុំខ្លួន ត្រូវធ្វើដូចតទៅនេះៈ

- ដោយផ្ទាល់មាត់
- តាមរយៈប្រធានពន្ធនាគារ ឬ មណ្ឌលឃុំខ្លួន។

ការជូនដំណឹងដល់ជនត្រូវចោទនៅក្រៅឃុំ ដល់ដើមបណ្ដឹងរដ្ឋប្បវេណី និងដល់មេធាវីត្រូវធ្វើដូចតទៅៈ

- ដោយផ្ទាល់មាត់
- តាមផ្លូវរដ្ឋបាល ឬ

– តាមរយៈអង្គភាពនគរបាល ឬ កងរាជអាវុធហត្ថ។

កាលណាការជូនដំណឹងធ្វើដោយផ្ទាល់មាត់ ក្រឡាបញ្ជីចុះនិទ្ទេសអំពីកាលបរិច្ឆេទនៃការជូនដំណឹងនៅរឹមទំព័រនៃដីកា។ ជនត្រូវចោទ ដើមបណ្តឹងរដ្ឋប្បវេណី ឬ មេធាវីហត្ថលេខារបស់ខ្លួន។ ក្នុងករណីដទៃទៀត ការជូនដំណឹងត្រូវធ្វើដោយការប្រគល់សេចក្តីចម្លងដីកាដោយមានចំណារទទួល។អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ និងមេធាវីអាចពិនិត្យមើល សំណុំរឿងរហូតដល់ពេលបើកសវនាការ។ អគ្គព្រះរាជអាជ្ញាអមសាលាអមសាលាឧទ្ធរណ៍ត្រូវប្រគល់សេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរដល់ក្រឡាបញ្ជីយ៉ាងយូរបំផុត១ (មួយ)ថ្ងៃ មុនពេលសវនាការ។ គូភាគី និងមេធាវីអាចប្រគល់សារណាដល់ក្រឡាបញ្ជី។ សេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ និងសារណាត្រូវចុះទិដ្ឋាការដោយក្រឡាបញ្ជីដោយមានការចុះកាលបរិច្ឆេទ និងត្រូវបញ្ចូលក្នុងសំណុំរឿងភ្លាមៗ។

គូភាគី និងមេធាវី ត្រូវបានអនុញ្ញាតឲ្យជូនសារណារហូតដល់ពេលចាប់ផ្តើមបើកសវនាការ។ ការពិភាក្សាដេញដោលត្រូវប្រព្រឹត្តទៅក្នុងបន្ទប់ពិភាក្សា។ ក្រោយពីរបាយការណ៍របស់ប្រធានសភាស៊ើបសួរ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ និងមេធាវីរបស់គូភាគី ធ្វើការកត់សម្គាល់របស់ខ្លួនដោយសង្ខេប។ សភាស៊ើបសួរអាចបង្គាប់ឲ្យគូភាគី ព្រមទាំងជនត្រូវចោទជាប់ឃុំ ចូលមកបង្ហាញខ្លួនដោយផ្ទាល់ហើយនិងផ្តល់វត្ថុតាង។ កាលណាការពិភាក្សាដេញដោលបានបញ្ចប់ សភាស៊ើបសួរធ្វើការពិគ្រោះសម្រេចដោយគ្មានវត្តមានរបស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ គូភាគីនិងមេធាវីឡើយ។ សាលដីកាត្រូវប្រកាសនាពេលសវនាការអសាធារណៈនៅថ្ងៃនោះ ឬ ក៏នៅពេលសវនាការលើកក្រោយ។ សាលដីកាត្រូវតែមានសំអាងហេតុ ហើយត្រូវហត្ថលេខាដោយប្រធានសភាស៊ើបសួរ។ សាលដីកាត្រូវជូនដំណឹងដោយផ្ទាល់មាត់ក្នុងរយៈពេលខ្លីបំផុត ដល់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍។ ក្រឡាបញ្ជីចុះនិទ្ទេសអំពីកាលបរិច្ឆេទនៃកាជូនដំណឹងនៅត្រឹមទំព័រនៃសាលដីកា។អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ចុះហត្ថលេខាថាបានទទួល។ សាលដីកាត្រូវជូនដំណឹង ដល់គូភាគី និងមេធាវី។នៅរាល់ពេលដែលបានទទួលដំណឹង សភាស៊ើបសួរ ពិនិត្យមើលពីនិយ័តភាពនៃនីតិវិធី និងការប្រព្រឹត្តទៅដ៏ល្អនៃនីតិវិធីនេះ។ កាលណាពិនិត្យឃើញមូលហេតុនៃមោឃភាព សភាស៊ើបសួរអាចចាត់ទុកជាមោឃៈដោយឯកឯងនូវនីតិវិធីទាំងមូល ឬ ផ្នែកណាមួយ។

សភាស៊ើបសួរអាចបង្គាប់ឲ្យធ្វើកិច្ចស៊ើបសួរបំពេញបន្ថែម តាមដែលខ្លួនយល់ឃើញថាមានប្រយោជន៍។ ដើម្បីបំពេញកិច្ចនេះ សភាស៊ើបសួរ ត្រូវចាត់តាំងសមាជិកម្នាក់របស់សភា ឬ ក៏ចៅក្រមស៊ើបសួរណាម្នាក់ដែលខ្លួនប្រគល់អំណាចឲ្យ។ ចៅក្រមដែលទទួលភារកិច្ចស៊ើបសួបំពេញនោះ ប្រើប្រាស់អំណាចរបស់ចៅក្រមស៊ើបសួរនៅក្នុងព្រំដែនកំណត់ដោយសភាស៊ើបសួរ។ កាលណាកិច្ចស៊ើបសួរត្រូវបំពេញរួចហើយ សំណុំរឿងនៃនីតិវិធីត្រូវយកតម្កល់ទុកនៅការិយាល័យក្រឡាបញ្ជីនៃសភាស៊ើបសួរ។ ប្រធានសភាស៊ើបសួរកំណត់កាលបរិច្ឆេទនៃសវនាការថ្មី។ សភាស៊ើបសួរដោយឯកឯង ឬ តាមសេចក្តីសន្និដ្ឋានរបស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ អាចបង្គាប់ឲ្យពន្លាតការដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យ ដល់បទល្មើសដែលទាក់ទងគ្នានឹងបទល្មើស ដែលចង្អុលដោយចៅក្រមស៊ើបសួរ កាលណាបទល្មើសនោះលេចចេញពីសំណុំរឿងនៃនីតិវិធី។ បទល្មើសដែលទាក់ទងគ្នាគឺ កាលណាបទល្មើសបានប្រព្រឹត្តដោយបុគ្គលផ្សេងគ្នា បន្ទាប់ពីមានការព្រមព្រៀងគ្នា ទោះបីជាការប្រព្រឹត្តនៅក្នុងពេល ឬ នៅទីកន្លែងផ្សេងគ្នាក៏ដោយ កាលណាវត្ថុដែលលួច គៃបំបាត់ ឬ បានមកពីបទល្មើសណាមួយនោះ ត្រូវបានលាក់បំបាត់ដោយបុគ្គលផ្សេងទៀត។

សភាស៊ើបសួរអាចបង្គាប់ឲ្យចោទប្រកាន់បុគ្គលផ្សេងក្រៅពីបុគ្គល ដែលចែងដោយចៅក្រមស៊ើបសួរ លើកលែងតែករណីអាជ្ញាអស់ជំនុំ។ ក្រោយពេលដែលដីកាបស់ចៅក្រមស៊ើបសួរ ឬ សាលដីកាបស់សភាស៊ើបសួរដែលលើកលែងចោទប្រកាន់បានចូលជាស្ថាពរ ហើយមានលេចឡើងនូវវត្ថុបន្ទុកថ្មី ការស៊ើបសួរអាចត្រូវបានបើកឡើងវិញ តាមគំនិតផ្តើមរបស់ព្រះរាជអាជ្ញា។

### ២.២.អានុភាពណាសមោឃដោយសភាស៊ើបសួរ

សភាស៊ើបសួរអាចប្រកាសមិនទទួលពាក្យប្តឹងសុំឲ្យមោឃកម្ម នៅក្នុងករណីដូចតទៅ៖

- ពាក្យប្តឹងសុំគ្មានសំអាងហេតុ
- ពាក្យប្តឹងសុំទាក់ទងនឹងដីកាដែលអាចប្តឹងឧទ្ធរណ៍បាន
- ពាក្យប្តឹងសុំគ្មានមូលកភាពជាក់ស្តែង។

សេចក្តីសម្រេចរបស់សភាស៊ើបសួរមិនអាចតវ៉ាបានទេ។ កាលណាពាក្យប្តឹងសុំត្រូវបានប្រកាសមិនអាចទទួលបានទេ សំណុំរឿងបង្វិលភ្លាមទៅចៅក្រមស៊ើបសួរ។ កាលណាបានទទួលបណ្តឹងសុំមោឃកម្មចំពោះកិច្ច ឬ លិខិតណាមួយនៃនីតិវិធី ប្រសិនបើសភាស៊ើបសួរយល់ព្រមតាមពាក្យប្តឹងសុំនេះ សភាស៊ើបសួរសម្រេចថា តើមោឃកម្មនេះត្រូវធ្វើទៅលើកិច្ច ឬ លិខិតផ្សេងទៀតដែរឬទេ។ កិច្ច ឬ លិខិតដែលត្រូវចាត់ទុកជាមោឃៈ ត្រូវដកចេញពីសំណុំរឿង ហើយតម្កល់ទុកការិយាល័យក្រឡាបញ្ជីណសសភាស៊ើបសួរ។ ក្រោយពេលធ្វើមោឃកម្មរួច សភាស៊ើបសួរអាច៖

- បង្វិលសំណុំរឿងទៅចៅក្រមស៊ើបសួរ
- ដកសមត្ថកិច្ចចៅក្រមស៊ើបសួរ ហើយបញ្ជូនសំណុំរឿងទៅចៅក្រមស៊ើបសួរម្នាក់ផ្សេងទៀតឬ
- បន្តការស៊ើបសួរដោយខ្លួនឯងលើរឿងនោះ

កាលណាសភាស៊ើបសួរសម្រេចថាបន្តការស៊ើបសួរដោយខ្លួនឯងនោះ សភាស៊ើបសួរប្រគល់ភារកិច្ចទៅសមាជិកខ្លួនម្នាក់ ដែលប្រើប្រាស់អំណាចជាចៅក្រមស៊ើបសួរ លើកលែងតែអំណាចនៃការបិទការស៊ើបសួរស្តីពីចៅក្រមស៊ើបសួរ។ កាលណាការស៊ើបសួរហាក់ដូចជាត្រូវបញ្ចប់ សំណុំរឿងនៃនីតិវិធីត្រូវតម្កល់ទុកការិយាល័យក្រឡាបញ្ជីនៃសភាស៊ើបសួរ។ ប្រធាននៃសភាស៊ើបសួរកំណត់កាលបរិច្ឆេទនៃសវនាការ។ សភាស៊ើបសួរបិទការស៊ើបសួរ តាមសាលដីកាដំណោះស្រាយ។ ដីកាដំណោះស្រាយរបស់ចៅក្រមស៊ើបសួរ ត្រូវយកមកអនុវត្តលើសាលដីកា ដំណោះស្រាយរបស់សភាស៊ើបសួរ។ ក្នុងករណីដែលសភាស៊ើបសួរស្រេចដោះលែងជនត្រូវចោទដែលជាប់ឃុំ សេចក្តីសម្រេចនោះត្រូវមានអានុភាពអនុវត្តភ្លាម។

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ក្រោយពីបានធ្វើការ សិក្សាស្រាវជ្រាវលើប្រធានបទស្តីពី កិច្ចស៊ើបសួររឿងក្តីព្រហ្មទណ្ឌក្នុងព្រះរាជាណាចក្រកម្ពុជា រួចមកហើយបានបង្ហាញឲ្យឃើញថា នីតិវិធីនៃការស៊ើបសួរនេះទាមទារឲ្យ មានការប្រព្រឹត្តទៅប្រកបដោយ ទំនួសខុសត្រូវខ្ពស់ ភាពហ្មត់ចត់បំផុត និងការខិតខំប្រឹងប្រែងក្នុងការអនុវត្តវិធានទាំងឡាយដែលច្បាប់បានផ្តល់សិទ្ធិ និងអំណាចក្នុងការស្រាវជ្រាវ ដើម្បីបង្ហាញឲ្យឃើញពីការពិតក្នុងគោលដៅផ្តល់នូវយុត្តិធម៌ជូនដល់ភាគីនៅក្នុងរឿងក្តី។ ចំពោះការស៊ើបសួរវាមានលក្ខណៈស្មុគស្មាញ និងសុំាញ៉ាំមួយចំនួនដែលទាក់ទងទៅនឹង កិច្ចស៊ើបសួរដែលទាក់ទងទៅនឹងបុគ្គល និងកិច្ចស៊ើបសួរនេះ ដោយហេតុថាវាបង្ហាញឲ្យឃើញពីភាពប្រទាក់ក្រឡាគ្នាអំពីបញ្ហាដែលកើតឡើង និងអាចកំណត់ពីភាពខុស ឬត្រូវរបស់ជនត្រូវចោទ ឬដើមបណ្តឹងរដ្ឋប្បវេណីបាន។ ជាងនេះទៅទៀតដើម្បីឲ្យមានប្រសិទ្ធិភាពក្នុងការស្វែងរកភស្តុតាង និងកិច្ចស៊ើបសួរទាក់ទងនឹងបុគ្គល តែងតែតម្រូវឲ្យមានការវាយតម្លៃនូវភស្តុតាងដែលទទួលបានដើម្បីបង្ហាញឲ្យឃើញពីភាពស្របច្បាប់ និងអាចយកមកប្រើប្រាស់បានក្នុងគោលដៅបង្ហាញការពិត។ ម្យ៉ាងវិញទៀត ចៅក្រមស៊ើបសួរត្រូវតែព្យាយាមធ្វើសំណុំរឿងក្តីដែលខ្លួនបំពេញកិច្ចប្រព្រឹត្តទៅបានរលូនក្នុងការស្វែងរកភស្តុតាងក្នុងការដោះបន្ទុកនិងដាក់បន្ទុក។

លើសពីនេះទៅទៀត ចំពោះការអនុវត្តនូវវិធានការនិរន្តរាយដើម្បីទទួលបាននូវប្រសិទ្ធភាព និងលក្ខខណ្ឌចាំបាច់បំផុតទៅនឹងមូលដ្ឋានក្នុងការអនុវត្តនោះ តម្រូវឲ្យចៅក្រមស៊ើបសួរត្រូវធ្វើការអនុវត្តកិច្ចនេះស្របទៅនឹងមូលដ្ឋានច្បាប់ ជាពិសេស ទៅតាមក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧។ មិនតែប៉ុណ្ណោះ នៅក្នុងករណីផ្សេងទៀតក៏ទាមទារឲ្យចៅក្រមស៊ើបសួរគប្បីមានការសិក្សា និងប្រើយន្តការនានាឲ្យបានត្រឹមត្រូវ ជាពិសេសពាក់ព័ន្ធទៅនឹងសិទ្ធិសេរីភាពរបស់ជនត្រូវចោទ។ ម្យ៉ាងវិញទៀត ជាគោលការណ៍នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចៅក្រមស៊ើបសួរគួរជៀសវាងការស្រាវជ្រាវបទល្មើសណាមួយដែលមិនមានដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់តំណាងអយ្យការ ជាពិសេសករណីលេចឡើងនូវអង្គហេតុថ្មីពេលស្រាវជ្រាវ។ នៅក្នុងនោះផងដែរ ការអនុវត្តនីតិវិធីនៃការស៊ើបសួរ ជាកត្តាមួយយ៉ាងសំខាន់ដែលទាមទារឲ្យចៅក្រមស៊ើបសួរអនុវត្តដោយ តឹងរឹងបំផុតដោយ សារតែការអនុវត្តមិនមែនមានគោលដំណងតែដើម្បីការពារទៅលើភាគីម្ខាងនោះទេ គឺដើម្បីលាតត្រដាងការពិតដែលត្រូវបានធ្វើឡើងក្នុងនាមជាបុគ្គលឯករាជ្យ។

ផ្ទុយមកវិញក្នុង **“នីតិវិធីស៊ើបសួររឿងក្តីព្រហ្មទណ្ឌបច្ចុប្បន្នក្នុងព្រះរាជាណាចក្រកម្ពុជា”** នេះមិនមែនមានតែចៅក្រមស៊ើបសួរតែមួយដំណាក់កាលនោះទេ ដែលមានន័យថានៅមានដំណាក់កាលទីពីរមួយទៀតគឺ សភាស៊ើបសួរ។ ជាការពិតណាស់សភាស៊ើបសួរ ដែលមានជាស្ថាប័នមួយដ៏សំខាន់ដើម្បីធ្វើការស៊ើបសួរបន្ថែមនៅពេលដែលមានប្តឹងតវ៉ាទៅនឹងសេចក្តីសម្រេចរបស់សាលាដំបូង ជាពិសេសការធ្វើពិនិត្យទៅ លើដំណើរការរឿងក្តីដែលមានការប្តឹងតវ៉ាទៅនឹងសេចក្តីសម្រេចរបស់សាលាដំបូងជាពិសេសការធ្វើការពិនិត្យទៅលើដំណើរការរឿងក្តីដែលចៅក្រមស៊ើបសួរបានធ្វើកន្លងមក ថាមានភាពត្រឹមត្រូវដែរឬទេ។ ក្នុងករណីដែលដំណើរការនៃការស៊ើបសួររបស់ចៅក្រមមានភាពមិនប្រក្រតី ឬកិច្ចដែលចៅក្រមធ្វើការស៊ើបសួរនោះវាមានលក្ខណៈផ្ទុយទៅនឹងអត្ថបទច្បាប់ដែលបានបញ្ញត្តិ ក្នុងនោះសភាស៊ើបសួរមានសិទ្ធិចេញសាលដីកាសម្រេចថាកិច្ចដែលចៅក្រមស៊ើបសួរនោះធ្វើចាត់ទុកមោឃៈ។ ប៉ុន្តែកិច្ចស៊ើបសួររបស់ចៅក្រមស៊ើបសួរមានលក្ខណៈត្រឹមត្រូវតាមនីតិវិធីសព្វគ្រប់ហើយ ហើយមានបុគ្គលបានដាក់ពាក្យប្តឹងសុំសភាស៊ើបសួរ ពេលនោះពាក្យបណ្តឹងដែលបានប្តឹងមកនោះពុំមានប្រសិទ្ធភាពដែលតម្រូវឲ្យសភាស៊ើបសួរធ្វើអធិបញ្ញាឲ្យចៅក្រមស៊ើបសួរឡើងវិញនោះទេ។

ហេតុដូច្នេះ ការបង្កើតឲ្យមានសភាស៊ើបសួរក្នុងគោលបំណង ធានាឲ្យការស៊ើបសួរមានភាពសុក្រឹត្យ និង យុត្តិធម៌ ដោយសារតែចៅក្រមស៊ើបសួរ គឺជាកត្តាចម្បងចាំបាច់បំផុតសម្រាប់ប្រទេសជាតិ ដែលបានផ្តល់ជំនួយផ្នែក សេដ្ឋកិច្ចដល់ប្រជាពលរដ្ឋឲ្យមានសេរីភាពក្នុងការមាន ឬមិនមានមេធាវីការពារខ្លួន ឲ្យទទួលបាននូវភាពយុត្តិធម៌មួយ ដែលមានលក្ខណៈសមស្របត្រូវអនុវត្តដោយបុគ្គលឯករាជ្យដើម្បីធ្វើការស្រាវជ្រាវនៅក្នុងរឿងព្រហ្មទណ្ឌនេះ។

សរុបមក កិច្ចស៊ើបសួររឿងក្តីព្រហ្មទណ្ឌ នេះពិតជាមានសារៈសំខាន់ណាស់ដែលអាចបង្ហាញ និងការស្វែងរក ជនល្មើសវាទាមទារឲ្យមានការសហការ គ្នារវាងបុគ្គលដែលពាក់ព័ន្ធក្នុងរឿងក្តី និងបុគ្គលដែលដោះស្រាយក្នុងរឿងក្តីតស៊ូ ស្វែងរកនូវភស្តុតាងយ៉ាងយកចិត្តទុកដាក់និងអត់ធ្មត់បំផុតរបស់បុគ្គលទាំងនេះជាពិសេសចៅក្រមស៊ើបសួរ។ ទោះបីជា យើងខ្ញុំសូមធ្វើការគាំទ្រ ឲ្យមាននីតិវិធីនៃការស៊ើបសួរនេះដែលត្រូវបានអនុវត្តដោយចៅក្រមស៊ើបសួរ និងសភាស៊ើបសួរ និងសភាស៊ើបសួរដើម្បីសម្រួលដល់ជីវភាពរបស់ប្រជាពលរដ្ឋនៃព្រះរាជាណាចក្រកម្ពុជា ដែលមាននីតិវិធីនេះមានលក្ខ ណៈសមស្របណាស់ សម្រាប់ប្រទេសយើងដែលជាប្រទេសកំពុងអភិវឌ្ឍន៍។

# អនុសាសន៍

# អនុសាសន៍

ក្រោយបីឆ្លងកាត់តាមការស្រាវជ្រាវ និងបានបកស្រាយជាច្រើនអំពីកិច្ចស៊ើបសួរក្នុង រឿងក្តីព្រហ្មទណ្ឌសង្កេតឃើញថា នីតិវិធីស៊ើបសួរក្នុងរឿងព្រហ្មទណ្ឌនេះជាលក្ខណៈល្អពិតប្រាកដមែន។ ទោះជាយ៉ាងណា ក្នុងនីតិវិធីអនុវត្ត ក្នុងពេលមានបទល្មើសព្រហ្មទណ្ឌ ក៏នៅតែមានចំណុចមួយចំនួនលេចឡើងជាចន្លោះប្រហោងតម្រូវឲ្យមានការកែសម្រួលវិញផងដែរ នៅពេលដែលកំពុងអនុវត្ត និងការកើតឡើងនូវបញ្ហាប្រឈមនាពេលអនាគត។ យើងបានដឹងហើយថា ប្រទេសកម្ពុជាមានបទល្មើសកើតឡើងជាច្រើនប្រភេទ ហើយបទល្មើសទាំងអស់នោះមិនមែនសុទ្ធ តែរកឃើញតាមរយៈការស៊ើបសួរ ដើម្បីស្វែងរកចាប់ជនល្មើសយកមកដាក់ទោសបានទាំងអស់នោះទេ ដោយសារមានបញ្ហាមួយចំនួនបានធ្វើឲ្យមានការរាំងស្ទះដល់ដំណើរការនេះរួមមាន ការខ្វះភស្តុតាង ការខ្វះនូវបច្ចេកទេស ខ្វះឧបករណ៍ដើម្បីស្រាវជ្រាវ ការធ្វើកោសល្យវិច័យ ឬ បណ្តាលមកពីការខ្វះនូវការយកចិត្តទុកដាក់របស់បុគ្គលដែលធ្វើការដោះស្រាយរឿងក្តី ជាពិសេសចៅក្រមស៊ើបសួរ និងសភាស៊ើបសួរ និងសភាស៊ើបសួរដែលជាហេតុបណ្តាលឲ្យដំណើរការរឿងក្តីព្រហ្មទណ្ឌមានភាពយឺតយ៉ាវ និងចំណាយពេលវេលាអស់ជាច្រើន និងកត្តាជាច្រើនទៀតមានដូចជា បញ្ហាច្បាប់បញ្ហានយោបាយក្នុងសង្គម ឬបញ្ហាអំពើពុករលួយដែលកើតមាននៅក្នុងសង្គមនៅតាមបណ្តាតុលាការមួយចំនួន ដែលធ្វើឲ្យអ្នកធ្វើមិនបានទទួលខុសត្រូវនូវកំហុស ចំណែកអ្នកដែលទទួលគឺជាមនុស្សស្មោះត្រង់ និងគ្មានកំហុស។

ម្យ៉ាងវិញទៀត យើងសង្កេតឃើញថាទ្រឹស្តី និងការអនុវត្តជាក់ស្តែង គឺមានលក្ខណៈដាច់ស្រលះដោយមិនមានភាពដូចគ្នាទាំងអស់នោះទេ ហេតុដូច្នេះហើយយើងខ្ញុំសូមសំណូមពរដល់អ្នកដែលអនុវត្តទាំងអស់ ជាពិសេសចៅក្រមស៊ើបសួរក៏ដូចជាសភាស៊ើបសួរផ្ទាល់ ដែលមានសិទ្ធិអធិបញ្ញាមកចៅក្រមស៊ើបសួរ ដែលបំពេញកិច្ចនីតិវិធីអនុវត្តកិច្ចការនេះប្រកបដោយភាពយុត្តិធម៌ និងមនិសិការវិជ្ជាជីវៈ។ ដោយក្នុងដំណាក់កាលនៃការស៊ើបសួរនេះមានលក្ខណៈសំខាន់ណាស់ក្នុងការស្វែងរកយុត្តិធម៌ដើម្បីផ្តល់ជូនគូភាគីនៅក្នុសំណុំរឿង ហើយដំណាក់កាលនេះក៏មានចេញនូវវិធានការនិរន្តរាយដែលជាវិធានការមួយដែលតម្រូវឲ្យមានការចាប់ និងការដាក់ជនត្រូវចោទក្នុងឃុំ និងត្រួតពិនិត្យតាមផ្លូវតុលាការជាដើម ដែលចៅក្រមស៊ើបសួរជាអ្នកអនុវត្ត។ ដូច្នេះ បើមិនអនុវត្តមិនមានភាពប្រក្រតីនោះទេ វានឹងបណ្តាលឲ្យមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សិទ្ធិ និងសេរីភាពជាមូលដ្ឋានរបស់ជនត្រូវចោទ។

ហេតុដូច្នេះហើយ ទើបតម្រូវឲ្យស្ថាប័នតុលាការ ក៏ដូចជាស្ថាប័នរាជរដ្ឋាភិបាលត្រូវតែធ្វើការរៀបចំឡើងវិញនូវកម្មវិធីសិក្ខាសាលា និងវគ្គបណ្តុះបណ្តាលផ្សេងៗ ទោលើវិស័យច្បាប់ជាពិសេស គឺធ្វើការទំនាក់ទំនងជាមួយដៃគូ ដែលជាប្រទេសមានភាពរីកចម្រើនជាងប្រទេសយើងដើម្បីផ្លាស់ប្តូរបទពិសោធន៍គ្នាទៅវិញទៅមកក្នុងវិស័យតុលាការ ដើម្បីឲ្យវិជ្ជាជីវៈរបស់ចៅក្រមកាន់តែមានប្រសិទ្ធិភាព។

# ឯកសារយោង

## ១.បទដ្ឋានគតិយុត្ត

- រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា, ថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣
- ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា,លេខ នស/រកម/១១០៩/០២២,ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩
- ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា,លេខ នស/រកម/០៨០៧/០២៤, ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ ២០០៧
- ច្បាប់ស្តីពីវិសោធនកម្ម មាត្រា ២៤៧, ៣៦៨, ៣៧២និងមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា,លេខ នស/រកម/០៦១៣/០០៩,ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១៣
- ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ,លេខ នស/រកម/០៧១៤/០១៥,ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤
- ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា,លេខ នស/រកម/០៧១៤/០១៦, ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤
- ច្បាប់ស្តីពីយុត្តិធម៌អនីតិជន,លេខ នស/រកម/០៧១៦/០០៩,ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១៦

## ២.សៀវភៅនិងស្នាដៃនិពន្ធ

- អ៊ុន បូផា, នីតិភស្តុតាង,បោះពុម្ពលើកទី២ ឆ្នាំ២០១៦
- រុន ពណ្ណារិទ្ធ និងចាំងស៊ីណាត,នីតិវិធីព្រហ្មទណ្ឌ, សាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ,២០១៥ ២០១៦

# បញ្ជីរាយនាមឧបសម្ព័ន្ធ

**ឧបសម្ព័ន្ធទី១ គម្រូដីកាតំណាងអយ្យការ**

១.ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ

២.ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម

៣.ដីកាចាត់ឲ្យបំពេញកិច្ចស៊ើបសួរបន្ថែម

៤.ដីកាសន្និដ្ឋានសុំឲ្យឃុំខ្លួនបណ្ដោះអាសន្ន

៥.ដីកាសន្និដ្ឋានស្ថាពរ

**ឧបសម្ព័ន្ធទី២ គម្រូដីកា និងកំណត់ហេតុចៅក្រមស៊ើបសួរ**

១.ដីកាសម្រេចចាត់តាំងចៅក្រមស៊ើបសួរ

២.ដីកាកោះ

៣.ដីកាបង្គាប់ឲ្យចូលខ្លួន

៤.ដីកាបង្គាប់ឲ្យនាំខ្លួន

៥.ដីកាបញ្ជាប់ឲ្យនាំខ្លួន

៦.ដីកាបង្គាប់ឲ្យចាប់ខ្លួន

៧.ដីកាបញ្ជាប់ឲ្យចាប់ខ្លួន

៨.ដីកាបញ្ជូន

៩.ដីកាសម្រេចឲ្យឃុំខ្លួនបណ្ដោះអាសន្ន

១០.ដីកាបង្គាប់ឲ្យឃុំខ្លួនបណ្ដោះអាសន្ន

១១.ដីកាសម្រេចមិនឃុំខ្លួនបណ្ដោះអាសន្ន

១២ ដីកាសម្រេចអនុញ្ញាតឲ្យនៅក្រៅឃុំបណ្ដោះអាសន្ន

១៣.ដីកាសម្រេចដាក់ជនត្រូវចោទឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ

១៤.ដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្នបន្ត

១៥.ដីកាសម្រេចពន្យារពេលឃុំខ្លួនបណ្ដោះអាសន្ន

១៦.ដីកាបង្គាប់ឲ្យឃុំខ្លួនបណ្ដោះអាសន្នបន្ត

១៧.ដីកាសម្រេចដោះលែងឲ្យនៅក្រៅឃុំ

១៨.ដីកាបង្គាប់ឲ្យដោះលែង

១៩.ដីកាសម្រេចមិនព្រមដោះលែងឲ្យនៅក្រៅឃុំ

២០.ដីកាចាត់ឲ្យស៊ើបសួរ

២១ ដីកាបញ្ជូនឲ្យឆ្លើយ

២២.ដីកាបង្គាប់ឲ្យស្រាវជ្រាវនិងបំពេញសាវតាជាតិ

២៣.ដីកាចាត់តាំងអ្នកជំនាញ

២៤.ដីកាទទួលស្គាល់មេធាវី ឬអ្នកការពារ
២៥.ដីកាសម្រេចប្រគល់វត្ថុចាប់យក
២៦.លិខិតជូនដំណឹងអំពីការបិទការស៊ើបសួរ
២៧.ដីកាបញ្ជូនព័ត៌មាន
២៨.ដីកាបញ្ជូនសំណុំរឿងពិនិត្យ
២៩.ដីកាសម្រេចលើកលែងការចោទប្រកាន់
៣០.ដីកាសម្រេចលើកលែងការចោទប្រកាន់
៣១.លិខិតជូនដំណឹងពីការសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះ
៣២.ដីកាបញ្ជូនសំណុំរឿងទៅជំនុំជម្រះ
៣៣.ដីកាបង្គាប់រក្សាទុកជនត្រូវចោទឲ្យនៅពន្ធនាគារជាបណ្តោះអាសន្ន
៣៤.លិខិតជូនដំណឹងស្តីពីការសម្រេចដាក់ឲ្យស្ថិតក្រោមការពិនិត្យ
៣៥.ដីកាសម្រេចដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យ
៣៦.កំណត់ហេតុស្តីពីការសួរចម្លើយតទល់
៣៧.កំណត់ហេតុស្តីពីការស្តាប់ចម្លើយសាក្សី
៣៨.កំណត់ហេតុស្តីពីការសួចម្លើយជនត្រូវចោទ
៣៩.កំណត់ហេតុស្តីពីការស្តាប់សម្លើយដើមបណ្តឹងរដ្ឋប្បវេណី និងជនរងគ្រោះ

**គម្រូដីកាសនាស៊ើបសួរ**

១.ដីកាសម្រេច

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

បន្ទប់ស៊ើបសួរ "ម"
លេខ៖ 2835 "ម" ដដ

# ដីកាលើកលែងចោទប្រកាន់

យើង គួយ សៅ អនុប្រធានសាលាដំបូងរាជធានីភ្នំពេញ និងជាចៅក្រមស៊ើបសួរ ដោយមានលោកស្រី ឈុយ អង្គាទ្រីក ជាក្រឡាបញ្ជី។

- បានឃើញ បញ្ញត្តិមាត្រា ២៤៧ថ្មី នៃច្បាប់ស្តីពីវិសោធនកម្ម នៃក្រមនីតិវិធីព្រហ្មទណ្ឌ។
- បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ ១៨៤៦ ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២១។
- បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ១៩២២ អ.យ.ថ ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២១ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។
- បានឃើញ សំណុំរឿងស៊ើបសួរលេខ ១៣៨៥ ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២១។
- បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ ២០៦០ អ.យ.ថ ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០២១ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ដែលទាក់ទងនឹងជនត្រូវចោទដូចខាងក្រោម៖

ឈ្មោះ **មាន ពេជ្រវីតា** ហៅ **យូប៊ី** ភេទស្រី អាយុ ២០ឆ្នាំ សញ្ជាតិខ្មែរ មុខរបរ និស្សិត ទីកន្លែងកំណើត សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ ទីលំនៅបច្ចុប្បន្ន ផ្ទះលេខ ១៤៦ សង្កាត់ទឹកល្អក់ទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ នៅលីវ ឪពុកឈ្មោះ **ហេង សេរីម៉េង** "រស់" ម្តាយឈ្មោះ **ម៉េង ច័ន្ទនិមល** "រស់" ជានីតិជន ទោសពីមុនគ្មាន ដែលត្រូវបានចោទប្រកាន់ពីបទ **លួចមានស្ថានទម្ងន់ទោស** ប្រព្រឹត្តនៅចំណុចផ្លូវ ១៣៨ កែងផ្លូវ ២៥៩ ស្ថិតនៅក្រុម ២៨ ភូមិ ១០ សង្កាត់ទឹកល្អក់ទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ជាបទល្មើសព្រហ្មទណ្ឌ និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ។ (ក្រៅឃុំ)

- ដីកាសម្រេចដោះលែងឱ្យនៅក្រៅឃុំលេខ ២២៩៧ "ម" ដពស ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២១។
- ដីកាបង្គាប់ឱ្យដោះលែងលេខ ៣២៧២ "ម" ដយង ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២១។

- ជនរងគ្រោះ ឈ្មោះ **ហេង សៀ** ភេទប្រុស អាយុ ៥៩ឆ្នាំ សញ្ជាតិខ្មែរ ទីលំនៅបច្ចុប្បន្ន ផ្ទះលេខ៧៥ ផ្លូវ២១៧ ភូមិទ្រា សង្កាត់ស្ទឹងមានជ័យទី១ ខណ្ឌមានជ័យ រាជធានីភ្នំពេញ។

- មេធាវី ឈ្មោះ **មាស ស៊ីផន** អត្តលេខ ៧៧៥ មេធាវី ឈ្មោះ **មាស សោភា** មេធាវី ឈ្មោះ **ម៉ម ចាន់ណែត** មេធាវី ឈ្មោះ **អ៊ុំ រតនា** អត្តលេខ ៨៥៦ មេធាវី ឈ្មោះ **សួស វិទ្យា** អត្តលេខ ២១៦៦ មេធាវី ឈ្មោះ **វិរោចន៍ សុផង់** និង មេធាវី ឈ្មោះ **គង់ លាងជូ** ជាសហមេធាវីការពារសិទ្ធិឱ្យជនត្រូវចោទ។
- មេធាវី ឈ្មោះ **ឡុយ សុគន្ធ** អត្តលេខ ៤២២ មេធាវី ឈ្មោះ **ពុធ ធារី** និងមេធាវី ឈ្មោះ **វណ្ណ ឥន្ទសីហា** ជាសហមេធាវីការពារសិទ្ធិឱ្យជនរងគ្រោះ។

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អយ្យការអមសាលាដំបូង
រាជធានីភ្នំពេញ

សំណុំរឿងព្រហ្មទណ្ឌលេខ ៣២១០
ចុះថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១៥
លេខ [illegible] . អ . ជ . ក

# ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យជំនុំជម្រះ

**យើង ខែម សុខា ព្រះរាជអាជ្ញា នៃ អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ**

-បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ ៣២១០ ចុះថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១៥ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញ ពាក្យបណ្ដឹង ចុះថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ២០១៥ របស់ឈ្មោះ ឈុន ណារី ។

**ក្រោយពីបានពិនិត្យឯកសារខាងលើ**

យល់ឃើញថា មានជនត្រូវចោទដូចតទៅ:

១-ឈ្មោះត្រកូល-នាមខ្លួន ស្រី សុភា ភេទប្រុស អាយុ ៦១ឆ្នាំ ជនជាតិខ្មែរ មុខរបរ ប្រធានក្រុមប្រឹក្សាភិបាលក្រុមហ៊ុន ៣៧G មានទីលំនៅបច្ចុប្បន្ននៅផ្ទះលេខ [illegible] ផ្លូវលេខ [illegible] សង្កាត់ [illegible] ខណ្ឌ [illegible] រាជធានីភ្នំពេញ ជាជនជាប់ចោទ។

២-ឈ្មោះត្រកូល-នាមខ្លួន ស្រី ធន្នូ ភេទប្រុស អាយុ ៣៧ឆ្នាំ ជនជាតិខ្មែរ មុខរបរ នាយកក្រុមហ៊ុន ៣៧G [illegible] មានទីលំនៅបច្ចុប្បន្ននៅផ្ទះលេខ [illegible] ផ្លូវលេខ [illegible] សង្កាត់ [illegible] ខណ្ឌ [illegible] រាជធានីភ្នំពេញ ជាជនជាប់ចោទ។

ជនត្រូវចោទខាងលើ[1] [illegible] ឈ្មោះ ឈុន ណារី ភេទស្រី អាយុ ៣៧ឆ្នាំ បាន [illegible] ១ ហិកតា ( [illegible] ) [illegible] ឈ្មោះ ស្រី [illegible] ដែលជាដីរបស់ក្រុមហ៊ុន ៣៧G ពីឈ្មោះ ស្រី ធន្នូ ដោយមានការទុកចិត្ត ឈ្មោះ ឈុន ណារី [illegible] ពីឈ្មោះ ស្រី សុភា ដែលជាប្រធានក្រុមប្រឹក្សាភិបាលក្រុមហ៊ុន ៣៧G នោះទេ [illegible] ។ នៅឆ្នាំ២០១៥ នេះ ឈ្មោះ ឈុន ណារី [illegible]

[1] [illegible]

-១-

អាសយដ្ឋានៈ [illegible] ភ្នំពេញ
Address : #25 27, Street 217 213, Sangkat Veal Vong, Khan 7 Makara, Phnom Penh, Cambodia
ទូរសារ-ទូរស័ព្ទ (៨៥៥)-២៣ ៨៨ ២០ ៥៩
Fax-Phone : (855)-23 88 20 59

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

# ដីកាសម្រេចមិនឃុំខ្លួនបណ្តោះអាសន្ន

បន្ទប់ស៊ើបសួរ (ត)

លេខ...០៥៧... "ត" ដ.ព.ស

យើង រស់ ពិសិដ្ឋ ចៅក្រមស៊ើបសួរសាលាសាលាដំបូងរាជធានីភ្នំពេញ

អមដោយលោកស្រី ទី ឈីឡា ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

-បានឃើញ មាត្រា ២០៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើប្រាស់តាមព្រះរាជក្រមលេខ នស/រកម០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ ។

-បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ ៥៧៥១ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៨ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញ សំណុំរឿងស៊ើបសួរលេខ ៣១៨៨ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៩ របស់សាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ២៩៥៩ អ.យ.ខ ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៩ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ បានសម្រេចបើកការស៊ើបសួរលើជនត្រូវចោទ ៖

ឈ្មោះ សឿង រតនា ភេទប្រុស អាយុ៣៤ឆ្នាំ ជនជាតិខ្មែរ មុខរបរអាជីវករ ទីកន្លែងកំណើតនៅស្រុកបាណនខេត្តបាត់ដំបង អាសយដ្ឋានស្នាក់នៅផ្ទះលេខ៦០ ផ្លូវលេខ២៦៥ សង្កាត់ទឹកល្អក់២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ឪពុកឈ្មោះ សឿង ហៀង (ស្លាប់) ម្តាយឈ្មោះ តាំង សៀមហុង (រស់) នៅលីវ ជាតិជន ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ "គ្មាន" ។

ដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យពីបទ "មិនបំពេញកាតព្វកិច្ចចំពោះឧបករណ៍អាចជួញដូរបាន" ប្រព្រឹត្តនៅចំណុចរាជធានីភ្នំពេញ កាលពីថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៧ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៣១ នៃច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាន ។

-បានឃើញ កំណត់ហេតុបង្ហាញខ្លួនលើកដំបូង ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញ កំណត់ហេតុសួរយកចម្លើយជនត្រូវចោទ ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញ កំណត់ហេតុដេញដោលចំពោះមុខជនត្រូវចោទ ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញ មាត្រា ២០៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ជាគោលការណ៍ជនត្រូវចោទត្រូវមានសេរីភាព ។

( ក្រោយពីបានស៊ើបសួរ និងពិនិត្យពិចារណាត្រឹមត្រូវតាមច្បាប់ហើយ )

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកំពត

លេខ: ៦២

## ដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន

យើង **ហុខ សុគុណា ខឌ្ឍនា** ចៅក្រមនៃសាលាដំបូងខេត្តកំពត ។

- បានឃើញមាត្រា ៥៣០ , ៥៤៨ , ៥៤៩ និងមាត្រាពាក់ព័ន្ធនៃក្រមនីតិវិធីរដ្ឋប្បវេណី ។

- បានឃើញពាក្យសុំដីកាសម្រេចរក្សាការពារ ចុះថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ២០១៦ របស់ព្រះអង្គម្ចាស់ក្សត្រីយ៍ នរោត្តម ម៉ារី ។

- បានឃើញសំណុំរឿងរក្សាការពារលេខ: ៦០ ចុះថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ២០១៦ របស់សាលាដំបូងខេត្តកំពត ។

**<u>កម្មវត្ថុ</u>**: - សុំដីកាសម្រេចរក្សាការពារចាត់ចែងជាបណ្ដោះអាសន្នលើដីទំហំ ១៥០,៥១៧ម² ដែលមានប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ ក.៣០០២១៣២ , ក.៣០០២១៣៣ , ក.៣ ០០២១៣៤ , ក.៣ ០០២១៣៥ ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ២០០៣ ស្ថិតនៅភូមិអង្គ្រង ឃុំកំពង់ត្រាចខាងលិច ស្រុកកំពង់ត្រាច ខេត្តកំពត ( បច្ចុប្បន្នអាចកែប្រែតំបន់រដ្ឋបាល មកជា ភូមិអូរស្លែង ឃុំដំណាក់កន្ទួតខាងជើង ស្រុកកំពង់ត្រាច ខេត្តកំពត ) ដោយហាមឃាត់មិនឲ្យលក់ ដូរ ទិញ ផ្ទេរសិទ្ធិ ធ្វើសន្តតិកម្ម អ៊ីប៉ូតែក បញ្ចាំ កាប្យ ឬ ចាត់ចែងផ្សេងៗ ។

- សុំគ្រប់គ្រងបណ្ដោះអាសន្នលើដីទំហំ ១៥០,៥១៧ម² ដែលមានប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ ក.៣ ០០២១៣២ , ក.៣ ០០២១៣៣ , ក.៣ ០០២១៣៤ , ក.៣ ០០២១៣៥ ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ២០០៣ ស្ថិតនៅភូមិអង្គ្រង ឃុំកំពង់ត្រាចខាងលិច ស្រុកកំពង់ត្រាច ខេត្តកំពត ( បច្ចុប្បន្នអាចកែប្រែតំបន់រដ្ឋបាលមកជា ភូមិអូរស្លែង ឃុំដំណាក់កន្ទួតខាងជើង ស្រុកកំពង់ត្រាច ខេត្តកំពត ) ។

**ភាគី**: - ម្ចាស់បំណុល ព្រះអង្គម្ចាស់ក្សត្រីយ៍ នរោត្តម ម៉ារី ។

ដោយមានលោក **ផែង ហេង** ដែលមានការិយាល័យផ្ទះលេខ ១៤CEO ផ្លូវលេខ ៣៨៤ សង្កាត់ទួលស្វាយព្រៃ១ ខណ្ឌចំការមន រាជធានីភ្នំពេញ ជាមេធាវីតំណាងដោយអាណត្តិ ។

- កូនបំណុលឈ្មោះ

១- ឈ្មោះ **អេង វី** ភេទប្រុស អាយុ ៤០ឆ្នាំ ទីលំនៅភូមិអូរស្លែង ឃុំដំណាក់កន្ទួតខាងជើង

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អយ្យការអមសាលាដំបូង

រាជធានីភ្នំពេញ

លេខ ៣១៦៧ អ.យ.ដ

# ដីកាបញ្ជូន

គោរពជូន ៖ ឯកឧត្តមប្រធាននាយកដ្ឋាននគរបាលព្រហ្មទណ្ឌ នៃក្រសួងមហាផ្ទៃ

| ល.រ | រាយឈ្មោះលិខិត | ចំនួន | សេចក្តីផ្សេងៗ |
|---|---|---|---|
| ០១ | -ដីកាបញ្ជាឲ្យចូលខ្លួនលេខ ១៣៤ អ.យ.ដ ចុះថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០២១ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។ | ០១ ច្បាប់ | "ដើម្បីអនុវត្ត" |
| | | | |

ថ្ងៃ [illegible] ខែជេស្ឋ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ២០២១

ជ.ព្រះរាជអាជ្ញា

ស៊ិត-ចន្ធា

ព្រះរាជអាជ្ញារង

16/06/21

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

# ដីកាសម្រេចមិនឃុំខ្លួនបណ្ដោះអាសន្ន

បន្ទប់ស៊ើបសួរ (ត)

លេខ...០៥៧... "ត" ដ.ព.ស

យើង រស់ ពិសិដ្ឋ ចៅក្រមស៊ើបសួរសាលាសាលាដំបូងរាជធានីភ្នំពេញ

អមដោយលោកស្រី ទី លីឡា ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

-បានឃើញ មាត្រា ២០៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើប្រាស់តាមព្រះរាជក្រមលេខ នស/រកម០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ ។

-បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ ៥៧៥១ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៨ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញ សំណុំរឿងស៊ើបសួរលេខ ៣១៨៨ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៩ របស់សាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ២៩៥៩ អ.យ.ខ ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៩ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ បានសម្រេចបើកការស៊ើបសួរលើជនត្រូវចោទ ៖

ឈ្មោះ សឿង រតនា ភេទប្រុស អាយុ៣៤ឆ្នាំ ជនជាតិខ្មែរ មុខរបរអាជីវករ ទីកន្លែងកំណើតនៅស្រុកបាណន់ ខេត្តបាត់ដំបង អាសយដ្ឋានស្នាក់នៅផ្ទះលេខ៦០ ផ្លូវលេខ២៦៥ សង្កាត់ទឹកល្អក់២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ឪពុកឈ្មោះ សឿង ហៀង (ស្លាប់) ម្ដាយឈ្មោះ តាំង សៀមហុង (រស់) នៅលីវ ជានីតិជន ប្រវត្តិនៃការផ្ដន្ទាទោសដោយតុលាការ "គ្មាន" ។

ដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យពីបទ "មិនបំពេញកាតព្វកិច្ចចំពោះឧបករណ៍អាចជួញដូរបាន" ប្រព្រឹត្តនៅចំណុចរាជធានីភ្នំពេញ កាលពីថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៧ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ២៣១ នៃច្បាប់ស្ដីពីឧបករណ៍អាចជួញដូរបាន ។

-បានឃើញ កំណត់ហេតុបង្ហាញខ្លួនលើកដំបូង ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញ កំណត់ហេតុសួរយកចម្លើយជនត្រូវចោទ ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញ កំណត់ហេតុដេញដោលចំពោះមុខជនត្រូវចោទ ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញ មាត្រា ២០៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ជាគោលការណ៍ជនត្រូវចោទត្រូវមានសេរីភាព ។

( ក្រោយពីបានស៊ើបសួរ និងពិនិត្យពិចារណាត្រឹមត្រូវតាមច្បាប់ហើយ )

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

បន្ទប់ស៊ើបសួរ "ម"

លេខៈ 2835 "ម" ដជ

# ដីកាលើកលែងចោទប្រកាន់

យើង **កុយ សៅ** អនុប្រធានសាលាដំបូងរាជធានីភ្នំពេញ និងជាចៅក្រមស៊ើបសួរ ដោយមានលោកស្រី **ឆុយ អង្គារត្នា** ជាក្រឡាបញ្ជី។

- បានឃើញ បញ្ញត្តិមាត្រា ២៤៧ថ្មី នៃច្បាប់ស្តីពីវិសោធនកម្ម នៃក្រមនីតិវិធីព្រហ្មទណ្ឌ។
- បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ ១៨៤៦ ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២១។
- បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ១៤២២ អ.យ.ច ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២១ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។
- បានឃើញ សំណុំរឿងស៊ើបសួរលេខ ១៣៨៥ ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២១។
- បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ ២០៦០ អ.យ.ច ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០២១ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ដែលទាក់ទងនឹងជនត្រូវចោទដូចខាងក្រោម៖

ឈ្មោះ **មាន ពេជ្ររីតា ហៅ យូប៊ី** ភេទស្រី អាយុ ២០ឆ្នាំ សញ្ជាតិខ្មែរ មុខរបរ និស្សិត ទីកន្លែងកំណើត សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ ទីលំនៅបច្ចុប្បន្ន ផ្ទះលេខ ១៤៦ សង្កាត់ទឹកល្អក់ទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ នៅលើវឪពុកឈ្មោះ **ហេង សេរីម៉េង** "រស់" ម្តាយឈ្មោះ **ម៉េង ច័ន្ទនិមល** "រស់" ជាទីតិជន ទោសពីមុនគ្មាន ដែលត្រូវបានចោទប្រកាន់ពីបទ **លួចមានស្ថានទម្ងន់ទោស** ប្រព្រឹត្តនៅចំណុចផ្លូវ ១៣៨ កែងផ្លូវ ២៥៩ ស្ថិតនៅក្រុម ២៨ ភូមិ ១០ សង្កាត់ទឹកល្អក់ទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ជាបទល្មើសព្រហ្មទណ្ឌ និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ។ (ក្រៅឃុំ)

- ដីកាសម្រេចដោះលែងឱ្យនៅក្រៅឃុំលេខ ២២៩៧ "ម" ដពស ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២១។
- ដីកាបង្គាប់ឱ្យដោះលែងលេខ ៣២៧២ "ម" ដឃដ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២១។

- ជនរងគ្រោះ ឈ្មោះ **ហេង សៀ** ភេទប្រុស អាយុ ៥៩ឆ្នាំ សញ្ជាតិខ្មែរ ទីលំនៅបច្ចុប្បន្ន ផ្ទះលេខ៧៥ ផ្លូវ២១៧ ភូមិទ្រា សង្កាត់ស្ទឹងមានជ័យទី១ ខណ្ឌមានជ័យ រាជធានីភ្នំពេញ។

- មេធាវី ឈ្មោះ **មាស ស៊ីផន** អត្តលេខ ៧៧៥ មេធាវី ឈ្មោះ **មាស សោភា** មេធាវី ឈ្មោះ **ម៉ម ចាន់ណែត** មេធាវី ឈ្មោះ **អ៊ុំ រតនា** អត្តលេខ ៨៥៦ មេធាវី ឈ្មោះ **សួស វិឡា** អត្តលេខ ២១៦៦ មេធាវី ឈ្មោះ **វិរោចន៍ សុផង់** និងមេធាវី ឈ្មោះ **គង់ លាងជួ** ជាសហមេធាវីការពារសិទ្ធិឱ្យជនត្រូវចោទ។
- មេធាវី ឈ្មោះ **ផុយ សុគន្ធ** អត្តលេខ ៤២២ មេធាវី ឈ្មោះ **ពុធ ធារី** និងមេធាវី ឈ្មោះ **វណ្ណ ឆ័ន្ទសីហា** ជាសហមេធាវីការពារសិទ្ធិឱ្យជនរងគ្រោះ។

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ជាន់ទី ៣
បន្ទប់អក្សរ "ញ"
ឡេង ណាង

**អយ្យការអមសាលាដំបូង**
**រាជធានីភ្នំពេញ**

សំណុំរឿងព្រហ្មទណ្ឌ
លេខ ១៥ ចុះថ្ងៃទី ០៣.០១.២០១៦

# ដីកាកោះ

**យើង ហៀង សុគន្ធ តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ**

អញ្ជើញឈ្មោះ **កឹម សុខា**

មានទីលំនៅបច្ចុប្បន្នស្នាក់នៅ ទីស្នាក់ការគណបក្សសង្គ្រោះជាតិ ស្ថិតនៅ ផ្ទះលេខ ៥៧៦ ផ្លូវជាតិលេខ ២ ភូមិព្រៃកគាត់ សង្កាត់ចាក់អង្រែលើ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ។

**ឱ្យចូលទៅកាន់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ**

នៅថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០១៦ វេលាម៉ោង ០៩ ៖ ០០ នាទីព្រឹក

ដើម្បី **សាកសួរ**

ពីដំណើររឿង ៖ **ការញុះញង់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋ ឬប្រព្រឹត្តអំពើបង្កឱ្យមានភាពវឹកវរធ្ងន់ធ្ងរដល់សន្តិសុខសង្គម ។**

សាមីខ្លួន ត្រូវអញ្ជើញតាមដីកាកោះនេះ ឱ្យបានទាន់ពេលវេលា និងយកលិខិត ឬឯកសារផ្សេង ៗ ដែលទាក់ទិននឹងរឿងខាងលើមកជាមួយផង ប្រសិនបើមាន ។

រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ មករា ឆ្នាំ ២០១៦

**តំណាងអយ្យការ**

**ហៀង_សុគន្ធ**
**ព្រះរាជអាជ្ញារង**

## សម្រេច

១. លើកលែងចោទប្រកាន់លើឈ្មោះ **មាន ពេជ្ររីតា** ហៅ **ឈូបី** ភេទស្រី អាយុ ២០ឆ្នាំ សញ្ជាតិខ្មែរ ដែលមានអត្តសញ្ញាណដូចខាងលើ ពីបទ **លួច មានស្ថានទម្ងន់ទោសដោយសារប្រព្រឹត្តអំពើហិង្សា** ប្រព្រឹត្តនៅចំណុចផ្ទះ ១៣៨ ផ្លូវ ២៥៩ ស្ថិតនៅក្រុម ២៨ ភូមិ ១០ សង្កាត់ទឹកល្អក់ទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ជាបទល្មើសព្រហ្មទណ្ឌ និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ។

២. សម្រេចលើវត្ថុតាងដូចខាងក្រោម៖

២.១ ប្រគល់នូវទូរស័ព្ទ១គ្រឿង ម៉ាក iPhone 12 pro max ពណ៌ទឹកមាស របកអេក្រង់ (មិនប្រាកដ) ឱ្យទៅម្ចាស់ដើមវិញ ឈ្មោះ **ហេង សៀ** ដូចមានក្នុងកំណត់ហេតុទទួលវត្ថុតាងលេខ ៩០០ វវត ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២១ របស់សាលាដំបូង និងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

២.២ ប្រគល់នូវទូរស័ព្ទ១គ្រឿង ម៉ាក iPhone 11 pro max ពណ៌ខ្មៅ លេខ IMEI: 353959101077501 របកអេក្រង់ (មិនប្រាកដ) ឱ្យទៅម្ចាស់ដើមវិញ ឈ្មោះ **មាន ពេជ្ររីតា** ដូចមានក្នុងកំណត់ហេតុទទួលវត្ថុតាងលេខ ៩០០ វវត ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២១ របស់សាលាដំបូង និងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

២.៣ រឹបអូសនូវកូនកាំបិតចុងស្រួច ដងពណ៌ខ្មៅ ចំនួន ១ដើម ដូចមានក្នុងកំណត់ហេតុទទួលវត្ថុតាងលេខ ៩០៥ វវត ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២១ របស់សាលាដំបូង និងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ស្របតាមបញ្ញត្តិមាត្រា ១៦១ កថាខណ្ឌ ៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

ថ្ងៃ ... ខែជេស្ឋ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែមិថុនា ឆ្នាំ២០២១

**ចៅក្រមស៊ើបសួរ**

គួយ ទេសាំ

**បានឃើញ**

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែមិថុនា ឆ្នាំ២០២១

**ព.ព្រះរាជអាជ្ញា**

ស៊ុខ_ឆវ័ន្ត

ព្រះរាជអាជ្ញារង

**ក្រឡាបញ្ជី**

គុយ_សុផារ៉ែក

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

# ដីកាបង្គាប់ឱ្យចាប់ខ្លួន

លេខ ..1184... "ត"ដ.ច.ខ

យើង រស់ ពិសិដ្ឋ ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ

-បានឃើញ បញ្ញត្តិមាត្រា ១៩៦ និងមាត្រា ១៩៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌដែលប្រកាសឱ្យប្រើតាមព្រះរាជក្រម លេខ នស/រកម/០៨/០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ ។

-បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ ៥៧៥១ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៨ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញ សំណុំរឿងស៊ើបសួរលេខ ៣១៨៨ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៩ របស់សាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ២៩៥៩ អ.យ.ខ ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៩ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ដែលបើកការស៊ើបសួរលើជនត្រូវចោទ ៖

ឈ្មោះ សឿង រតនា ភេទប្រុស អាយុ៣៤ឆ្នាំ ជនជាតិខ្មែរ អាសយដ្ឋានស្នាក់នៅផ្ទះលេខ៦០ ផ្លូវលេខ២១០ សង្កាត់ទឹកល្អក់ទី៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ ពីបទ "មិនបំពេញកាតព្វកិច្ចចំពោះឧបករណ៍អាចជួញដូរបាន" ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៧ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៣១ នៃច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់ ។

-បានឃើញ ដីកាបញ្ជូនឱ្យឆ្លើយលេខ ១៣៣០ "ត"ព្រ.១ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៩ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ ។

## សំអាងហេតុ

១-ចៅក្រមស៊ើបសួរបានចេញដីកាបង្គាប់ឱ្យចូលខ្លួនលេខ ១០៥៨ "ត"ព្រ.១ ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០១៩ ឱ្យជនត្រូវចោទចូលមកបង្ហាញខ្លួន ដើម្បីសួរចម្លើយពាក់ព័ន្ធនឹងសំណុំរឿងខាងលើនេះ ប៉ុន្តែពុំមានវត្តមានរបស់ឈ្មោះ សឿន រតនា មកបង្ហាញខ្លួនឡើយ ។

២-បទល្មើសចោទប្រកាន់នេះ ជាបទមជ្ឈិមដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ ហើយបុគ្គលរូបនេះ បានរត់គេចខ្លួនមិនដឹងជាស្ថិតនៅទីកន្លែងណាពិតប្រាកដ ដើម្បីសម្រួលដល់នីតិវិធីស៊ើបសួរឱ្យបានពេញលេញ គប្បីចេញដីកាបង្គាប់ឱ្យចាប់ខ្លួនជនត្រូវចោទខាងលើនេះ ។

## ហេតុដូច្នេះសម្រេច

១-ឱ្យចាប់ខ្លួនឈ្មោះ សឿង រតនា ភេទប្រុស អាយុ៣៤ឆ្នាំ ជនជាតិខ្មែរ (ដែលមានសាវតាជាតិដូចខាងលើ) ។

២-បញ្ជាដល់កងកម្លាំងសាធារណៈឱ្យស្រាវជ្រាវរកចាប់ និងនាំខ្លួនឈ្មោះខាងលើនេះ មកប្រគល់ជូនសាលាដំបូងរាជធានីភ្នំពេញ ដើម្បីចាត់ការតាមច្បាប់ ។

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

បន្ទប់ស៊ើបសួរ (១)

លេខ: 3413 /ភ.ជ.ឃ.ដ

# ដីកាបង្គាប់ឲ្យដោះលែង

## យើង លី សុបម៉េង ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ

-បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ ៤៧៥៨ ចុះថ្ងៃទី ០១ ខែសីហា ឆ្នាំ២០១៧ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ៣០៩២ អ.យ.ប ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០១៧ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញ សំណុំរឿងស៊ើបសួរលេខ ២៩៤៥ ចុះថ្ងៃទី ០៦ ខែសីហា ឆ្នាំ២០១៧ របស់សាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញ ដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ៦២៧១ (១).ជ.ឃ.ជ ចុះថ្ងៃទី ០៦ ខែសីហា ឆ្នាំ២០១៧ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញ ដីកាសម្រេចដោះលែងឱ្យនៅក្រៅឃុំលេខ: 2303 (១).ដ.ព.ស ចុះថ្ងៃទី ៣០ ខែមេសា ឆ្នាំ២០១៨ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។

**<u>បង្គាប់មក</u>**

លោកប្រធានមន្ទីរអប់រំកែប្រែ **រាជធានីភ្នំពេញ** (PJ) ឲ្យដោះលែងជនត្រូវចោទឈ្មោះ **ញឹក ប៊ុនឆៃ** (ញឹក ប៊ុនឆៃ) ភេទប្រុស អាយុ៥៥ឆ្នាំ (០៣.០២.១៩៦៣) ជនជាតិខ្មែរ មុខរបរ ប្រធានគណបក្សខ្មែររួបរួមជាតិ ទីកន្លែងកំណើត ភូមិតាអុងតាងលិច ឃុំស្វាយទេព ស្រុកថ្ពូក ខេត្តបាត់ដំបង មានទីលំនៅមុនពេលឃាត់ខ្លួនផ្ទះលេខ ២២G ផ្លូវកែវចិន្ដា ភូមិ៣ សង្កាត់ជ្រោយចង្វារ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ឪពុកឈ្មោះ ញឹក មេន (ស) ម្ដាយឈ្មោះ អួន សារ៉េត (ស) ប្រពន្ធឈ្មោះ សម សុភាព (រ) មានកូន០៥នាក់ ទោសពីមុនគ្មាន ជាអតីតជន ។

ត្រូវបានតុលាការដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យពីបទ: **សមគំនិតក្នុងបទផលិតគ្រឿងញៀន និងកាន់កាប់សារធាតុសម្រាប់ផ្សំគ្រឿងញៀន** ប្រព្រឹត្តនៅចំណុចភូមិទី១ ឃុំត្រែងត្រយឹង ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ កាលពីថ្ងៃទី ០១ ខែមេសា ឆ្នាំ២០០៧ តាមមាត្រា ២៨ នៃក្រមព្រហ្មទណ្ឌ , មាត្រា ៣៨.១ថ្មី ចំណុចទី៤ មាត្រា ៣១.១ថ្មី ចំណុចទី៥.៧ នៃច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀនឆ្នាំ២០០៥ ឲ្យនៅក្រៅឃុំជាបណ្ដោះអាសន្ន ប្រសិនបើឈ្មោះនេះមិនត្រូវបានឃុំខ្លួនពីបទល្មើសផ្សេងទៀត ។

ថ្ងៃចន្ទ ១រោច ខែពិសាខ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែមេសា ឆ្នាំ២០១៨

**ចៅក្រមស៊ើបសួរ**

លី សុបម៉េង

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងរាជធានីភ្នំពេញ**

# ដីកាបង្គាប់ឱ្យចាប់ខ្លួន

លេខ ..1181... "ត"ដ.ច.ខ

យើង **រស់ ពិសិដ្ឋ** ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ

-បានឃើញ បញ្ញត្តិមាត្រា ១៩៦ និងមាត្រា ១៩៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌដែលប្រកាសឱ្យប្រើតាមព្រះរាជក្រម លេខ នស/រកម/០៨/០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ ។

-បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ ៥៧៥១ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៨ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញ សំណុំរឿងស៊ើបសួរលេខ ៣១៨៨ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៩ របស់សាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ២៩៥៩ អ.យ.ខ ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៩ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ដែលបើកការស៊ើបសួរលើជនត្រូវចោទ ៖

ឈ្មោះ សឿង រតនា ភេទប្រុស អាយុ៣៤ឆ្នាំ ជនជាតិខ្មែរ អាសយដ្ឋានស្នាក់នៅផ្ទះលេខ៦០ ផ្លូវលេខ២១០ សង្កាត់ទឹកល្អក់ទី៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ ពីបទ "មិនបំពេញកាតព្វកិច្ចចំពោះឧបករណ៍អាចជួញដូរបាន" ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៧ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៣១ នៃច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់ ។

-បានឃើញ ដីកាបញ្ជូនឱ្យឆ្លើយលេខ ១៣៣០ "ត"ព្រ.ទ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៩ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ ។

## សំអាងហេតុ

១-ចៅក្រមស៊ើបសួរបានចេញដីកាបង្គាប់ឱ្យចូលខ្លួនលេខ ១០៥៨ "ត"ព្រ.ទ ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០១៩ ឱ្យជនត្រូវចោទចូលមកបង្ហាញខ្លួន ដើម្បីសួរចម្លើយពាក់ព័ន្ធនឹងសំណុំរឿងខាងលើនេះ ប៉ុន្តែពុំមានវត្តមានរបស់ឈ្មោះ សឿន រតនា មកបង្ហាញខ្លួនឡើយ ។

២-បទល្មើសចោទប្រកាន់នេះ ជាបទមជ្ឈិមដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ ហើយបុគ្គលរូបនេះ បានរត់គេចខ្លួនមិនដឹងជាស្ថិតនៅទីកន្លែងណាពិតប្រាកដ ដើម្បីសម្រួលដល់នីតិវិធីស៊ើបសួរឱ្យបានពេញលេញ គប្បីចេញដីកាបង្គាប់ឱ្យចាប់ខ្លួនជនត្រូវចោទខាងលើនេះ ។

## ហេតុដូច្នេះសម្រេច

១-ឱ្យចាប់ខ្លួនឈ្មោះ សឿង រតនា ភេទប្រុស អាយុ៣៤ឆ្នាំ ជនជាតិខ្មែរ (ដែលមានសាវតាជាតិដូចខាងលើ) ។

២-បញ្ជាដល់កងកម្លាំងសាធារណៈឱ្យស្រាវជ្រាវរកចាប់ និងនាំខ្លួនឈ្មោះខាងលើនេះ មកប្រគល់ជូនសាលាដំបូងរាជធានីភ្នំពេញ ដើម្បីចាត់ការតាមច្បាប់ ។

**សាលាដំបូងរាជធានីភ្នំពេញ**

លេខ ១៣៤.... "ម" ចបខ

# ដីកាបង្គាប់ឲ្យចាប់ខ្លួន

យើង **គុយ សៅ** ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ។

- បានឃើញ មាត្រា ១៩៥ និងមាត្រាបន្តបន្ទាប់នៃក្រមនីតិវិធីព្រហ្មទណ្ឌ។
- បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ ១១៥០ ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៩។
- បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ ៧៦២ អ.យ.វ ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៩។
- បានឃើញ សំណុំរឿងស៊ើបសួរលេខ ៧៨៩ ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១៩។
- បានឃើញ ដីកាបញ្ជូនឲ្យឆ្លើយលេខ ១៨៦ ប.ព្រ.១ ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៩ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ និងយោបល់របស់ព្រះរាជអាជ្ញា។

**ក្រោយពីបានពិនិត្យមើលសំណុំរឿងទាំងស្រុង ឃើញថា:**

ឈ្មោះ **ហ្វូរ ស៊ាន់** ភេទប្រុស អាយុ៧១ ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ ទីកន្លែងកំណើតភូមិចិន ឃុំស្រែរនោង ស្រុកត្រាំកក់ ខេត្តតាកែវ ទីលំនៅបច្ចុប្បន្នផ្ទះលេខ១៩រ ផ្លូវលេខ៥៥៤ ភូមិ៧ សង្កាត់បឹងកក់ទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ជាតិជន (គេចខ្លួន)។

ត្រូវចោទប្រកាន់ពីបទ **រួមគំនិតក្បត់ និងញុះញង់ឲ្យប្រព្រឹត្តបទឧក្រិដ្ឋជាអាទិ៍** ប្រព្រឹត្តនៅប្រទេសកម្ពុជា និងទីកន្លែងផ្សេងទៀត កាលពីថ្ងៃទី២០ ២១ ២២ ២៥ ២៦ និងថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៩ តាមបញ្ញត្តិមាត្រា ៤៥៣ មាត្រា ៤៩៤ និងមាត្រា ៤៩៥ នៃក្រមព្រហ្មទណ្ឌ។

**ឃើញថា** តាមរបាយការណ៍លេខ ២១៦/១៩ របក.ឧបកក ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៩ របស់នាយកដ្ឋានប្រឆាំងភេរវកម្ម និងឧក្រិដ្ឋកម្មឆ្លងដែន បានបញ្ជាក់ថា ឈ្មោះខាងលើពុំមានវត្តមាននៅតាមទីលំនៅក្នុងមូលដ្ឋានរបស់ខ្លួន ក្នុងព្រះរាជាណាចក្រកម្ពុជានោះទេ។ ដូច្នេះតុលាការគប្បីចេញដីកាបង្គាប់ឲ្យចាប់ខ្លួនលើជនត្រូវចោទឈ្មោះ **ហ្វូរ ស៊ាន់** ភេទប្រុស អាយុ៧១ ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ ដើម្បីឲ្យជនត្រូវចោទមកបង្ហាញខ្លួនចំពោះមុខតុលាការដើម្បីរកការពិតក្នុងរឿងក្តីនេះ។

## ហេតុដូច្នេះសម្រេច

១. បង្គាប់ឲ្យចាប់ខ្លួនឈ្មោះ **ហ្វូរ ស៊ាន់** ដែលមានអត្តសញ្ញាណខាងលើនេះ។

២. បញ្ជាដល់កងកម្លាំងសាធារណៈ ឲ្យស្រាវជ្រាវរកចាប់ និងនាំខ្លួនឈ្មោះខាងលើនេះ មកប្រគល់ជូនសាលាដំបូងរាជធានីភ្នំពេញ ដើម្បីចាត់ការតាមច្បាប់។

ថ្ងៃ[illegible]...ខែផល្គុន ឆ្នាំកុរ ឯកស័ក ព.ស ២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី [illegible]...ខែមីនា ឆ្នាំ២០១៩

**ចៅក្រមស៊ើបសួរ**

គុយ សៅ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

**សភាពេញអង្គ**
សំណុំរឿងលេខ: ០១ សព.តប
ចុះថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០១៨
**ដីកាសម្រេច**
លេខ៖ [illegible]
ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៨

# ដីកាសម្រេច

**អ្នកដើមបណ្តឹងនៃបណ្តឹងទាមទារឲ្យស្តារសិទ្ធិធ្វើនយោបាយឡើងវិញ**

ឈ្មោះ [illegible] ឈ្មោះ [illegible] ឈ្មោះ [illegible] ឈ្មោះ [illegible] ឈ្មោះ [illegible] ឈ្មោះ [illegible] ឈ្មោះ [illegible] ឈ្មោះ [illegible] ឈ្មោះ [illegible] ឈ្មោះ [illegible] ឈ្មោះ [illegible] ឈ្មោះ [illegible] ឈ្មោះ [illegible] ឈ្មោះ [illegible] និងឈ្មោះ [illegible] ដែលមានអាសយដ្ឋានបច្ចុប្បន្ន [illegible] ។

**ចុងចម្លើយនៃបណ្តឹងទាមទារឲ្យស្តារសិទ្ធិធ្វើនយោបាយឡើងវិញ**

ក្រសួងមហាផ្ទៃ មានអាសយដ្ឋាន [illegible] ។

**កម្មវត្ថុបណ្តឹង ៖** ប្តឹងទាមទារឲ្យស្តារសិទ្ធិធ្វើនយោបាយ ដែលបានកំណត់ក្នុងសាលដីកាលេខ ៣៤០ (ក) ចុះថ្ងៃទី ១៦ ខែវិច្ឆិកា ឆ្នាំ២០១៧ របស់តុលាការកំពូល ក្នុងសំណុំរឿងរដ្ឋបាលលេខ ០១ ត.ប ចុះថ្ងៃទី ៦ ខែ តុលា ឆ្នាំ ២០១៧ របស់តុលាការកំពូល ។

**អង្គហេតុដែលជាមូលហេតុនៃការទាមទារសុំឲ្យស្តារសិទ្ធិធ្វើនយោបាយឡើងវិញ**

តាមពាក្យបណ្តឹងទាមទារសុំឲ្យស្តារសិទ្ធិធ្វើនយោបាយ ចុះថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០១៨ របស់សមាជិក [illegible] នៃបណ្តឹងទាមទារសុំឲ្យស្តារសិទ្ធិធ្វើនយោបាយ [illegible] ក្រោយពីបាន [illegible] តុលាការកំពូលបានសម្រេចរំលាយគណបក្សសង្គ្រោះជាតិ និងហាមឃាត់ការធ្វើសកម្មភាពនយោបាយរបស់ថ្នាក់ដឹកនាំគណបក្សសង្គ្រោះជាតិចំនួន ១១៨ (មួយរយដប់ប្រាំបី)នាក់ តាមសាលដីកាលេខ ៣៤០ (ក) ចុះថ្ងៃទី១៦

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**អយ្យការអមសាលាដំបូង**
**រាជធានីភ្នំពេញ**

សំណុំរឿងព្រហ្មទណ្ឌលេខ ៦៣៧១
ចុះថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០១៩
លេខ ៤៣០០...... អ.យ.ក

# ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ

យើង **កែវ សុធា** តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

-**បានឃើញ**សំណុំរឿងព្រហ្មទណ្ឌលេខ **៦៣៧១** ចុះថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០១៩ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

-**បានឃើញ**របាយការណ៍លេខ **៨៥៥/១៩** រ.ប.ក.នបកក២ ចុះថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០១៩ របស់នាយកដ្ឋានប្រឆាំងភេរវកម្ម និងឧក្រិដ្ឋកម្មឆ្លងដែន នៃក្រសួងមហាផ្ទៃ ។

-**បានឃើញ**លិខិតលេខ **១៨១៨ កយ រប/១៩** ចុះថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០១៩ របស់ក្រសួងយុត្តិធម៌ ។

## ក្រោយពីបានពិនិត្យឯកសារខាងលើ

យល់ឃើញថា មានតម្រុយសន្និដ្ឋានបានថា:

ឈ្មោះ **សម វង្សី** ភេទប្រុស កើតថ្ងៃទី ១០ ខែ មីនា ឆ្នាំ ១៩៤៩ ជនជាតិខ្មែរ សាសនាព្រះពុទ្ធ កាន់លិខិតឆ្លងដែនលេខ D0002190 ទីកន្លែងកំណើតសង្កាត់លេខ២ ក្រុងភ្នំពេញ មានទីលំនៅបច្ចុប្បន្នផ្ទះលេខ ៥៧៦ ផ្លូវជាតិលេខ២ សង្កាត់ចាក់អង្រែលើ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ឪពុកឈ្មោះ **សម សារី** "ស្លាប់" ម្តាយឈ្មោះ **អ៊ិន អេម** "ស្លាប់" ប្រពន្ធឈ្មោះ **ជុំឡុង សុម្ភ័ា** "រស់" មានកូន០៣នាក់ ជានីតិជន ។

បានប្រព្រឹត្តដូចតទៅ[1]៖ នាយប់ថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០១៩ ទណ្ឌិតឈ្មោះ **សម រង្ស៊ី** បាននិយាយក្នុងកិច្ចសម្ភាសន៍ជាមួយលោក **ម្យូង ណារ៉េត** នៃវិទ្យុអាស៊ីសេរី ដោយបានប្រមាថទៅលើអង្គព្រះមហាក្សត្រ ដែលមានខ្លឹមសារថា **"ព្រះមហាក្សត្ររបស់យើង គឺជាចំណាប់ខ្មាំងរបស់ ហ៊ុន សែន ដូច្នេះលោកអត់ហ៊ានធ្វើអីទេ លោកខ្លាច ហ៊ុន សែន លោកចង់តែរក្សារាជបល្ល័ង្កលោក ដូច្នេះយើងទុកព្រះអង្គមួយអន្លើទៅ យើងមិនអាចពឹងព្រះមហាក្សត្រដែលជាអាយ៉ងរបស់លោក ហ៊ុន សែន ដូចសព្វថ្ងៃទេបាទ"** ។ ពាក្យសម្តីរបស់ទណ្ឌិតឈ្មោះ **សម រង្ស៊ី** ដែលបានផ្សព្វផ្សាយជាសាធារណៈនេះ បានធ្វើឲ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ព្រះកិត្តិនាម **ព្រះករុណា ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុតដែលប្រជារាស្ត្រខ្មែរទូទាំងព្រះរាជាណាចក្រកម្ពុជាគោរពស្រឡាញ់ស្មើជីវិត ។

---

[1] សេចក្តីសង្ខេបអង្គហេតុ



អាសយដ្ឋានៈ អគារលេខ ២៥ ផ្លូវលេខ ២១៧ សង្កាត់វាលវង់ ខណ្ឌ ៧ មករា ភ្នំពេញ
Adress: #25, Street 217, Sangkat Vealvong, Khan 7makara, Phnom Penh, Cambodia.
ទូរសារ-ទូរស័ព្ទ: (៨៥៥)-២៣ ៨៨ ២០ ៥៩
Fax-Phone : (855) - 23 88 20 59

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

បន្ទប់ស៊ើបសួរ "ហ"

លេខ: 652 "ហ" ដចន

# ដីកាបង្គាប់ឱ្យចាប់ខ្លួន

**យើង ពេជ្រ ទិដ្ឋារ៉ា** ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ

-**បានឃើញ** មាត្រា ១៩៥ និងមាត្រាបន្តបន្ទាប់នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

-**បានឃើញ** សំណុំរឿងព្រហ្មទណ្ឌលេខ ១៥១៣ ចុះថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០២០ របស់សាលាដំបូងរាជធានីភ្នំពេញ ។

-**បានឃើញ** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ១២១១ អ.យ.ឃ ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០២០ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញ ចំណាររបស់តំណាងអយ្យការ ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២០ ។

ក្រោយពីបានពិនិត្យសំណុំរឿងចប់សព្វគ្រប់ ឃើញថា

ឈ្មោះ **អ៊ុក ភក្តី** ភេទប្រុស កើតថ្ងៃទី១៥ ខែតុលា ឆ្នាំ១៩៦៦ សញ្ជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ១០១៣៦៥០៩៧ មានទីកន្លែងកំណើតនៅឃុំត្រពាំងធំខាងត្បូង ស្រុកត្រាំកក់ ខេត្តតាកែវ មានទីលំនៅបច្ចុប្បន្ននៅភូមិត្រពាំងកែស ឃុំត្រាំកក់ ស្រុកត្រាំកក់ ខេត្តតាកែវ ។

ត្រូវចោទប្រកាន់ពីបទ **លួចលក់អចលនវត្ថុដែលមិនមែនជារបស់ខ្លួន** ប្រព្រឹត្តនៅភូមិសំរោងត្បូង សង្កាត់សំរោង ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ តាមបញ្ញត្តិមាត្រា ២៥៥ នៃច្បាប់ភូមិបាល ។

## យល់ឃើញថា

-បទល្មើសដែលត្រូវចោទប្រកាន់ជាបទមជ្ឈិម ដែលតម្រូវឱ្យផ្តន្ទាទោសដាក់ពន្ធនាគារ ។

-ជនត្រូវចោទមិនដឹងស្ថិតនៅទីកន្លែងណា ។

-ជៀសវាងការរឹងទទឹងមិនចូលខ្លួនមកទទួលខុសត្រូវព្រហ្មទណ្ឌ ។

-តាមការស្នើសុំបំពេញកិច្ចរបស់តំណាងអយ្យការ ស្នើសុំចៅក្រមស៊ើបសួរចេញដីកាបង្គាប់ឱ្យចាប់ខ្លួន ។

## ហេតុដូច្នេះ

១-ឱ្យចាប់ខ្លួនឈ្មោះ **អ៊ុក ភក្តី** ខាងលើ យកមកបង្ហាញខ្លួនចំពោះមុខចៅក្រមស៊ើបសួរ ។

២-បញ្ជាដល់កម្លាំងសាធារណៈ ឱ្យស្រាវជ្រាវរកចាប់ និងនាំខ្លួនឈ្មោះខាងលើនេះ មកសាលាដំបូងរាជធានីភ្នំពេញ ដើម្បីចាត់ការតាមនីតិវិធីច្បាប់ ។

ថ្ងៃអង្គារ ១២កើត ខែជេស្ឋ ឆ្នាំជូត ទោស័ក ព.ស២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ,ថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០២០

ចៅក្រមស៊ើបសួរ

**ពេជ្រ ទិដ្ឋារ៉ា**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អយ្យការអមសាលាដំបូង
រាជធានីភ្នំពេញ

សំណុំរឿងព្រហ្មទណ្ឌលេខ ៣២១០
ចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៩
លេខ [illegible] ព.ជ.ក

# ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ

**យើង [illegible] ព្រះរាជអាជ្ញា នៃ អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ**

-បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ ៣២១០ ចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៩ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញ ពាក្យបណ្តឹង ចុះថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០១៩ របស់ឈ្មោះ ឈុន ណារី ។

**ក្រោយពីបានពិនិត្យសំណុំរឿងខាងលើ**

យល់ឃើញថា មានជនត្រូវសង្ស័យដូចតទៅ៖

១-ឈ្មោះត្រកូល-នាមខ្លួន ស្រី សុផា ភេទប្រុស អាយុ [illegible] សញ្ជាតិខ្មែរ មុខរបរ ប្រធានក្រុមប្រឹក្សាភិបាលក្រុមហ៊ុន [illegible] [illegible] រាជធានីភ្នំពេញ ជាដើមចោទ។

២-ឈ្មោះត្រកូល-នាមខ្លួន ស្រី ធនូ ភេទប្រុស អាយុ [illegible] សញ្ជាតិខ្មែរ មុខរបរ នាយកក្រុមហ៊ុន [illegible] [illegible] រាជធានីភ្នំពេញ ជាដើមចោទ។

[illegible][1] [illegible] ឆ្នាំ២០០៨ ឈ្មោះ ឈុន ណារី ភេទស្រី អាយុ [illegible] [illegible] (១០.០០០ម៉ែត្រការ៉េ) [illegible] ឈ្មោះ ស្រី [illegible] ក្រុមហ៊ុន [illegible] ពីឈ្មោះ ស្រី ធនូ [illegible] ឈ្មោះ ឈុន ណារី [illegible] ឈ្មោះ ស្រី សុផា ដែលជាប្រធានក្រុមប្រឹក្សាភិបាលក្រុមហ៊ុន [illegible] [illegible] ឆ្នាំ២០០៩ នេះ ឈ្មោះ ឈុន ណារី [illegible]

[1] [illegible]



អាសយដ្ឋាន៖ អគារលេខ ២៥-២៧ ផ្លូវលេខ ២១៧-២១៣ សង្កាត់វាលវង់ ខណ្ឌ៧មករា ភ្នំពេញ
Adress : #25-27, Street 217-213, Sangkat Veal Vong, Khan 7makara, Phnom Penh, Cambodia
ទូរសារ-ទូរស័ព្ទ (៨៥៥)-២៣ ៨៨ ២០ ៥៩
Fax-Phone : (855)-23 88 20 59

ក្រសួងយុត្តិធម៌
ចូលថ្ងៃទី ២៥-០៧-២០១៩
លេខ ៣៧៤១ ... ម៉ោង ...

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**អយ្យការអមសាលាដំបូង**
**រាជធានីភ្នំពេញ**

**ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ**
**សូមគោរពជូន**
**ឯកឧត្តម រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

អគ្គនាយកដ្ឋានកិច្ចការអយ្យការ និងព្រហ្មទណ្ឌ
ស្នងការដ្ឋាន ០១
ថ្ងៃទី 29 . 07 . 2019
លេខ ... ម៉ោង ...

លេខ.៦៣១. អ.យ.ត

**កម្មវត្ថុ៖** ស្តីពីការជូនដំណឹងអំពី *ការបើកការស៊ើបសួរ* លើឈ្មោះ នៅ សាត គេទ ប្រុស អាយុ ៤៧ឆ្នាំ ជា មន្ត្រីនៃមន្ទីររៀបចំដែនដីនគរូបនីយកម្មសំណង់ និងសុរិយោដី ខេត្តកណ្តាល [illegible]

**យោង៖**
- សំណុំរឿងព្រហ្មទណ្ឌលេខ ២២០៩ ចុះថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០១៩ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។
- មាត្រា ៥៦ នៃច្បាប់ស្តីពី វិសោធនកម្ម ច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល។
- លិខិតលេខ ២១៧៩ កយ-អក/១៣ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៣ របស់ក្រសួងយុត្តិធម៌។

នាយកដ្ឋានកិច្ចការអយ្យការ និងកិច្ចការអនុវត្តទោស
ថ្ងៃទី ០១-០៨-២០១៩
លេខ ១៤១ ... ម៉ោង ...

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទសូមគោរពជម្រាបជូន **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាជ្រាបថា៖ អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ បានទទួលចាត់ការលើសំណុំរឿងព្រហ្មទណ្ឌលេខ ២២០៩ ចុះថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០១៩ ដែលមានដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ អៀ ម៉េងឃីម, ឈ្មោះ ប្រាក់ លឹម, ឈ្មោះ ថេង គឹមសាយ និងឈ្មោះ កុល ច័ន្ទសុវត្ថា បានប្តឹងលើឈ្មោះ នៅ សាត គេទ ប្រុស អាយុ ៤៧ឆ្នាំ មានតួនាទីជា មន្ត្រីនៃមន្ទីររៀបចំដែនដីនគរូបនីយកម្មសំណង់ និងសុរិយោដី ខេត្តកណ្តាល ពីបទ សមគំនិតក្នុងអំពើក្លែងបន្លំ ប្រើប្រាស់លិខិតក្លែង និងលួចលក់អចលនវត្ថុដែលមិនមែនជារបស់ខ្លួន ប្រព្រឹត្តនៅចំណុចភូមិ ជើងព្រៃ ភូមិ តាដោល ឃុំ អំពៅព្រៃ ស្រុក កណ្តាលស្ទឹង ខេត្តកណ្តាល កាលពីអំឡុងឆ្នាំ ២០១៥។

បន្ទាប់ពីធ្វើការស្រាវជ្រាវ ស៊ើបអង្កេតបឋមរួចមកឃើញថាឈ្មោះ នៅ សាត គេទ ប្រុស អាយុ ៤៧ឆ្នាំ អាសយដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ៧ J ផ្លូវលេខ ២៦៥ ភូមិ ១៣ សង្កាត់ ទឹកល្អក់ទី៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ មានតម្រុយសន្មតថា ជាប់ពាក់ព័ន្ធក្នុងការប្រព្រឹត្តបទល្មើស ក្លែងបន្លំ ប្រព្រឹត្តនៅ រាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ ២០១៦ ប្រាកដមែន។

ហេតុដូច្នេះ អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ សម្រេចបើកការស៊ើបសួរលើឈ្មោះ នៅ សាត គេទ ប្រុស អាយុ ៤៧ឆ្នាំ មានតួនាទីជា មន្ត្រីនៃមន្ទីររៀបចំដែនដីនគរូបនីយកម្មសំណង់ និងសុរិយោដី ខេត្តកណ្តាល ពីបទ ក្លែងបន្លំ តាមមាត្រា ៦២៦ និងមាត្រា ៦២៧ នៃក្រមព្រហ្មទណ្ឌ តាមដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ...៣១៤០.... អ.យ.ត ចុះថ្ងៃទី១៩ ខែ កក្កដា ឆ្នាំ ២០១៩ បញ្ជូនទៅសាលាដំបូងរាជធានីភ្នំពេញ ដើម្បីចាត់ការបន្តតាមនីតិវិធី។

អាស្រ័យហេតុដូចបានគោរពជម្រាបជូនខាងលើនេះសូម **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាទទួលជ្រាប ដោយសេចក្តីអនុគ្រោះ។

សូម **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ។

ថ្ងៃ..សុក្រ..៣..កើត.... ខែអាសាឍ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី..១៩...... ខែ កក្កដា ឆ្នាំ ២០១៩

**បានឃើញ**
**ព្រះរាជអាជ្ញា**

វីរេច_សុជា

**ព្រះរាជអាជ្ញារង**

ខិន_ពេជ
ព្រះរាជអាជ្ញារង

INAOT

សាលាដំបូងរាជធានីភ្នំពេញ

បន្ទប់ស៊ើបសួរ "ខ១"

លេខ ១១១៥ ព្រ.ប

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**លិខិតជូនដំណឹង**

**ស្ដីពីការលើកលែងចោទប្រកាន់**

យើង **សេខ រិទ្ធី** ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ

បានឃើញ មាត្រា២៤៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ ។

បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ **៨០៣២** ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៧ ។

បានឃើញ ដីកាសម្រេចលើកលែងចោទប្រកាន់លេខ **៦០៤៩ (ខ១) ដ.អ** ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៨ ។

**ប្រាប់មក**

ឈ្មោះ **ជា មុនី** ភេទប្រុស អាយុ ៤៨ឆ្នាំ ជនជាតិខ្មែរ ទីលំនៅបច្ចុប្បន្នផ្ទះលេខ១៦អា ផ្លូវលេខ៣៦០ សង្កាត់បឹងកេងកងទី៣ ខណ្ឌចំការមន រាជធានីភ្នំពេញ ជាជនត្រូវចោទ។

ត្បិតសំណុំរឿងព្រហ្មទណ្ឌលេ **៨០៣២** ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៧ ដែលមានជនត្រូវចោទឈ្មោះ **ជា មុនី** ភេទប្រុស អាយុ ៤៨ឆ្នាំ ត្រូវចោទពីបទ **ញុះញង់ឲ្យប្រព្រឹត្តបទឧក្រិដ្ឋជាអាទិ៍** ប្រព្រឹត្តនៅចំណុច រាជធានីភ្នំពេញ កាលពីថ្ងៃទី១៥ ខែ ធ្នូ ឆ្នាំ២០១៧ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឲ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា **៤៩៤** និងមាត្រា **៤៩៥** នៃក្រមព្រហ្មទណ្ឌ នោះយើងបានស៊ើបសួរចប់សព្វគ្រប់តាមនីតិវិធីហើយ ។

យើងបានសម្រេច **លើកលែងចោទប្រកាន់** លើជនត្រូវចោទឈ្មោះ **ជា មុនី** ភេទប្រុស អាយុ ៤៨ឆ្នាំ តាមដីកាសម្រេចលើកលែងចោទប្រកាន់លេខ **៦០៤៩ (ខ១) ដ.អ** ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៨ សូមជ្រាបជាដំណឹង ។

ថ្ងៃសុក្រ ០៥រោច ខែមិគសិរ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៨

**ចៅក្រមស៊ើបសួរ**

សេខ រិទ្ធី

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

មន្ទីរស៊ើបសួរ "ឆ"

លេខ: ៤៣៧......ដ.យ.ដ

## ដីកាបង្គាប់ឲ្យចាប់ខ្លួន

យើង **គោ វណ្ឌី** ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ

-បានឃើញមាត្រា ១៩៥ និងមាត្រាបន្តបន្ទាប់នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

-បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ ៥៦៥២ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៦។

-បានឃើញដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ ៣៥៧២ អ.យ.ប ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញដីកាបញ្ជូនឲ្យឆ្លើយលេខ ៧៥៨ "ឆ" ព្រទ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៧ របស់ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ។

ក្រោយពីបានពិនិត្យលើសំណុំរឿងចប់សព្វគ្រប់ សំអាងហេតុ:

-ឈ្មោះ អៀ គុយម៉ុង ភេទប្រុស អាយុ៥៧ឆ្នាំ ជាតិខ្មែរ មុខរបរអាជីវករ ទីកន្លែងកំណើត ភូមិប្រាំបីនោម ឃុំពង្រ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង ទីលំនៅបច្ចុប្បន្ន ភូមិស្វាយជ្រុំថ្មី ឃុំស្វាយជ្រុំ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង ឪពុកឈ្មោះ អៀ ហុងឃីម "ស្លាប់" ម្ដាយឈ្មោះ តាំង ហ៊ុចហ្វួយ "ស្លាប់" ប្រពន្ធឈ្មោះ យូ ស៊ីចេង មានកូន ០២នាក់។

ត្រូវចោទប្រកាន់ពីបទ: លួចលក់អចលនវត្ថុអ្នកដទៃ ប្រព្រឹត្តនៅ ភូមិ៧ សង្កាត់ខ្សាម ក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៦ បទល្មើសដែលមានចែងឲ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ២៥៥ នៃច្បាប់ភូមិបាល។

-តំណាងអយ្យការបានផ្ដល់យោបល់ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៧ គប្បីចៅក្រមស៊ើបសួរសម្រេចតាមនីតិវិធី។

## ហេតុដូច្នេះសម្រេច

១-ឲ្យចាប់ខ្លួនឈ្មោះ អៀ គុយម៉ុង ភេទប្រុស អាយុ៥៧ឆ្នាំ ជាតិខ្មែរ ដែលមានអត្តសញ្ញាណខាងលើនេះ ។

២-បញ្ជាដល់កងកម្លាំងសាធារណៈ ឲ្យស្រាវជ្រាវរកចាប់ និងនាំខ្លួនឈ្មោះខាងលើនេះ មកប្រគល់ជូនសាលាដំបូងរាជធានីភ្នំពេញ ដើម្បីចាត់ការតាមច្បាប់ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៦..... ខែវិច្ឆិកា ឆ្នាំ២០១៧

**ចៅក្រមស៊ើបសួរ**

គោ. វណ្ឌី

TNAOT

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

បន្ទប់ស៊ើបសួរ "ហ"

លេខ: 653 "ហ" ដចន

# ដីកាបង្គាប់ឱ្យចាប់ខ្លួន

យើង **ពេជ្រ ទិដ្ឋាធរ** ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ

-**បានឃើញ** មាត្រា ១៩៥ និងមាត្រាបន្តបន្ទាប់នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

-**បានឃើញ** សំណុំរឿងព្រហ្មទណ្ឌលេខ ១៥១៣ ចុះថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០២០ របស់សាលាដំបូងរាជធានីភ្នំពេញ ។

-**បានឃើញ** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ១២១១ អ.យ.ឃ ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០២០ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញ ចំណាររបស់តំណាងអយ្យការ ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២០ ។

ក្រោយពីបានពិនិត្យសំណុំរឿងចប់សព្វគ្រប់ ឃើញថា

ឈ្មោះ **ម៉ាត់ ឌី** ភេទប្រុស កើតថ្ងៃទី០៧ ខែមេសា ឆ្នាំ១៩៦៩ សញ្ជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ០១០៩៦០៩០៩ មានទីកន្លែងកំណើតនៅឃុំព្រែកព្នៅ ស្រុកពញាឮ ខេត្តកណ្ដាល មានទីលំនៅបច្ចុប្បន្ននៅភូមិដូង សង្កាត់ព្រែកព្នៅ ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ ។

ត្រូវចោទប្រកាន់ពីបទ **លួចលក់អចលនវត្ថុដែលមិនមែនជារបស់ខ្លួន** ប្រព្រឹត្តនៅភូមិសំរោងត្បូង សង្កាត់សំរោង ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ តាមបញ្ញត្តិមាត្រា ២៥៥ នៃច្បាប់ភូមិបាល ។

## យល់ឃើញថា

-បទល្មើសដែលត្រូវចោទប្រកាន់ជាបទមជ្ឈិម ដែលតម្រូវឱ្យផ្តន្ទាទោសដាក់ពន្ធនាគារ ។

-ជនត្រូវចោទមិនដឹងស្ថិតនៅទីកន្លែងណា ។

-ជៀសវាងការរឹងទទឹងមិនចូលខ្លួនមកទទួលខុសត្រូវព្រហ្មទណ្ឌ ។

-តាមការស្នើសុំបំពេញកិច្ចរបស់តំណាងអយ្យការ ស្នើសុំចៅក្រមស៊ើបសួរចេញដីកាបង្គាប់ឱ្យចាប់ខ្លួន ។

## ហេតុដូច្នេះ

១-ឱ្យចាប់ខ្លួនឈ្មោះ **ម៉ាត់ ឌី** ខាងលើយកមកបង្ហាញខ្លួនចំពោះមុខចៅក្រមស៊ើបសួរ ។

២-បញ្ជាដល់កម្លាំងសាធារណៈ ឱ្យស្រាវជ្រាវរកចាប់ និងនាំខ្លួនឈ្មោះខាងលើនេះ មកសាលាដំបូងរាជធានីភ្នំពេញ ដើម្បីចាត់ការតាមនីតិវិធីច្បាប់ ។

ថ្ងៃអង្គារ ១១កើត ខែជេស្ឋ ឆ្នាំជូត ទោស័ក ព.ស២៥៦៤
ធ្វើនៅរាជធានីភ្នំពេញ ,ថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០២០
**ចៅក្រមស៊ើបសួរ**

**ពេជ្រ ទិដ្ឋាធរ**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាដំបូងរាជធានីភ្នំពេញ

បន្ទប់ស៊ើបសួរ "ជ"
លេខ ៩១១ តព្រ

# ដីកាបង្គាប់ឲ្យចាប់ខ្លួន

យើង **ថ្លាង ដាវ៉ែណាត** ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ

-បានឃើញ មាត្រា ១៩៥ និងមាត្រា បន្តបន្ទាប់នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

-បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ ៣០៣ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៣។

-បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ ២២៦ អ.យ.ជ ចុះថ្ងៃទី០៨ ខែមីនា ឆ្នាំ២០១៣។

-បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមលេខ ០៦ អ.យ.ព ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ២០១៥។

-បានឃើញ ដីកាបញ្ជូនឲ្យឆ្លើយលេខ ២៥៣៦ តព្រ ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៥ ដោយមានការ ឯកភាព ពីតំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-ក្រោយពីបានពិនិត្យលើសំណុំរឿងទាំងមូលគ្រប់ យើងឃើញថា:

ជនត្រូវចោទឈ្មោះ ឆេង ស្មុគី ភេទស្រី អាយុ ៤២ឆ្នាំ ជនជាតិ ខ្មែរ មានទីលំនៅផ្ទះលេខ ២៥៨ ភូមិព្រែកលៀប សង្កាត់ព្រែកលៀប ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ។

ត្រូវចោទប្រកាន់ពីបទ: ចេញមូលប្បទានប័ត្រគ្មានសាច់ប្រាក់ និង ឆបោក ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០០៦ និងកាលពីឆ្នាំ ២០០៦ តាមបញ្ញត្តិមាត្រា ២៣១ នៃច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់ និងមាត្រា ៣៧៧ , ៣៧៨ នៃក្រមព្រហ្មទណ្ឌ។

## យល់ឃើញថា

-បទល្មើសខាងលើជាបទមជ្ឈិម ដែលច្បាប់កម្រិតឲ្យផ្តន្ទាទោសស្មើ ឬលើសពី ០១ឆ្នាំ។

-ជនត្រូវចោទបានគេចខ្លួន។

-ជនត្រូវចោទមានសាវតាជាតិ (អត្តសញ្ញាណ) ច្បាស់លាស់។

## ហេតុដូច្នេះសម្រេច

១) ឲ្យចាប់ខ្លួនឈ្មោះ ឆេង ស្មុគី ភេទស្រី អាយុ ៤២ឆ្នាំ ដែលមានអត្តសញ្ញាណខាងលើនេះ។

២) បញ្ជាដល់កងកម្លាំងសាធារណៈ ឲ្យស្រាវជ្រាវចាប់ខ្លួន និងនាំខ្លួនឈ្មោះខាងលើនេះ មកប្រគល់ជូនសាលាដំបូងរាជធានីភ្នំពេញ ដើម្បីចាត់ការតាមច្បាប់។

រាជធានីភ្នំពេញ ថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៥

**ចៅក្រមស៊ើបសួរ**

**ថ្លាង ដាវ៉ែណាត**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងរាជធានីភ្នំពេញ**

បន្ទប់ស៊ើបសួរ (ត)
លេខ...057... "ត" ដ.ព.ស

# ដីកាសម្រេចមិនឃុំខ្លួនបណ្ដោះអាសន្ន

យើង រស់ ពិសិដ្ឋ ចៅក្រមស៊ើបសួរសាលាសាលាដំបូងរាជធានីភ្នំពេញ
អមដោយលោកស្រី ឌី ឈីឡា ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

-បានឃើញ មាត្រា ២០៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើប្រាស់តាមព្រះរាជក្រមលេខ នស/រកម០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ ។

-បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ ៥៧៥១ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៨ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញ សំណុំរឿងស៊ើបសួរលេខ ៣១៨៨ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៩ របស់សាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ២៩៥៩ អ.យ.ឧ ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៩ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ បានសម្រេចបើកការស៊ើបសួរលើជនត្រូវចោទ ៖

ឈ្មោះ សឿង រតនា ភេទប្រុស អាយុ៣៩ឆ្នាំ ជនជាតិខ្មែរ មុខរបរអាជីវករ ទីកន្លែងកំណើតនៅស្រុកបាណន់ ខេត្តបាត់ដំបង អាសយដ្ឋានស្នាក់នៅផ្ទះលេខ៦០ ផ្លូវលេខ២៦៥ សង្កាត់ទឹកល្អក់២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ឪពុកឈ្មោះ សឿង ហៀង (ស្លាប់) ម្ដាយឈ្មោះ តាំង សៀមហុង (រស់) នៅលីវ ជានីតិជន ប្រវត្តិនៃការផ្ដន្ទាទោសដោយតុលាការ "គ្មាន" ។

ដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យពីបទ "មិនបំពេញកាតព្វកិច្ចចំពោះឧបករណ៍អាចជួញដូរបាន" ប្រព្រឹត្តនៅចំណុចរាជធានីភ្នំពេញ កាលពីថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៧ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ២៣១ នៃច្បាប់ស្ដីពីឧបករណ៍អាចជួញដូរបាន ។

-បានឃើញ កំណត់ហេតុបង្ហាញខ្លួនលើកដំបូង ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញ កំណត់ហេតុសួរយកចម្លើយជនត្រូវចោទ ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញ កំណត់ហេតុដេញដោលចំពោះមុខជនត្រូវចោទ ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញ មាត្រា ២០៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ជាគោលការណ៍ជនត្រូវចោទត្រូវមានសេរីភាព ។

( ក្រោយពីបានស៊ើបសួរ និងពិនិត្យពិចារណាត្រឹមត្រូវតាមច្បាប់ហើយ )